ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ប្រជាជនខ្មែរជឿលើផ្កាយដុះកន្ទុយជាងជឿលើកំណត់ហេតុ
- យុត្តិធម៌អន្តរកាល និងសុខភាពផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២២០ ខែមេសា ឆ្នាំ២០១៨

# ស្វែងរកការពិត

លេខ២២០ ខែមេសា ឆ្នាំ២០១៨

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ ប្រជាជនខ្មែរជឿលើផ្កាយដុះកន្ទុយជាងជឿលើកំណត់ហេតុរបស់ ............១

**ផ្នែកឯកសារ**

◆ សចម្លើយសារភាពរបស់ យាង ស៊ីមហន ហៅ ប៊ុត លេខាតំបន់.............៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ១៧ មេសា ១៩៧៥ ជាថ្ងៃទុក្ខលំបាកវេទនារបស់ប្រជាជនខ្មែរ............៩

◆ ការចងចាំរបស់ ម៉ែន ឡឿន ពីព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា.............១១

◆ បុណ្យចូលឆ្នាំខ្មែរបែរជាគ្រួសារខ្ញុំត្រៀមភៀសខ្លួន ............................១៣

◆ តើប្រជាជនកម្ពុជាទទួលបានយុត្តិធម៌អ្វីខ្លះ បន្ទាប់ពី២០ឆ្នាំ..................១៥

◆ រដូវចូលឆ្នាំខ្មែរជាខែដែល យន ចាំមិនភ្លេច ....................................២០

◆ ជា សែន អតីតកម្មាភិបាលខ្មែរក្រហម ជនជាតិចារ៉ាយ ....................២២

◆ ការជម្លៀសគ្រូបង្រៀន និងមន្ត្រីរាជការ នៅខេត្តប៉ៃលិន...................២៤

◆ សិលាចារិកមួយផ្ទាំងត្រូវបានរកឃើញនៅស្រុកអន្លង់វែង ...................៣០

**ផ្នែកច្បាប់**

◆ អំណះអំណាងមេធាវីការពារក្តីរបស់ នួន ជា ក្នុងការបិទបញ្ចប់.......៣៣

**វេទិកាពិភាក្សាសាធារណៈ**

◆ យុត្តិធម៌អន្តរកាល និងសុខភាពផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជា.............៣៧

◆ សំឡេងចេញពីអន្លង់វែងជុំវិញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥.......៤៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ៧ មករា ១៩៧៩ ដល់ ៧ មករា ២០១៨ ..............................៤៩

◆ ព្រលឹងមាសម្តាយ ..........................................................៥



យោធាខ្មែរក្រហមចូលក្រុងភ្នំពេញ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** ៖ អ៊ុន សុដាវី, គីម សុវណ្ណដានី, លី សុខឃាង, រ៉ូនិត អារី, ម៉ាក ដូរី, សួត វិចិត្រ, ស សារិន, អ៊ុង វណ្ណា **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ ឆេង វើង, ហូ ថុនា, ដារ៉ារដ្ឋ មេត្តា **អ្នកបកប្រែ** ៖ ម៉ែន ឡឿន **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ជំនួយការនិពន្ធនាយក** ៖ សោម ប៊ុនថន, ឡុង ដានី **ក្រាហ្វិកកុំព្យូទ័រ** ៖ សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ** ៖ សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, khmerrougehistory.org www.truthcambodia.com**

# ប្រជាជនខ្មែរជឿលើផ្កាយដុះកន្ទុយជាង ជឿលើកំណត់ហេតុរបស់ អ៊ិត សារិន ពីការមក ដល់នៃក្រុមខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ប្រជាជនខ្មែរតែងមានជំនឿទៅលើអព្ភូតហេតុអស្ចារ្យនៃផ្កាយដុះកន្ទុយ ។ អព្ភូតហេតុនេះបានកើតឡើងយូរៗម្តង និងបានបញ្ចេញពន្លឺភ្លឺច្បាស់ពីទិសខាងកើតឆៀងខាងជើងនាពេលព្រឹកព្រលឹម ដែលអាចឲ្យយើងមើលឃើញពីចម្ងាយ ។ អព្ភូតហេតុអស្ចារ្យនេះ បានកើតឡើងនៅប្រទេសកម្ពុជានៅដើមទសវត្សរ៍ឆ្នាំ១៩៧០ នៅអំឡុងពេលដែលមានរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ។ ប្រជាជនកម្ពុជារស់នៅទីក្រុងភ្នំពេញ ទីប្រជុំជនតាមបណ្តាខេត្តនានា និងជាពិសេសប្រជាជនរស់នៅតាមទីជនបទស្រុកស្រែចម្ការ ដែលបានឃើញអព្ភូតហេតុនេះច្បាស់ បានចំណាំ ហើយនិយាយតៗគ្នា និងមានប្រផ្នូលឲ្យដឹងមុនថា ប្រទេសកម្ពុជានឹងកើតមានចលាចលសង្គ្រាម និងគ្រោះទុរ្ភិក្សនៅពេលខាងមុខមិនខានឡើយ ។ ប្រជាជនខ្មែរនៅពេលនោះ បានជឿទៅលើអព្ភូតហេតុ ផ្កាយដុះកន្ទុយនេះ ជាជាងជឿទៅលើកំណត់ហេតុរបស់ អ៊ិត សារិន ដែលបានទៅចូលរួមជាមួយក្រុមខ្មែរក្រហមនៅក្នុងតំបន់រំដោះ អស់រយៈពេល៩ខែ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧២ រហូតដល់ដើមឆ្នាំ១៩៧៣ ។ គាត់បានកត់ត្រាយ៉ាងលម្អិតពីសកម្មភាពប្រចាំថ្ងៃការងារ និងមាគ៌ាដឹកនាំរបស់បដិវត្តន៍ខ្មែរក្រហម និងគ្រោះមហន្តរាយនៅពេលដែលប្រទេសធ្លាក់ក្រោមការគ្រប់គ្រងរបស់កុម្មុយនីស្តនាពេលខាងមុខ ។

ស្របពេលប្រទេសកម្ពុជាកំពុងរងឥទ្ធិពលពីសង្គ្រាមរវាងវៀតណាមខាងជើង និងខាងត្បូងដែលគាំទ្រដោយសហរដ្ឋអាមេរិក និងភាពរីករាលដោយសារការបះបោររបស់ប្រជាជននៅស្រុកសំឡូត ខេត្តបាត់ដំបងប្រឆាំងនឹងទាហានដែលរឹបអូសយកដីធ្លីរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ រួមជាមួយអំពើហិង្សា និងបាតុកម្មប្រឆាំងនឹងរបប លន់ នល់ ដែលផ្ទុះឡើងនៅក្នុងទីក្រុងភ្នំពេញ ក្រុងកំពង់ចាម និងតាមបណ្តាខេត្តមួយចំនួនទៀត ទើបធ្វើឲ្យប្រជាជនខ្មែរកាន់តែជឿជាក់ខ្លាំងលើការដំណាលពីផ្កាយដុះកន្ទុយនេះ ។

នៅពេលសង្គ្រាមបានផ្ទុះឡើង ទំនាយដែលបាននិយាយពីអនាគតរបស់នគររាជវង្ស នាម៉ឺន មន្ត្រី ប្រជានុរាស្ត្រ ដែលបានប្រមូលចងក្រងនៅក្នុងសៀវភៅ «ពុទ្ធទំនាយ» ឬ «ឥន្ទទំនាយ» របស់អ្នកនិពន្ធ ព្រះពោធិវង្ស នន្ទ ង៉ែត និង ធន់ ហ៊ិន ក៏ត្រូវបានលើកមកនិយាយតៗគ្នាដែរ ដូចជាឃ្លាថា «មានផ្ទះតែគ្មានមនុស្សនៅ មានផ្លូវតែគ្មានមនុស្សដើរ» ។ «ទឹកហូរច្រាស់ឡើងលើ មិនព្រួយដើរហើរ ហោះបានរាល់គ្នា» ។ យកកប្បាសទិញដូរម្ជុលស្លាអស់ប្រាក់ទៅណា វិនាសបាត់បង់ ។ ក្រៅពីឃ្លាខាងលើ ក៏មានការសរសេរពាក្យកាព្យដែរ ដូចជា ៖ «ផ្គរលាន់ឯបូព៌ាត្រកណ្តក អ្នកតាចាស់ស្រុកឱបដៃយំ កំពិសឡើងពងកំពូលភ្នំ ក្អែកសសម្ងំក្នុងគុម្ពត្រែង» ពោធិ៍ព្រឹក្សរាបគល់ពុំចាក់ឫស ពស់វែកត្រាំពិសផ្តាំកន្ទែង ក្របីលាក់ខ្លួនសម្រួចស្នែង រាជហង្សដើរស្វែងកាប់សំបុក« ពពេចក្រាបពងក្រោមគង្គា ក្អែកពាំផ្លែល្វារាយគ្រប់ស្រុកអ្នកផងឃើញហើយខំរើសទុក តំណទៅមុខទើបដឹងខ្លួន» ជាដើម ។ ទំនាយទាំងនេះធ្វើឲ្យប្រជាជនជាច្រើនជឿថា ជាសញ្ញាណ នៃការប្រែប្រួល និងផ្លាស់ប្តូររបបដឹកនាំសង្គមនៅពេលឆាប់ៗ ជាពិសេសសំដៅទៅលើក្រុមបដិវត្តន៍ខ្មែរក្រហម ដែលបានឃោសនា និងពង្រីកកម្លាំងកាន់តែធំ ហើយបានវាយលុកកាន់តែខ្លាំងក្លា និងប្រព្រឹត្តឃោរឃៅលើប្រជាជននៅតាមទីជនបទ តាមទីប្រជុំជន និងក្រុងនានា ។ ទំនាយដែលប្រជាជនខ្មែរកាន់ព្រះពុទ្ធសាសនាលើកមកនិយាយតៗគ្នាមកនោះ ស្របទៅនឹងបរិបទប្រវត្តិសាស្ត្រ និងការដឹកនាំរបស់ក្រុមខ្មែរក្រហម ។

អ៊ុន វណ្ណា ជាសិស្សសាលានៅក្នុងក្រុងព្រៃវែងនៅមុនពេលយោធាខ្មែរក្រហមបានចូលមកគ្រប់គ្រងប្រទេស បានសរសេររៀបរាប់នៅក្នុងសៀវភៅ ដែលមានចំណងជើង «ព្រលឹងមាសម្តាយ» របស់គាត់ថា នៅព្រឹកព្រលឹមថ្ងៃមួយ ពេលគាត់ក្រោកដំបាយដើម្បីខ្ចប់ទៅហូបនៅសាលារៀន ស្រាប់តែគាត់ឮសំឡេងស្រែកខ្ទានឡើង «ផ្កាយព្រឹកដុះកន្ទុយ! ផ្កាយព្រឹកដុះកន្ទុយ!» ។ ផ្កាយដុះកន្ទុយនេះ លេចចេញពីទិសបូព៌ជះរស្មីឆ្ពូតវែងមកចំស្រុកខ្មែរ ។ វណ្ណា បានរត់ទៅផ្ទះ អ៊ំ សៀន ដែលជាចាស់ទុំនៅក្នុងភូមិដើម្បីស្តាប់ការបកស្រាយ ។ សំឡេងជ្រួលច្របល់ អ៊ូអរ ក៏ចាប់ផ្តើមលាន់ឮឡើងពីមាត់មួយទៅមាត់មួយ ជួយមើល! ជួយមើល! ផ្កាយព្រឹកដុះកន្ទុយ! ផ្កាយព្រឹកដុះកន្ទុយ! កន្ទុយបាញ់ចំស្រុកយើង ច្បាស់ជាមានសង្គ្រាមទុរ្ភិក្សកើតឡើងជាមិនខានឡើយ ។ ចាប់តាំងពីពេលនោះមក វណ្ណា បានសង្កេតឃើញមានការវាយប្រយុទ្ធគ្នារវាងកងកម្លាំងបដិវត្តន៍ខ្មែរក្រហម និងកងទ័ព លន់ នល់ បានកើតឡើងជាច្រើនលើកច្រើនសារ រួមទាំងការទម្លាក់គ្រាប់បែកបណ្តាលឲ្យស្លាប់ប្រជាជនក្នុងភូមិស្រុករបស់គាត់ទៀតផង ។ វណ្ណា តែងតែស្តាប់ចាស់ៗជជែកគ្នាពីអព្ភូតហេតុ និងទំនាយផ្សេងទាក់ទងស្រុកទេសរហូតដល់របប លន់ នល់ ដួលរលំ ។

ម៉ែន ឌឿន ជាសិស្សសាលាបឋមសិក្សានៅក្នុងក្រុងកំពង់ចាមនៅក្នុងរបប លន់ នល់ បានរៀបរាប់ថា ប្រហែលពីរខែក្រោយរដ្ឋប្រហារមានហេតុការចម្លែកមួយមួយបានកើតឡើង គឺផ្កាយដុះកន្ទុយ ដែលអ្នកក្រុងកំពង់ចាម និងអ្នកនៅខាងកើតទន្លេកំពង់ចាម បានមើលឃើញប្រហែលម៉ោង៥ទៀបភ្លឺ ។ ព្រឹកមួយពេលគាត់ឈឺធ្មេញថ្គាម ឪពុករបស់គាត់បានជូនគាត់ទៅព្យាបាល និងដកធ្មេញនៅមន្ទីរពេទ្យកំពង់ចាម ។ គាត់ក៏បានដើរទៅស្តាប់ចាស់ៗនៅមុខបន្ទប់ពេទ្យធ្មេញ ។ ចាស់ៗទាំងនោះមកពីស្ទួង បាននិយាយពីផ្កាយដុះកន្ទុយដែលជាប្រផ្នូលអាក្រក់សម្រាប់ប្រទេសជាតិ ។ ក្រោយមក គាត់បានឃើញហ្វូងបាតុករដើរតវ៉ានៅតាមដងផ្លូវនៅក្រុងកំពង់ចាម សំដៅចូលមកក្រុងភ្នំពេញ ដើម្បីទាមទារឲ្យសម្តេចព្រះ នរោត្តម សីហនុ យាងត្រឡប់មកកាន់អំណាចវិញ ។ ហ្វូងបាតុករទាំងនេះបានទៅរុះរើសម្ភារ ដុតឯកសារ វាយបំផ្លាញសាលាដំបូង សាលាស្រុក និងសាលាខេត្តកំពង់ចាម ។ អ្នកដែលដឹកនាំហ្វូងបាតុករចូលមក ហាក់ដូចជាបានស្គាល់ទីកន្លែងទាំងនោះយ៉ាងច្បាស់ ដែលអាចជាក្រុមចលនារបស់ខ្មែរក្រហម ។ បាតុកម្ម



យោធាខ្មែរក្រហមចូលក្រុងភ្នំពេញ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។

នេះបានប្រែក្លាយទៅជាហិង្សា ហើយបាតុករបានចាប់តំណាងរាស្ត្រឈ្មោះ សុស សាអ៊ុន សម្លាប់ និងវះយកថ្លើម និងសម្លាប់តំណាងរាស្ត្រម្នាក់ទៀត ដែលមកចរចា និងដោះស្រាយនូវការទាមទាររបស់ហ្វូងបាតុករ នៅម្តុំរោងចក្រតម្បាញក្រុងកំពង់ចាម ។ ឌឿន បានបន្តថា ទាំងនេះជាការចំណាំតៗគ្នាមក ដោយសារប្រទេសខ្មែរបានជួបប្រទះនូវសង្គ្រាមរាំងជល់ជាច្រើនលើកច្រើនសារអំពើហិង្សា និងជារឿងពិតដែលបានកើតឡើងចាប់ពីខែឧសភា ឆ្នាំ១៩៧០ រហូតដល់ខ្មែរក្រហមចូលមកដល់ឆ្នាំ១៩៧៥ ។

អ៊ំ សុផាន់ កើតនៅក្រុងភ្នំពេញ និងមានអាយុ៨ឆ្នាំ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ បានមានប្រសាសន៍ថា នៅព្រឹកព្រលឹម ថ្ងៃមួយ ជីតារបស់គាត់ឈ្មោះ ហែម ខាន់ ជាអាចារ្យនៅវត្តថាន់ បានដាស់គាត់ឲ្យក្រោកពីដំណេកមើលផ្កាយដុះកន្ទុយ ។ សុផាន់ បានបើកបង្អួចផ្ទះរបស់គាត់ដែលកាលនោះស្ថិតនៅខាងក្រោយព្រះបរមរាជវាំង មើលឃើញផ្កាយនោះយ៉ាងច្បាស់ ដែលជះពន្លឺមកពីទិសខាងកើត ។ បន្ទាប់ពីបានមើលផ្កាយដុះកន្ទុយរះតារបស់គាត់ បាននិទានប្រាប់គាត់ថា «ចៅ ចាំសង្កេតមើល នៅពេលមានផ្កាយដុះកន្ទុយកើតឡើង មិនយូរប៉ុន្មានស្រុកភូមិ នឹងកើតទុរ្ភិក្សកើតសង្គ្រាមវឹកវរមិនខានឡើយ ហើយនៅគ្រប់ទិសទីនឹងមានទុងស្គរ ដាស់ប្រជារាស្ត្រឲ្យក្រោកឡើងការពារផ្ទះសម្បែង ភូមិដ្ឋានរបស់ខ្លួន» ។ បន្ទាប់ពីបានស្តាប់តារបស់គាត់និទានរួចមក នៅអំឡុងពេលវិស្សមកាលរយៈពេលបីខែពីការសិក្សា ឆ្នាំ១៩៧៣ សុផាន់ បានទៅលេងស្រុកកំណើតនៅឃុំត្នោត ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។ នៅទីនោះ សុផាន់ បានឃើញកងទ័ពវៀតកុង និងវៀតមិញ ចេញចូលក្នុងភូមិឃុំរបស់គាត់ជាញឹកញាប់ ហើយនៅក្នុងភូមិឃុំរបស់គាត់ក៏ចាប់ផ្តើមច្របូកច្របល់ ។ សុផាន់ មិនអាចត្រឡប់មកភ្នំពេញបានទេ ដោយសារអសន្តិសុខដូច្នេះ ពូរបស់គាត់ឈ្មោះ ហែម បណ្ឌិត ជាសាស្ត្រាចារ្យនៅសាលាបឹងត្របែក បានជួលក្រុមស៊ើបការណ៍ «ឆ្មាខ្មៅ» របស់ទាហាន លន់ នល់ ឲ្យចូលទៅក្នុងភូមិ រំដោះយកគាត់ទាំងយប់មកក្រុងស្វាយរៀងវិញ ។ បន្ទាប់មក ពូរបស់ សុផាន បានទិញសំបុត្រយន្តហោះឲ្យ សុផាន់ ជិះត្រឡប់មកភ្នំពេញវិញ ព្រោះផ្លូវជាតិលេខមួយត្រូវបានខ្មែរក្រហមកាត់ផ្តាច់ និងគ្រប់គ្រង ។



សង្គ្រាមបានផ្ទុះឡើងកាន់តែខ្លាំងរវាងកងកម្លាំងបដិវត្តន៍ខ្មែរក្រហម និងរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់ លន់ នល់ រហូតមកដល់ឆ្នាំ១៩៧៥ ហើយប្រហែលដោយសារប្រជាជនខ្មែរដក់ជាប់ជាមួយអភ្នូតហេតុផ្កាយដុះកន្ទុយ ពុទ្ធទំនាយ និងមិនបានគបគខ្លាំងក្លាទៅលើក្រុមបដិវត្តន៍ខ្មែរក្រហមវិញ ទើបបណ្តោយឲ្យខ្មែរក្រហមដែលបានហាមឃាត់ដាច់ខាតទៅលើជំនឿអរូបិយទាំងនេះ និងការគោរពប្រណិប័តន៍សាសនានៅក្នុងអំឡុងពេលដែលខ្លួនដឹកនាំចលនាតស៊ូ ទទួលបានជ័យជម្នះទៅលើរបប លន់ នល់ យ៉ាងងាយស្រួល ។

សង្គ្រាមរវាងក្រុមបដិវត្តន៍ខ្មែរក្រហម និងរបបសាធារណរដ្ឋខ្មែរបានបញ្ចប់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលត្រូវនឹងថ្ងៃចូលឆ្នាំខ្មែរ ។ ប៉ុន្តែក៏ជាថ្ងៃដែលក្រុមខ្មែរក្រហមបានចាប់ផ្តើមជម្លៀស និងបង្ខំប្រជាជននៅទីក្រុង ឲ្យចាកចេញពីផ្ទះសម្បែង និងជាថ្ងៃដែលប្រជាជនកម្ពុជាចាប់ផ្តើមរងទុក្ខវេទនា បែកបាក់គ្រួសារ និងស្លាប់អស់ប្រមាណជិតពីរលាននាក់ ។

**សោម ប៊ុនថន**

# ចម្លើយសារភាពរបស់ យាង ស៊ីមហាន ហៅ ប៊ុត លេខាតំបន់១០៥ ភូមិភាគពាយ័ព្យ

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព D០២៧០១*

យាង ស៊ីមហាន ហៅ ប៊ុត ភេទប្រុស អាយុ៣៧ឆ្នាំ (ក្នុងឆ្នាំ ១៩៧៨) ។ ប៊ុត មានស្រុកកំណើតនៅខេត្តកំពង់ចាម ។ ឪពុករបស់ ប៊ុត ឈ្មោះ យាង ជាប និងម្តាយឈ្មោះ ផែ ស៊ីន មានមុខរបរដាំម្លូរ និងដាំបន្លែបង្ការ ។

បើតាមចម្លើយសារភាពរបស់ យាង ស៊ីមហាន ហៅ ប៊ុត ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ នៅថ្ងៃទី២៨ខែតុលា ឆ្នាំ១៩៧៨ បានសរសេររៀបរាប់ថា៖

នៅចុងឆ្នាំ១៩៦២ ប៊ុត បានបញ្ចប់ការសិក្សានៅវិទ្យាល័យកំពង់ចាម និងបានមករៀនបន្តនៅមហាវិទ្យាល័យវិទ្យាសាស្ត្រនៅទីក្រុងភ្នំពេញ ។ ដោយសារស្ថានភាពក្រលំបាក និងគ្មានសាច់ញាតិនៅភ្នំពេញ ប៊ុត បានដាក់ពាក្យស្នាក់នៅទីស្នាក់ការមិត្តសិស្សចាស់តាមរយៈបងប្រុសរបស់ខ្លួនឈ្មោះ យាង ជួន ។ ពេលស្នាក់នៅទីស្នាក់ការមិត្តសិស្សចាស់ ប៊ុត បានក្លាយជាសមាជិកសម្ព័ន្ធយុវជនកម្ពុជាប្រជាធិបតេយ្យ ។ ដោយមានឈ្មោះ ឡេង ប៊ុនសុង បាននាំ ប៊ុត ទៅខ្ទេសនាមជូនបង ពេញ (អៀង សារី) ។ បង ពេញ បានខ្ទេសនាម ប៊ុត ឲ្យជួប មិត្តខឹម (ដាំដេង) ដែលស្នាក់នៅទី



រូបកណ្តាលជួរខាងមុខ ៖ យាង ការអូន ត្រូវជាប្អូនប្រុសរបស់ យាង ស៊ីមហាន សព្វថ្ងៃរស់នៅខេត្តប៉ៃលិន

ស្នាក់ការមិត្តសិស្សចាស់ជាមួយគ្នា ។

ក្រោយមក នៅខែតុលាឆ្នាំ១៩៦២ ឈ្មោះ ទឹម បានហៅ ប៉ិត ទៅផ្ទះរបស់ឈ្មោះ ថាច់ គីមសឺន ដើម្បីប្រកាសចាត់តាំងគណៈយុវជនកម្ពុជាប្រជាធិបតេយ្យក្រុង និងបែងចែកតួនាទី ។ នៅផ្ទះ ថាច់ គីមសឺន ប៉ិត បានជួបជាមួយ ឈ្មោះ ថាច់ ញ៉ឹង ឈ្មោះ ស៊ុំ (គង់ សុផល) និង ឈ្មោះ ឆាំ (ស៊ាត ឆែ) ។ ក្រោយមក ប៉ិត ថាច់ គីមស៊ឺន និង ថាច់ ញ៉ឹង ត្រូវបានចាត់តាំងឲ្យអូសទាញនិស្សិតផ្នែកមហាវិទ្យាល័យឲ្យចូលបដិវត្តន៍ ។ ឆាំ ទទួលអូសទាញផ្នែកសាលាឈ្នួល ទឹម ផ្នែកមធ្យមសិក្សាខាងរដ្ឋ ។ ការប្រជុំនេះត្រូវប្រព្រឹត្តទៅជារៀងរាល់កន្លះខែម្ដង និង មួយខែម្ដងសម្រាប់គណៈរួម ។

ដោយមានការណែនាំពីឈ្មោះ ឆាំ ប៉ិត បានចូលធ្វើគ្រូបង្រៀន នៅសាលាកម្ពុជបុត្រ ផ្នែកវិទ្យាសាស្ត្ររូបនិយម និងគីមីថ្នាក់ទី៤ទំនើប ដើម្បីបានប្រាក់ខ្វះផ្គត់ផ្គង់ជីវភាព ។ ក្រោយមក ឆាំ បានណែនាំឲ្យ ប៉ិត ចូល សេ-អ៊ី-អា ហើយឈ្មោះ ឆាំ បានរៀបរាប់កម្លាំងខ្វះៗ ដែលជាខ្មែរ សេ-អ៊ី-អា បង្កប់ក្នុងជួរបដិវត្តរួមមាន ឈ្មោះ កែវ មាស ឈ្មោះ ដូ ដេត ឈ្មោះ ជ័យ នួន ឈ្មោះ ប៉ិនថាន់ និង ឈ្មោះ អន ជាដើម ។ ប៉ិត បានសម្រេចចិត្ត ចូល សេ-អ៊ី-អា ហើយថែមទាំងបានអូសទាញបានឈ្មោះ ទួន សុខផល្លា នៅមហាវិទ្យាល័យគណិតសាស្ត្រឲ្យចូលសេ-អ៊ី-អាទៀតផង ។

នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៦៥ ប៉ិត បាចខិតប័ណ្ណដើម្បីអូសទាញយុវជនឲ្យចូលបដិវត្តន៍តែត្រូវបានគិញដឹង ។ បន្ទាប់ពីគិញដឹងសម្ភភាពទាំងនោះ ប៉ិត និងបក្ខពួកបានរត់គេចខ្លួន ។ ប៉ិត បានទៅមន្ទីរ១០០ ឬមន្ទីរដើមផ្ដៀក ស្ថិតនៅក្នុងទឹកដីយួនក្បែរព្រំដែនក្នុងស្រុកមេមត់ ។ នៅមន្ទីរ១០០ មានឈ្មោះ ទុំ ជាលេខាមន្ទីរ ស្ដើង និង សឿង ជាសមាជិក ។ ប៉ិត ទៅដល់មន្ទីរ១០០ ត្រូវបានបង ពេញ ឲ្យធ្វើជាពេទ្យព្យាបាលកម្មាភិបាលនៅក្នុងមន្ទីរ ។ នៅមន្ទីរ១០០នេះក៏មានសមាសភាព សេ-អ៊ី-អា ខ្វះបង្កប់ក្នុងនោះដែរ ។ នៅខែកក្កដា ឆ្នាំ១៩៦៥ បងពេញ បានបញ្ជាឲ្យ ប៉ិត ទៅរៀនពេទ្យជាមួយយួនដែលបានបើវគ្គពេទ្យមធ្យមនៅក្នុងព្រៃ ។

ឆ្នាំ១៩៦៦ ក្រោយបញ្ចប់វគ្គពេទ្យ ប៉ិត បានត្រឡប់មកមន្ទីរ១០០វិញ ។ នៅខែកញ្ញា ឆ្នាំ១៩៦៦ បងទី១ (ប៉ុល ពត) បានមកដល់មន្ទីរ១០០ ជាមួយឈ្មោះ ប្រាង ឈ្មោះ វី និងកម្មាភិបាលជនជាតិចារាយម្នាក់ឈ្មោះ ថឺន ។ បន្ទាប់ពីបងទី១ បានមកដល់មន្ទីរ១០០ គាត់ចាប់ផ្ដើមរៀបចំសន្និបាតមជ្ឈិមដើម្បីឲ្យរៀបចំលក្ខណៈសម្បត្តិធ្វើសង្គ្រាមប្រជាជន រួមទាំងបង្រៀនពីរបៀបធ្វើចម្រូងខ្នា អន្ទប់ អន្ទុង ជាដើម ។ កម្មាភិបាល សេ-អ៊ី-អា ដែល ប៉ិត បានស្គាល់រួមមានឈ្មោះ វេត ឈ្មោះ ស៊ី ឈ្មោះ ស៊ុំ ឈ្មោះ ដឹង និងក្រោយមកតាមរយៈ ប៉ង់ និង ទុំ បានឲ្យដឹងថា បង ពុ រួមមាន ភឹម ភួង ញឹម គុន ក៏ជា សេ-អ៊ី-អា ដែរ ។ ប៉ង់ និង ទុំ បានឲ្យដឹងទៀតថា បង ពុ ខាង សេ-អ៊ី-អា បានទាក់ទងគ្នាដើម្បីមានវិធានការណ៍ទប់ទល់ដែនការត្រៀមរៀបចំសង្គ្រាមបដិវត្តរបស់បក្ស ។

បន្ទាប់ពីសន្និបាតបក្សបានផ្លាស់ប្ដូរមន្ទីរ១០០ ទៅនៅភូមិភាគឦសានវិញ ។ ចុងខែតុលាឆ្នាំ១៩៦៦ បក្សរៀបចំគ្រួសារឲ្យ ប៉ិត ។ មុនពេលចេញដំណើរទៅភូមិភាគឦសាន បក្សបានបែងចែកកម្លាំងជាពីរផ្នែក ហើយត្រូវចេញដំណើរក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៦ ។ ផ្នែកដែលត្រូវចេញដំណើរជាមួយបងពេញ (អៀង សារី) រួមមានឈ្មោះធូ ឈ្មោះប្រាង ឈ្មោះ បងភឹម ឈ្មោះ តាវី ឈ្មោះ ថឺន ឈ្មោះ សុង ឈ្មោះ សឿង ឈ្មោះ ម៉ុល ឈ្មោះទៀក ឈ្មោះ ជីបា ឈ្មោះ ប៉ិត ប្រពន្ធរបស់ ប៉ិត ឲ្យឈ្មោះ បាន់ ស៊ីវ (ធិន) ខ និងឈ្មោះ តាន់ ចំណែកកម្លាំងដែលនៅសល់ នៅជាមួយបងទី១ទាំងអស់ ។ កម្លាំងដែលទៅរតនៈគីរីត្រូវធ្វើដំណើរអស់រយៈពេលជាងមួយខែដោយមានឈ្មោះ ប្រាង ជាអ្នកស្គាល់ភូមិសាស្ត្រ និងនាំផ្លូវ ។ បន្ទាប់ពីទៅដល់រតនគីរី កម្មាភិបាលខ្មែរក្រហមបានធ្វើការផ្លាស់ប្ដូរឈ្មោះជៀសវាងកុំឲ្យបែកការណ៍ បង ពេញ បានប្ដូរឈ្មោះ វ៉ាន់ បង គឹម ប្ដូរឈ្មោះ ខាំ ធូ ប្ដូរឈ្មោះ យ៉ា វី នៅឈ្មោះ វី ដដែល ព្រោះនៅភូមិភាគឦសានតាំងពីឆ្នាំ១៩៦២ ប៉ិត ប្ដូរឈ្មោះ ដាំ សឿង ប្ដូរឈ្មោះ វិន សុង ប្ដូរឈ្មោះ យ៉ុន ប្រពន្ធរបស់ ប៉ិត ប្ដូរឈ្មោះ ស៊ីផា ជីបា ប្ដូរឈ្មោះ យិន ភឿន ប្ដូរឈ្មោះ ថនម៉ូល ប្ដូរឈ្មោះ យ៉ាត់ ទៀក ប្ដូរឈ្មោះ ដែង និង ប្រាង ប្ដូរមកឈ្មោះ បុង ។ ក្រោយមកបង វ៉ាន់ បានលើកផែនការរៀបចំសាលា និងបើកវគ្គអប់រំកម្មាភិបាលទាំងអស់ ។ ចំណែកប្រាង ហៅ បុង ក្នុងឋានៈជាអនុរបស់បង វ៉ាន់ បានបានឆ្លៀតឱកាសហៅអ្នកក្រោម

បន្ទាប់មកប្រជុំម្តងពីរទៅបីនាក់ដោយណែនាំពីដំណើរការ និងការធ្វើសកម្មភាពពង្រីក សេ-អ៊ី-អា ទៅមុខទៀត ។ បុង បានណែនាំថា បក្សកម្មុយនីស្តកម្ពុជា (នៅពេលនោះនៅជាបក្សពលករកម្ពុជានៅឡើយ) បានសម្រេចរៀបចំលក្ខណៈសម្បត្តិដើម្បីធ្វើសង្គ្រាមបដិវត្តន៍ហើយ យើងបានតស៊ូមតិខ្លះៗក្នុងគណៈដឹកនាំដែរ ដើម្បីទប់ផែនការនេះតែកន្លងទៅយើងមិនបានតស៊ូខ្លាំងទេ ព្រោះខ្លាចបែកការណ៍អំពីកម្លាំងយើងនៅក្នុងគណៈដឹកនាំបក្ស ។ ក្រោយពីបិទវគ្គកម្លាំងទាំងអស់ត្រូវបែកគ្នា មានបង ខាំ ទៅទទួលតំបន់១០៨ជាមួយតាវី យ៉ា ទៅទទួលតំបន់១០៥ (មណ្ឌលគិរី) ជាមួយបង ឡាំង ។ ចំណែកបង វ៉ាន់ ទៅរតនគិរី (១០២) ។ ប៊ុត នៅធ្វើការជាមួយបង វ៉ាន់ និងធ្វើជាពេទ្យព្យាបាលកម្មាភិបាលដែលបង វ៉ាន់ អញ្ជើញមករៀនសូត្រផង និងព្យាបាលប្រជាជននៅតាមចម្ការជិតៗកន្លែងបើកវគ្គផង ។

ក្រោយមកក្នុងខែកក្កដា ឆ្នាំ១៩៦៧ ប៊ុត និង តាន់ (យុវជនមន្ទីរពលីពេលផ្ទុះអាវុធដំបូង) ត្រូវបានបង វ៉ាន់ បញ្ជាឲ្យជួបឈ្មោះ យ៉ា ដើម្បីទៅទទួលបងទី១ នៅព្រំប្រទល់ក្រចេះ និងមណ្ឌលគិរី ។ ពេលបានជួបជាមួយបងទី១ ប៊ុត បានឃើញ សោ ភឹម ពាង (ហង់ លេខា១០៣) ខន គណៈ១០៤ និង យ៉ា ។ ពេលនោះមន្ទីរ១០០ ត្រូវបានរៀបចំឲ្យនៅជិតមន្ទីរ១០២ ។ បងទី១ បានបើកវគ្គដោយអញ្ជើញកម្មាភិបាលក្នុងភូមិភាគមករៀនត្រៀមរៀបចំដើម្បីប្រើហិង្សាទប់ទល់ឧបាយកលខ្មាំង ។ នៅឆ្នាំ១៩៦៧នេះដែរ បងទី១ ឈឺធ្ងន់ ។ នៅឆ្នាំ១៩៦៩ អង្គការបានឲ្យ ប៊ុត ទៅរៀបចំមន្ទីរថ្មី នៅក្នុងស្រុកអណ្តូងមាសខាងជើង ។ ប៊ុត មិនសូវបាននៅមន្ទីរទេ ព្រោះអង្គការបានបញ្ជាឲ្យទៅដើររៀបចំមន្ទីរជម្រៀស ។ ចុងឆ្នាំ១៩៦៩ ពេលបងទី២ទៅដល់មន្ទីរ១០០បានជួបបងទី១ ហើយ បងទី១ បានរៀបចំចេញដំណើរទៅក្រៅប្រទេសដោយយក បុង និងគ្រួសារទៅជាមួយដែរ ។ បុង បានហៅ ប៊ុត និង រិន មកផ្តាំផ្ញើថា ឲ្យធ្វើសកម្មភាពប្រឆាំងបក្សតាមការណែនាំរបស់ យ៉ា ចុះ ។ នៅដើមឆ្នាំ១៩៧០ ពេលប្រជុំភូមិភាគ ប៊ុត បានជួបជាមួយ យ៉ា និងរាយការណ៍តាមអ្វីដែល បុង បានផ្តាំផ្ញើ ។

នៅខែឧសភា ឆ្នាំ១៩៧០ បន្ទាប់ពីរដ្ឋប្រហារកម្លាំងរបស់អាមេរិកបានដាក់ទ័ពនៅគ្រប់មូលដ្ឋានដែលជាទីតាំងរបស់មន្ទីរទាំងអស់របស់ខ្មែរក្រហម ។ ដូច្នេះខ្មែរក្រហមបានប្រមូលកម្លាំងយោធាទាំងអស់មកនៅមន្ទីរក៥ ជំនួសឲ្យមន្ទីរ១០០ ។ ដោយនៅមូលដ្ឋាននោះប្របូកប្របល់ខ្លាំង ប្រជាជនរត់រតាត់រតាយខ្លះបានរត់ចូលដីវៀតណាម ។ ពេលនោះក៏មានឧទ្ធម្ភាចក្ររបស់អាមេរិកប្រមាណជាង២០គ្រឿង បានឆាបចុះឆាបឡើងដើម្បីទម្លាក់គ្រាប់បែកដុតព្រៃ ។ បង វ៉ាន់ កោះប្រជុំរួមមាន គណៈមន្ទីរ កម្មាភិបាលយោធាឈ្មោះ ខាំ ឈ្មោះ ភា (អៀង ធារិទ្ធ) ដែលមានគ្នាប្រហែលជា១០នាក់ ដើម្បីដោះស្រាយបញ្ហាជាបន្ទាន់ ។ ប៊ុត បានឲ្យយោបល់ថា ត្រូវជម្លៀសកម្លាំងទៅវ៉ឺនសៃ ។ នៅខែមិថុនា បង វ៉ាន់ បានហៅ ប៊ុត ទៅជួបដើម្បីរៀបចំដំណើរទៅទទួលបងទី១ នៅខាងកន្ទុយនាគ ។ បន្ទាប់មកបងទី១ ត្រូវចុះមករៀបចំកសាងមូលដ្ឋានបក្សថ្មីស្ថិតនៅភូមិភាគឧត្តរ ។ នៅភូមិភាគឦសានមានឈ្មោះ ខាំ ជាលេខា និងឈ្មោះ យ៉ា ជាអនុ និងឈ្មោះ វី ជាសមាជិក ។ នៅខែតុលា ឆ្នាំ១៩៧០ ខាំ បានហៅ ប៊ុត ឲ្យមកធ្វើការមូលដ្ឋាននៅតំបន់ដ-៥ ក្នុងស្រុកលំផាត់ក្រោមដែលជាស្រុកទើបតែរំដោះបានថ្មីៗ ។ ខាំ បានប្រគល់កងភាគមួយអនុសេនាធំ ដែលមានប្រធានឈ្មោះមិត្ត ចាន់ (ធាត់) ឲ្យមកជួយការពារនៅ ដ-៥ ។ ក្រោយមកក្នុងខែធ្នូ ឆ្នាំ១៩៧០ ខាំ បានហៅ ប៊ុត ទៅមន្ទីរភូមិភាគកាលនោះស្ថិតនៅ១២-ឃ នៅឡើយ ។ ពេលដែល ប៊ុត ទៅដល់បានជួប ខាំ និង យ៉ា ហើយបានរាយការណ៍ពីសភាពប្រជាជនសភាពខ្មាំង និងបញ្ហាកសាងកម្លាំងថ្មីរបស់ សេ-អ៊ី-អា ។ និយាយអំពីជីវភាពប្រជាជន ខាំ បានឲ្យ ប៊ុត គិតគូររកផ្លូវទិញអំបិលយកមកលក់ចែកជូនប្រជាជន ។ ខាំ បានឲ្យប្រាក់១០០០ដុល្លា យកទៅដូរ និងទាក់ទងទិញអំបិលយកមកដោះស្រាយនៅ ដ-៥ ។ នៅពេលនោះកម្មាភិបាលដែលគ្រប់គ្រងតំបន់រួមមាន ប៊ុត ទទួល ដ-៥ តាឡៅ ទទួល ដ-១ តា កង ដែង ទទួល ដ-២ មិត្ត កន ទទួល ដ-៣ និង តាវី ទទួល ដ-៤ ។

នៅខែមីនា ឆ្នាំ១៩៧១ យ៉ា បានហៅ ប៊ុត ទៅរៀននៅមន្ទីរ ដ-២ រួមជាមួយកម្មាភិបាលគ្រប់គ្រង ដ-២ និង ដ-១ ។ ដែលពេលនោះរៀនសូត្រពីការកសាងកម្លាំងឲ្យបានឆាប់រហ័ស ។ ក្រោយមកខែឧសភា ខាំ បានហៅ ប៊ុត ទៅជួបនៅស្ទឹងត្រែងជាប្រញាប់ដើម្បីឧទ្ទេសនាមពីសភាពការណ៍នៅស្ទឹងត្រែង ដែល

កម្មាភិបាលមកពីហាណូយគ្រប់គ្រងធ្វើផ្ដេសផ្ដាស់ បណ្ដាលឲ្យប្រជាជនមិនសប្បាយចិត្ត ។ ក្រោយមក ខាំ បានខទ្វេសនាម ប៉ិត ដឹកនាំនៅស្ទឹងត្រែង ជាពិសេសទីប្រជុំជនខេត្តស្ទឹងត្រែងតែម្ដង ដែលជាកន្លែងមានបញ្ហាស្មុគ្រស្មាញ ។ បន្ទាប់ពីទទួលភារកិច្ចនេះ ប៉ិត បានចូលទៅទីប្រជុំជនខេត្តស្ទឹងត្រែង ស្ទាបស្ទង់ក្ដាប់សភាពការណ៍ ។ ប៉ិត រាយការណ៍ទៅឲ្យ ខាំ ជារៀងរាល់កន្លះខែម្ដង ។ ដោយមានការណ៍ណែនាំពី ខាំ នោះ ប៉ិត បានខិតខំកសាងកម្លាំង និងគិតគូរពីបញ្ហាជីវភាពប្រជាជនកុំឲ្យដាច់ពោះស្លាប់ហើយ និងណែនាំឲ្យពង្រីកសហករណ៍លក់ដូរ ។

នៅដើមឆ្នាំ១៩៧២ យ៉ា បានរៀបចំប្រជុំនៅមន្ទីរភូមិភាគ ដោយខទ្វេសនាមឲ្យដឹងថា ខាំ ត្រូវអង្គការអញ្ជើញឲ្យទៅទទួលភារកិច្ចថ្មីៗ ។ យ៉ា បានប្រកាសប្រជុំចាត់តាំងពីគណៈភូមភាគថ្មី ដោយមាន យ៉ា ជាលេខាភូមិភាគ វី អនុលេខា ឡៅ សមាជិកអចិន្ត្រៃយ៍ ទឹម សមាជិក និង ប៉ិត សមាជិក ។ ពេលធ្វើសន្និបាតនៅភូមភាគក្បាសាន យ៉ា បាននិយាយផ្ដោតទៅលើកងទ័ពយួនដែលត្រៀមឈប់បាញ់ជាមួយអាមេរិក ។ អំពីផែនការកសាងកម្លាំងធ្វើយ៉ាងម៉េចឲ្យឃើត និងទិសដៅឆ្នាំ១៩៧២បក្សចង់ឲ្យប្រជាជនធ្វើស្រូវបាន៤០ភាគរយ ។

នៅឆ្នាំ១៩៧៣ យ៉ា បានរៀបចំឲ្យមានការប្រជុំម្ដងទៀត ដោយមានការចូលរួមពីគណៈភូមិភាគតែប៉ុណ្ណោះ ។ ការប្រជុំនេះបានលើកឡើងពីការពិនិត្យលើផែនការចាស់ ក្នុងការកសាងកម្លាំងមានភាពយឺតយ៉ាវ និងពិភាក្សាលើកពីសកម្មភាពថ្មី ពីការឈានទៅដល់ជ័យជម្នះកាន់តែឆាប់របស់ពួកកម្មុយនីស្ត ។ យ៉ា ក៏បានលើកផែនការរាំងស្ទះបក្សសម្រាប់ឆ្នាំ១៩៧៤ដែរ ។

ក្នុងឆ្នាំ១៩៧៤ តំបន់បានរៀបចំឲ្យមានសហករណ៍ និងបាយរួម ។ ប្រធានសហករណ៍ភាគច្រើនជាសមាសភាព សេ-អ៊ី-អា ចំណែកការបង្កបង្កើនផលមិនបានតាមការកំណត់របស់អង្គការទេ ព្រោះការងារនៅសហករណ៍មានការរាំងស្ទះ ភ្លៀងមិនទៀងទាត់ និងមានទឹកជំនន់ធំធ្វើឲ្យខូចខាតដំណាំប្រជាជន និងមានភាពអត់ឃ្លាននៅឆ្នាំ១៩៧៥ ។ នៅចុងឆ្នាំ១៩៧៤ យ៉ា បានផ្លាស់ចេញពីភូមិភាគក្បាសានទៅបំពេញភារកិច្ចថ្មី ដោយមានការចាត់តាំងគណៈភូមិភាគក្បាសានថ្មីរួមមាន វី ទទួលរួម និងតំបន់ (ដ-៣) ឡៅ អនុលេខាទទួលដ-១ ទឹម សមាជិកអចិន្ត្រៃយ៍ទទួល ដ-៥ និង ដ-២ ប៉ិត សមាជិកអចិន្ត្រៃយ៍ទទួល ដ-៤ និងដ-៦ ទុំសមាជិក (ខាងពាណិជ្ជកម្ម) ថារ៉ែន សមាជិក (អនុលេខា ដ-៦) និង ចាន់ សមាជិកដែលគ្រប់គ្រងខាងកសិកម្ម និងនយោបាយទឹក ។

នៅខែមករា ឆ្នាំ១៩៧៥ យ៉ា បានទៅនៅមន្ទីរនៅជិតព្រំដែនលាវ បានស្នាក់នៅមន្ទីរយួនរយៈពេល១ខែដើម្បីចាំទទួលភ្ញៀវ និងទទួលសម្ភារ ហើយ យ៉ា បានជួប ប៉ិតនៅមន្ទីរនោះដែរ ។ នៅខណៈនោះ អៀង សារី និង ខៀវ សំផន បានត្រឡប់មកពីក្រៅប្រទេសវិញ ។ យ៉ា បាននិយាយប្រាប់ បុង ពីសភាពការណ៍ថាបក្សនឹងឈ្នះក្នុងពេលឆាប់ៗនេះហើយព្រមទាំងណែនាំឲ្យយកចិត្តទុកដាក់បង្កប់ខ្លួន និងកម្លាំងតទៅមុខទៀតដើម្បីធ្វើសកម្មភាពសម្ងាត់ ។

នៅថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ នៅពេលដែលគណៈភូមិភាគកំពុងតែប្រជុំបានដឹងដំណឹងពីការរំដោះទីក្រុងភ្នំពេញដែលបក្សកម្មុយនីស្តកាន់កាប់ប្រទេសកម្ពុជាទាំងមូល ។ នៅខែឧសភា ឆ្នាំ១៩៧៥ អង្គការបានហៅ វី និង ឡៅ ទៅប្រជុំនៅទីក្រុងភ្នំពេញ ។ ក្នុងខែតុលា ឆ្នាំ១៩៧៥ ពេលដែល វី និង ឡៅ ត្រឡប់ពីធ្វើការជាមួយអង្គការនៅភ្នំពេញវិញ ឡៅ ប្រាប់ ប៉ិត ថា បក្សពលករកម្ពុជា សេ-អ៊ី-អា រៀបចំធ្វើមហាសន្និបាតមួយដែរ ដោយបានចាត់តាំង ភឹម ជាលេខា និង យ៉ា ជាអនុលេខា ព្រមទាំងលើកទិសដណ្ដើមរដ្ឋអំណាចដោយធ្វើរដ្ឋប្រហារ ។

នៅដើមឆ្នាំ១៩៧៦ អង្គការបានឲ្យ យ៉ា ត្រឡប់មកក្បាសានវិញ ។ ខែកុម្ភៈ ឆ្នាំ១៩៧៦ យ៉ា ឲ្យដឹងពីការដែលអង្គការរៀបចំគណៈក្បាសានថ្មីគឺភូមិភាគ១០៩ ដែលមាន យ៉ា ជាលេខា វី អនុលេខា (ទទួលក្បាសានខាងជើងនិងតំបន់១០១) ឡាំង សមាជិកអចិន្ត្រៃយ៍និងទទួលតំបន់១០៥ យី សមាជិកអចិន្ត្រៃយ៍និងទទួលតំបន់៥០៥ ឡៅ សមាជិកអចិន្ត្រៃយ៍និងទទួល១០៧ ទឹម សមាជិក និងទទួលតំបន់១០២ ប៉ិត សមាជិក និងទទួលតំបន់១០៤ ។

នៅខែមករា ឆ្នាំ១៩៧៦ យ៉ា បានបញ្ជាឲ្យ ប៉ិត ចរចាជាមួយយួនរឿងព្រំដែនជាជំនួបរវាងគណៈយោធាភាគតែមិនបានសម្រេច ។ ក្រោយមកខែកុម្ភៈ ឆ្នាំ១៩៧៦ យ៉ា បានត្រឡប់ទៅភូមិភាគក្បាសានម្ដងទៀត ដើម្បីរៀបចំចរចាជាមួយយួនពី

បញ្ហាព្រំដែន ដោយខាងភាគីយួនមានឈ្មោះ ទឹកាម តំណាងខាងមជ្ឈិម តែមិនបានចុះហត្ថលេខាលើចំណុចដែលមិនយល់ស្របគ្នាដដែល ។ ខែឧសភា យ៉ា បានមកប្រជុំនៅ១០៨ ដែលមានការចូលរួមពីកម្មាភិបាលចាប់តាំងពីស្រុករហូតដល់ភូមិភាគ ក្នុងការប្រជុំនេះយកផែនការរបស់ភូមិភាគ១០៩ នៅក្រចេះ និងផែនការបួនឆ្នាំដែលជាផែនការរបស់បក្សកម្មុយនីស្តកម្ពុជាក្នុងការកសាងសង្គមនិយម ។ យ៉ា បាននិយាយថា យើងត្រូវធ្វើដែរ តែមិនមែនកសាងសង្គមនិយមស្អីទេ ។ នៅខែសីហា យ៉ា បានហៅលេខា និងអនុលេខាតំបន់១០៧ ទៅប្រជុំនៅក្រចេះ ដើម្បីកំណត់ផែនការបួនឆ្នាំជូនអង្គការលើកនេះ យ៉ា មិនហ៊ានលើករឿងផ្សេងមកនិយាយទេព្រោះខ្លាច ឡាំង ដឹង ។

ប៊ុត បានសម្រាកពេទ្យពីខែសីហា ឆ្នាំ១៩៧៦ ដល់ ខែមករា ឆ្នាំ១៩៧៧ ទើបជា ។ ពេលអង្គការចាប់ យ៉ា បងទី២ បានហៅ ប៊ុត ពីពេទ្យទៅជួប និងប្រាប់ព័ត៌មានពីរឿងអង្គការចាប់ យ៉ាដែរ ។ ពេលបានដឹងរឿងនេះ ប៊ុត មានការបារម្ភខ្លាច យ៉ា សារភាពប្រាប់អំពីខ្សែ សេ-អ៊ី-អា ទាំងអស់ ។

នៅខែឧសភា ឆ្នាំ១៩៧៧ ឡោ ត្រូវបានអង្គការដកមកធ្វើការនៅភ្នំពេញ ។ ចាន់ ត្រូវបានទទួលតំបន់១០៧ជំនួស ឡោ ។ ការរៀបចំទំនាក់ទំនងទៅលាវ និងយួនមានការផ្លាស់ប្តូរ ។ ប៊ុត ត្រូវចាត់តាំងឲ្យទទួលទំនាក់ទំនងខាងលាវ ។ ចំណែកការទាក់ទងជាមួយយួនត្រូវធ្លាក់មកលើ ចាន់ ជាអ្នកទទួលជំនួសវិញ ។ នៅចុងខែមិថុនា ឆ្នាំ១៩៧៨ បក្សកម្មុយនីស្តកម្ពុជាបានហៅ វី ទៅភ្នំពេញ ។ នៅខែកក្កដា ឆ្នាំ១៩៧៨ អង្គការក៏បានហៅ ប៊ុត និង ទឹម មកជួបនៅភ្នំពេញដែរ ខាងអង្គការរួមមានបងទី១ បងទី២ វន ហើយខាងឦសានមានគណៈភាគទាំង៣នាក់ វី ប៊ុត និង ទឹម បងទី១ បានខ្ទេសនាមសភាពការណ៍ខាងក្នុង និងខាងក្រៅ អំពីរដ្ឋប្រហាររបស់ភឹម និងពីរឿងយួនបុកនៅឦសាន ។ បងទី១ ខ្ទេសនាម សារឿន និងដើមចូលក្នុងគណៈភាគឦសាន ។ បងទី១ ខ្ទេសនាម វន ឲ្យទៅកាន់ឦសានជាមួយ វី ប៊ុត និង ទឹម ដើម្បីប្រជុំខ្ទេសនាមគណៈភាគថ្មី និងវិធានការណ៍ដែលអង្គការបានសម្រេច ។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៧៨ ប៊ុត ទទួលសំបុត្រពី វន មួយច្បាប់ថា វី បានចងកសម្លាប់ខ្លួន និងឲ្យ ប៊ុត ទាក់ទងជាមួយយួនឲ្យជាប់ ។ ថ្ងៃទី៧ ខែកញ្ញាឆ្នាំ១៩៧៨ អង្គការបានហៅ ប៊ុត ទឹម ចាន់ ធិន និង បងរឿន មករៀននៅភ្នំពេញ ។ ពេលមកដល់ភ្នំពេញបានជួបជាមួយ សាន និង សារុន មកពីមណ្ឌលគិរីដែរ ។ រៀនចប់បងទី២ សួរ ប៊ុត ថាបើបក្សសម្រេចឲ្យមិត្តមកភ្នំពេញវិញ មិត្តគិតយ៉ាងណា? ប៊ុត ឆ្លើយថា តាមតែបក្ស ឥតមានសំណូមពរអ្វីទេ ។ ព្រឹកឡើងបងទី២ ហៅ ប៊ុត ទឹម ធិន និង បងសារឿន ជួបម្តងទៀត ដោយមានវត្តមាន វន ដែរ ។ បងទី២ ខ្ទេសនាមថា អង្គការ សម្រេចដក ប៊ុត និង ទឹម មកបំពេញភារកិច្ចថ្មីនៅភ្នំពេញ ហើយ រៀបចំគណៈភូមិភាគថ្មីនៅឦសានរួមមានៈ បងទី២ ជាលេខា បងរឿន អនុលេខា បង ដើម សមាជិក ធិន សមាជិក ចាន់ សមាជិក ។ ដោយមាន វន ទៅរៀបចំធ្វើសន្និបាតភូមិភាគ និងចាត់តាំងគណៈភូមិភាគថ្មី ។ នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៨ ប៊ុត និង ទឹម ចុះមកភ្នំពេញតាមកាណូត ។ នៅថ្ងៃទី១២ ខែតុលាឆ្នាំ១៩៧៨ បងទី២ ហៅ ប៊ុត និង ទឹម ទៅជួបសួរថាចង់ធ្វើអី? ប៊ុត និង ទឹម ថាចង់ធ្វើពលកម្មដែលមិនសូវគិត ។ នៅថ្ងៃទី១៤ ខែតុលា បងទី១ បានចូលមកនិយាយលេង និងថាចង់ធ្វើអី? កុំថាស្រេចតែអង្គការ ។ ទឹម ថាចង់ទៅសាលាបច្ចេកទេសចំណែក ប៊ុត ចង់ទៅខាងថ្នាំជាតិ ។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៨ សមមិត្ត លីន ជូន ប៊ុត និងគ្រួសារថា ទៅជួបអង្គការធ្វើការហើយ ប៊ុត ត្រូវអង្គការចាប់ខ្លួននៅពេលនោះតែម្តង ។

**ដារ៉ា រដ្ឋមេត្តា**


## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* និង *truthcambodia.com* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ!***

# ១៧ មេសា ១៩៧៥ ជាថ្ងៃ ទុក្ខលំបាកវេទនារបស់ប្រជាជនខ្មែរ

សម្រាប់ ដែលជាក្មេងជំនាន់ក្រោយធ្លាប់បានអានឯកសារ និងរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហមបានយល់ថាប្រជាជនខ្មែរដែលបានឆ្លងកាត់របបខ្មែរក្រហមមិនអាចភ្លេចបានទេ ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដែលជាថ្ងៃប្រវត្តិសាស្ត្ររបស់កម្លាំងតស៊ូខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ ។ រហូតមកដល់បច្ចុប្បន្ន ប្រជាជនខ្មែរនៅតែបន្តនិយាយ និងរំឭកពីព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ជាថ្ងៃសប្បាយរីករាយក្នុងអំឡុងពេលចូលឆ្នាំខ្មែរ និងក៏ជាថ្ងៃលំបាកវេទនារបស់ប្រជាជនខ្មែរ ។

នៅអំឡុងពេលនោះ ប្រជាជនខ្មែរនៅគ្រប់កន្លែងបានទទួលអបអរសាទរសប្បាយរីករាយជាមួយជ័យជម្នះរបស់ខ្មែរក្រហមដែលនៅចំពេលថ្ងៃចូលឆ្នាំខ្មែរ និងមានប្រជាជនខ្លះមានការភ័យខ្លាចទុក្ខព្រួយពីវត្តមានរបស់កងកម្លាំងរបស់ខ្មែរក្រហមដែលបានចូលមកដល់ទីក្រុងភ្នំពេញ ហើយក៏មានប្រជាជនខ្លះគិតថាប្រទេសជាតិមានសន្តិភាពដែរ ។ ប៉ុន្តែអ្វីដែលប្រជាជននឹកស្មានមិនដល់នោះ គឺមួយរយៈខ្លីប៉ុណ្ណោះប្រទេសកម្ពុជា ពិសេសទីក្រុងភ្នំពេញមានការប្រែប្រួលយ៉ាងខ្លាំង ដោយសារកងកម្លាំងរបស់ខ្មែរក្រហមបានសើបសួរប្រវត្តិរូប និងបាញ់សម្លាប់អតីតនាយទាហាន មន្ត្រីរដ្ឋការក្នុងរបប លន់ នល់ ។ ខ្មែរក្រហមបានបណ្តេញប្រជាជនខ្មែររួមជាមួយជនបរទេសឲ្យចាកចេញពីទីក្រុងទៅទីជនបទ ដោយបានឃោសនាថា នឹងមានការទម្លាក់គ្រាប់ពីសំណាក់សហរដ្ឋអាមេរិក ហើយមានតែជនបទទេទើបមានស្បៀងអាហារគ្រប់គ្រាន់ ដើម្បីចិញ្ចឹមបងប្អូន ។

នៅពេលជម្លៀសក្រោមកម្តៅថ្ងៃក្តៅហួតហែង ក្នុងខែមេសា មានប្រជាជនរាប់ពាន់នាក់ មានទាំងស្ត្រីមានផ្ទៃពោះ កុមារ អ្នកជំងឺចាស់ជរា បានស្លាប់នៅតាមផ្លូវ ដោយអត់មានស្បៀងអាហារហូបចុក និងគ្មានថ្នាំព្យាបាល ។ ការជម្លៀសនេះជានយោបាយដឹកនាំរបស់ខ្មែរក្រហមដោយមិនគិតពីភាពវេទនា និងទុក្ខលំបាកដែលប្រជាជននឹងទទួលរងឡើយ ។

ក្រោយពីជម្លៀសប្រជាជនទៅតាមទីជនបទ ទីក្រុងភ្នំពេញមានសភាពស្ងប់ស្ងាត់ប្រៀបបាននឹងទីក្រុងខ្មោច ប៉ុន្តែមានតែកម្មាភិបាលយោធាខ្មែរក្រហម និងកម្មកររស់នៅទៅវិញ ។ សណ្ឋាគារ រោងកុន ផ្សារ វត្តសាល ពេទ្យ សាលារៀន និង ផ្លូវ ដែលពោរពេញទៅដោយមនុស្សអ៊ូអរបានប្រែក្លាយទៅជាស្ងាត់ជ្រងំ ។ វត្តអារាមជាទីគោរពបូជា ក៏ត្រូវបានបំផ្លាញចោល និងលែងឮសំឡេង ព្រះសង្ឃសូត្រធម៌ ។ ព្រះសង្ឃត្រូវបានចាប់ផ្សឹក និងបញ្ជូនឲ្យទៅធ្វើស្រែចម្ការនៅតាមតំបន់ទីជនបទដាច់ស្រយាល់ ។ ដោយឡែក ព្រះវិហារក៏ត្រូវបានប្រែក្លាយជាគុក មន្ទីរឃុំឃាំង កន្លែងធ្វើទារុណកម្ម និងកន្លែងសម្លាប់ដែរ ។

ថ្ងៃទី១៧ មេសា ជាថ្ងៃដែលប្រជាជនគិតថាចប់សង្គ្រាមបានប្រែក្លាយទៅជាថ្ងៃសោកនាដកម្មដោយសារការបែកបាក់គ្រួសារបងប្អូន ឪពុក ម្តាយ និងជីដូនជីតា ។ ប្រទេសជាតិ និងប្រជាជនដែលមានភាពស៊ីវិល័យ ហ៊ឺហា ស្លៀកពាក់ឆើតឆាយ បែរទៅជាត្រូវពាក់ពណ៌ខ្មៅ ទ្រព្យសម្បត្តិត្រូវបានរឹបអូស សិទ្ធិសេរីភាព ការដើរហើរមិនត្រូវបានអនុញ្ញាត ។

ថ្ងៃ១៧ មេសា ក៏ជាថ្ងៃដែលខ្មែរក្រហមបានបែងចែកវណ្ណៈនៅក្នុងសង្គម រួមមាន កម្មាភិបាល ប្រជាជនថ្នាក់កណ្តាលថ្នាក់ក្រោម កម្មករ ប្រជាជនចាស់ និងប្រជាជនថ្មី ជាដើម ។ ប្រជាជនទាំងនេះតម្រូវឲ្យធ្វើស្រែរួម ហូបរួម រស់នៅរួមក្នុងសហករណ៍ ។ ការបែងចែងទាំងនេះ រួមជាមួយចាប់ខ្លួន ការសម្លាប់ ការធ្វើទារុណកម្ម ការហូបចុកមិនគ្រប់គ្រាន់ ជំងឺគ្មានថ្នាំព្យាបាល ការធ្វើការងារហួសកម្លាំង បានបណ្តាលឲ្យប្រជាជនប្រមាណជាងពីរលាននាក់ស្លាប់ ។

*ថ្ងៃ១៧ មេសា ជារដូវចូលឆ្នាំខ្មែរ ជួបជុំសប្បាយរីករាយ ដែលប្រជាជនចងចាំចាំមិនភ្លេច ។ បានក្លាយជាថ្ងៃទុក្ខលំបាកវេទនារបស់ប្រជាជនខ្មែរ និងជាថ្ងៃ*

**ចៅ ព្រហស្បតិ៍**





# ការចងចាំរបស់ ម៉ែន ឡឿន ពី ព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ពត៌មានស្តីអំពីរំដោះទីក្រុងភ្នំពេញបានលេចឮជាច្រើនដង នៅក្នុងតំបន់រំដោះ នៅមុនចូលឆ្នាំខ្មែរ ។ ពិធីបុណ្យប្រពៃណីចូលឆ្នាំខ្មែរបីថ្ងៃនៅក្នុងវត្តស្វាយបាក់ នៅក្នុងភូមិដូនដុំ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ព្រះសង្ឃចាស់ ក្មេង បានកំពុងប្រារព្ធធ្វើ បានឡើងពីចាំចាបនៅស្រែប្រាំងរបស់អ៊ុំម៉ែន នៅម្តុំបឹងខ្វុយ អូរត្រសេកមកចូលរួមដែរ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បុណ្យចូលឆ្នាំខ្មែរនៅក្នុងវត្តស្វាយបាក់មិនទាន់បានបញ្ចប់នៅឡើយ នៅមុនថ្ងៃត្រង់បន្តិច មានកម្មាភិបាលខ្មែរក្រហមពីរបីនាក់បានជិះម៉ូតូហុងដា សេអិល ចូលមកបានស្រែកប្រាប់ថា យើងរំដោះទីក្រុងភ្នំពេញបានហើយ កម្មាភិបាល និងសមមិត្តខ្មែរក្រហមបានស្រែកហ៊ោកញ្ជៀវអបអរជ័យជម្នះរបស់កងទ័ពរំដោះខ្មែរក្រហម ទៅលើពួកចក្រពត្តិអាមេរិក និងបរិវារ លន់ នល់ ។ ដំណឹងនោះបានឮឆាប់រហ័សពីភូមិមួយទៅភូមិមួយទៀត ។

ដំបូងឡើយ មិនបានជឿអំពីការរំដោះទីក្រុងភ្នំពេញ បានតាមដានស្តាប់វិទ្យុផ្សាយសម្លេងពីភ្នំពេញ ដែលផ្សាយរអាក់រអួលអំពីពត៌មានក្តៅៗ និងស្ថានការណ៍នៅទីក្រុងភ្នំពេញថា ប្រទេសមានសន្តិភាពឈប់ច្បាំង បន្ទាប់មកមានសម្លេងស្រែកសម្លុតថា កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជាបានទទួលជ័យជំនះដោយកម្លាំងប្រដាប់អាវុធ មិនមានការចរចារឡើយជាមួយរបបសាធារណរដ្ឋខ្មែរ បន្ទាប់មកក៏ផ្តាច់ការផ្សាយមិនដឹងថាមានរឿង



យោធាខ្មែរក្រហមចូលក្រុងភ្នំពេញ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។

អីកើតឡើង? "ខ្មែរក្រហមបានប្រកាសថា រំដោះបានខេត្ត ក្រុងទូទាំងប្រទេស" អ៊ុំៗប្រាប់ថា ខ្មែរក្រហមនឹងជម្លៀសប្រជាជនចេញពីក្រុងហើយ ។ អ៊ុំម៉ន បងប្អូនជីដូនមួយរបស់ ពីរនាក់ទៀត និង បានទទួលលិខិតអនុញ្ញាតធ្វើដំណើរទៅទទួលគ្រួសារម្ដាយមីងរបស់ នៅផ្សារផ្លូវយើងបានជិះកង់កាត់តាមភូមិខ្នុរដំបងឈូក ឡើងទៅផ្សារផ្លូវបានជួបគ្រួសាររបស់គាត់ បានកំពុងដើរជាមួយហ្វូងអ្នកជម្លៀស មានទូលស្ពាយបង្វិចបន្តិចបន្តួច និងស្បោង ថង់អង្ករខ្លះ ។ អ្នកជម្លៀសខ្លះបានដោះដូរខោអាវ ថ្នាំពេទ្យខ្លះជាមួយអង្ករស សត្វមាន់ ត្រីងៀត ត្រីឆ្អើរ របស់អ្នកមូលដ្ឋាននៅតាមផ្លូវ សម្រាប់ធ្វើអាហារហូបបានពីរបីពេលប៉ុណ្ណោះទម្រាំធ្វើដំណើរទៅដល់ទីដៅមូលដ្ឋានដែលកំណត់ដោយអង្គការ ។ មូលដ្ឋាននីមួយៗត្រូវទទួលយកអ្នកជម្លៀសទៅតាមចំនួនគ្រួសារដែលបានកំណត់ដូចជាមូលដ្ឋាននៅដើមផ្លូវកន្ទួងមកដែលបានទទួលរួចហើយ ដូច្នេះអ្នកជម្លៀសមកបន្ទាប់ទៀតក៏បញ្ជូនទៅមុខទៀត ទៅទិសខគួរ កំពង់ធំ ព្រះវិហារ និងប៉ូពាខ្លះ ។ គ្រួសារខ្លះមានស្បៀងតិចតួច ខ្លះទៀតគ្មានស្បៀងយក ដូច្នេះអ្នកគ្មានស្បៀងមើលមុខអ្នកមានហូបក្លិះៗ ឃ្លានណាស់ គួរឲ្យសង្វេគពេកក្រៃ ។ ប្រជាជនខ្លះមានប្រាក់ខ្លះដែរ តែអង្គការហាមមិនឲ្យចាយ ។ ក្រដាសប្រាក់ប្រភេទ៥០០រៀល ១០០០រៀល ត្រូវបានបោះចោលរាយប៉ាយនៅតាមដងផ្លូវ ដែលប្រាក់ទាំងនោះប្រជាជនខំសន្សំ និងប្រមូលយកមកតាមខ្លួន និងលាក់ទុកដោយសង្ឃឹមថានឹងអាចដោះស្រាយជីវភាព ប៉ុន្តែប្រែជាអសារបង់មិនមានប្រយោជន៍សោះ ។ គ្រួសារកាត់ចិនជាច្រើនគ្រួសារបានទូល និងស្ពាយបង្វិចលុយតាមខ្លួនយ៉ាងច្រើន ។ គ្រួសារទាំងនេះបានបោះបង់ចោលក្រដាសប្រាក់ទាំងនោះ និងអស់សង្ឃឹមជាខ្លាំងក្នុងជីវិតថា តើត្រូវបន្តរស់នៅយ៉ាងដូចម្ដេច? បើខ្លួនគ្មានអ្វីសោះនោះ ។ ទឹករកបានផឹក អុសរកបានដុត ប៉ុន្តែអង្ករ បន្លែ ត្រី សាច់ អំបិល ស្ករ តើទៅរកនៅឯណាបាន? ខោអាវ និងរបស់មានតម្លៃខ្លះនៅជាប់នឹងខ្លួនបានដោះដូរអស់ហើយ តើតទៅថ្ងៃមុខទៀតបានអ្វីហូប? លោកអើយ ! ។ ពេលនោះ ឈ្លប សេនាជន និងយោធាខ្មែរក្រហមបានសម្លឹងនិងតាមដានហ្វូងអ្នកជម្លៀសដែលកំពុងដើរទាំងនោះ មិនឲ្យចាកចេញពីផ្លូវឡើយ និងសាកសួរអ្នកជម្លៀសប្រុសៗ អំពីអតីតភាពការងារជាមួយរបបសាធារណរដ្ឋខ្មែរដែលមានប្រវត្តិជាអ្នករដ្ឋការបម្រើការងារថ្នាក់ទាប និងថ្នាក់ខ្ពស់ ជាដើម ។ ពលទាហាន និងនាយទាហាន ត្រូវបានប្រមូលយកទៅកន្លែងមួយឆ្ងាយពីផ្លូវជាតិ ដែលមានការឃោមកាមយ៉ាងតឹងរ៉ឹងពីយោធាខ្មែរក្រហមក្មេងៗ ។ មានក្រុមទាហាន លន់ នល់ មួយក្រុមមានគ្នា ៥ទៅ៦នាក់ ពាក់ស័ក្តិពេញស្មាអង្គុយជុំគ្នាមិនហ៊ានកម្រើក និងមានទឹកមុខភ័យបារម្ភពីសុវត្ថិភាពរបស់ខ្លួន និងការបែកបាក់គ្រួសារ ។ ក្រុមទាហាន លន់ នល់ ទាំងនេះបានសម្លឹងភ្លៀកៗមើលទៅអ្នកជម្លៀសដែលបានកំពុងធ្វើដំណើរទៅមុខ មើលទៅគួរឲ្យអាណិតទាហានទាំងនេះណាស់ ។ ពិតណាស់ យោធាខ្មែរក្រហមមិនទុកឲ្យគាត់រស់ឡើយ ។ ចំនួនអ្នកស្លាប់មានច្រើននៅតាមព្រៃគុម្ពោតឆ្ងាយពីផ្លូវជាតិបន្តិច អ្នកស្លាប់ទាំងនោះ ជារដ្ឋការជាន់ទាប ជាន់ខ្ពស់ ទាហាន ប៉េអឹម របស់របបសាធារណរដ្ឋខ្មែរ ។

**រ៉ែម៉ន ឌៀន**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.d.dccam.org*

# បុណ្យចូលឆ្នាំខ្មែរបែរជាគ្រួសារ ត្រៀមរៀបខ្លួន

ខែមេសា ជាខែដែលប្រជាជនខ្មែរជួបជុំ សប្បាយរីករាយ និងត្រៀមរៀបចំប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ។ ប៉ុន្តែផ្ទុយទៅវិញ នៅខែមេសា ឆ្នាំ១៩៧៥ សម្រាប់គ្រួសាររបស់ បែរជានាំគ្នាត្រៀមលក្ខណៈចាំរត់ភៀសខ្លួនគេចចេញពីគ្រាប់ផ្លោងរបស់ខ្មែរក្រហម ដែលផ្លោងចូលទីក្រុងភ្នំពេញទៅវិញ ។ កាលណោះ មានអាយុប្រហែល១១ឆ្នាំប៉ុណ្ណោះ មានបងប្អូនចំនួន៧នាក់ ក្នុងនោះបងស្រីពីរនាក់ ។ រស់នៅក្នុងគ្រួសារមួយដែលមានជីវភាពមធ្យម មានផ្ទះសង់នៅលើដីឡូដត៍មួយកន្លែងនៅទល់មុខផ្សារគីឡូម៉ែត្រលេខ៦ ។ ផ្ទះនោះមានទំហំ ៨,៥០ម៉ែត្រគុណ១៨ម៉ែត្រ ខាងក្រោមធ្វើពីថ្ម និងខាងលើធ្វើពីឈើប្រកហ្វីប្រូស៊ីម៉ង់ត៍ ស្ថិតនៅក្នុងសង្កាត់លេខ៦ ក្រុងភ្នំពេញ ។ នៅពេលមានគ្រាប់ផ្លោងចូលមកម្តងៗ ឪពុកម្តាយរបស់ខ្ញុំមានសេចក្តីព្រួយបារម្ភពីសុវត្ថិភាពរបស់កូនៗជាខ្លាំង ។ ក្រោយមក ឪពុករបស់ខ្ញុំក៏បានសម្រេចចិត្តបញ្ជូនកូនតូចៗចំនួនប្រាំនាក់ គឺបងស្រីរបស់ខ្ញុំពីរនាក់ និងប្អូនប្រុសរបស់ខ្ញុំពីរនាក់ទៀត មកឲ្យស្នាក់នៅបណ្តោះអាសន្ននៅផ្ទះបងប្អូននៅម្តុំផ្សារដេប៉ូ ក្បែររបងក្រសួងការពារជាតិ ដែលកាលណោះខ្ញុំមិនបានដឹងថា ទីនោះជាទីកន្លែងអ្វីទេ ។ ចំណែកឪពុកម្តាយ និងបងប្រុសពីរនាក់របស់ខ្ញុំស្នាក់នៅផ្ទះជាធម្មតា ។ កាលណោះ នៅពេលដែលខ្ញុំបានឮសំឡេងខ្ទម្ភាគចក្រចុះចតនៅក្នុងបរិវេណក្រសួងការពារជាតិ ខ្ញុំតែងរត់ទៅទីនោះ និងអើតមើលពីក្រៅរបង ។ រាល់លើក ខ្ញុំបានឃើញទាហានសែងអ្នករបួសចេញពីឧទ្ធម្ភាគចក្រដោយមានប្រឡាក់សុទ្ធតែឈាមជោគនៅនឹងឯកសណ្ឋានក្រឡេក្រឡា



ប្រជាជនជម្លៀសចេញពីក្រុងភ្នំពេញ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។

របស់ជនរងគ្រោះទាំងនោះ ដែលខ្ញុំអាចយល់ថា អ្នករបួសទាំងនោះគឺសុទ្ធតែជាទាហាន លន់ នល់ ។ បន្ទាប់មក ជនរងគ្រោះទាំងអស់ក៏ត្រូវបានបញ្ជូនតាមរថយន្តសង្គ្រោះបន្ទាន់ ទៅកាន់មន្ទីរពេទ្យ ។

ប្រហែលជាពីរសប្តាហ៍ក្រោយមក ពេលមានសភាពវឹកវរកាន់តែខ្លាំង អ្នកជិតខាងប្អូនប្រាំនាក់ បានមកនិយាយប្រាប់ម្តាយខ្ញុំថា ស្រុកកើតសង្គ្រាមបែបនេះ មិនគួរយកកូនដល់ទៅប្រាំនាក់ឲ្យទៅរស់នៅជាមួយអ្នកដទៃទេ ស្លាប់ឬរស់ គឺត្រូវនៅជុំគ្នាជាការប្រសើរ ។ ដោយយល់ថា អ្នកជិតខាងនិយាយត្រូវ ឪពុកម្តាយរបស់ខ្ញុំក៏បានមកទទួលយកពួកយើងទៅរស់នៅជួបជុំគ្នាវិញ ។ យើងបានធ្វើដំណើរទៅផ្ទះដោយជិះឡាំប្រឺតា ។ នៅតាមផ្លូវ ខ្ញុំចាប់អារម្មណ៍ថា ផ្លូវហាក់មានសភាពស្ងាត់បន្តិច មិនសូវមានអ្នកធ្វើចរាចរទៅមកឡើយ ។ យូរៗម្តង ខ្ញុំបានឮសម្លេងគ្រាប់ផ្លោងផ្ទុះនៅក្បែរផ្ទះរបស់ខ្ញុំ ។ ភាពជ្រួលច្របល់កាន់តែកើតមានខ្លាំងឡើងស្ទើរគ្រប់ទីកន្លែង ។ កងទ័ពខ្មែរក្រហមបានហ៊ុមព័ទ្ធជុំវិញទីក្រុងភ្នំពេញ ហើយការធ្វើដំណើរតាមផ្លូវគោក និងផ្លូវទឹកជួបប្រទះការលំបាកជាខ្លាំង ។ រីឯមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាសវិញ ក៏មិនប្រាកដថាមានសុវត្ថិភាពមួយរយភាគរយដែរ គឺត្រូវប្រឈមនឹងគ្រោះថ្នាក់ដោយយោធាខ្មែរក្រហមបានបាញ់ទម្លាក់យន្តហោះ ។ កត្តាទាំងអស់នេះហើយ បានធ្វើឲ្យទំនិញត្រូវឡើងថ្លៃខ្ពស់ ហេតុដូច្នេះការរស់នៅរបស់អ្នកទីក្រុងនៅក្នុងគ្រានោះ ត្រូវប្រឈមនឹងការលំបាក ។

ស្របពេលជាមួយគ្នានេះដែរ ខ្មែរក្រហមបានបន្ទុំខ្លួនចូលមកក្នុងក្រុងភ្នំពេញ ដោយបានធ្វើសកម្មភាពដាក់បំផ្ទុះគ្រាប់បែកនៅតាមរោងភាពយន្តមួយចំនួននៅទីក្រុងភ្នំពេញ ហើយនៅរោងល្ខោនគីឡូលេខ៦ នៅក្បែរផ្ទះរបស់ខ្ញុំ ក៏ខស្បរាហ៍មានហេតុការណ៍ផ្ទុះគ្រាប់បែកដែរ ។ ការបំផ្ទុះគ្រាប់បែក បណ្តាលឲ្យប្រជាជនស្លូតត្រង់មួយចំនួនត្រូវរងរបួស និងខ្លះទៀតក៏បានបាត់បង់ជីវិត ប៉ុន្តែអាជ្ញាធរមានសមត្ថកិច្ចមិនដែលចាប់អ្នកបង្កហេតុបានម្តងណាឡើយ ។ ឃ្លាំងស្តុកប្រេងសាំងនៅឫស្សីកែវ ក៏ត្រូវបានដុតឆេះជាញឹកញាប់ ស្ពានជ្រោយចង្វារត្រូវបានផ្តាច់ដោយសារការដាក់គ្រឿងផ្ទុះ ។ ម្តងឮថាគ្រាប់ផ្លោងបានធ្លាក់ចំផ្សារដើមគ ម្តងឮថាគ្រាប់ផ្លោងធ្លាក់ត្រូវផ្ទះលោកស្រី ឌី សាវេត ធ្លាក់នៅគារខ្មៅ បន្ទាប់មកឮថា មានការវាយប្រយុទ្ធគ្នានៅព្រែកហូរជាដើម ។ ទីបំផុតទីក្រុងភ្នំពេញត្រូវបានខ្មែរក្រហមចូលកាន់កាប់ទាំងស្រុងនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ។ ពេលនោះ ខ្ញុំបានឮចាស់ៗនិយាយគ្នាថា ទាហាន លន់ នល់ បានទម្លាក់អាវុធសុំចុះចាញ់ខ្មែរក្រហមដោយបានលើកទង់ជ័យសគ្រវីចុះឡើង ។ ប្រជាជនដែលរស់នៅក្នុងទីក្រុងបានចេញមកឈរតាមដងវិថីនានា មានក្មេងចាស់ប្រុសស្រីខ្លះបានដោះអាវគ្រវី ខ្លះបានលើកទង់ជ័យស ខ្លះស្រែកហោរកញ្ជៀវ លាន់ទ្រហឹងអឺងកង ខ្លះទៀតបានឡើងជិះរថយន្ត និងជិះរថក្រោះជាមួយយោធាខ្មែរក្រហមទៀតផង បញ្ជាក់ពីទឹកចិត្តអបអរសាទរ សប្បាយរីករាយ ដោយសង្ឃឹមក្នុងចិត្តថា សង្គ្រាមនឹងត្រូវបញ្ចប់ ក្តីសុខសាន្តនឹងកើតមានចំពោះពួកគាត់គ្រប់ៗគ្នា ។ ម្នាក់ៗមានចិត្តសប្បាយរីករាយជាខ្លាំងចំពោះថ្ងៃជ័យជម្នះនេះ ។ បន្ទាប់មកទៀត មានសេចក្តីប្រកាសព័ត៌មានចេញពីវិទ្យុជាតិថា "សង្គ្រាមនេះ បានទទួលជ័យជម្នះដោយការវាយប្រយុទ្ធគ្នា មិនមែនឈ្នះដោយការចរចាទេ" ។

នៅចាំបានថា ប្រហែលជាក្នុងអំឡុងថ្ងៃទី៩ ឬថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៥ នៅមុំផ្ទះរបស់ខ្ញុំមានសភាពស្ងប់ស្ងាត់ ។ ប៉ុន្តែពេលនោះប្រជាជននៅចាយលុយនៅឡើយ ។ ពេលនោះប្តីរបស់ម្តាយមីងខ្ញុំមានប្រាក់គួរសម គាត់បានចេញទៅខាងក្រៅផ្ទះ ទិញមាន់ ទា និងជ្រូកបានជាច្រើនក្បាលយកមកស្តុកទុកក្នុងផ្ទះរបស់គាត់ ។ ខ្ញុំមិនបានដឹងថា គាត់មានគំនិតយ៉ាងណាទេ ក្នុងការទិញមាន់ទា និងជ្រូកជាច្រើនក្បាលយកមកស្តុបទុកក្នុងស្ថានភាពបែបនេះនោះ ។

ថ្ងៃបន្ទាប់មក មានជ្រូកមួយក្បាល ដែលគាត់បានទិញនោះបានងាប់ដោយសារអាកាសធាតុក្តៅពេក គាត់ក៏បានហៅបងប្រុសរបស់ខ្ញុំទៅជួយធ្វើជ្រូកនោះ ។ យើងបានយកសាច់ជ្រូកនោះមកប្រឡាក់ហាលថ្ងៃខ្លះ ហើយសល់ពីប្រឡាក់យើងយកមកខបានមួយឆ្នាំងធំ ។

លុះដល់ថ្ងៃខ្មែរក្រហមបណ្តេញយើងចេញពីផ្ទះ ក្រុមគ្រួសាររបស់យើងបានសាច់ជ្រូកនោះធ្វើជាស្បៀងអាហារក្នុងការធ្វើដំណើរទៅកាន់ទិសដៅដែលខ្មែរក្រហមបានកំណត់ឲ្យយើងទៅ ។

**ឆេង ខេង**

# តើប្រជាជនកម្ពុជាទទួលបានយុត្តិធម៌អ្វីខ្លះ បន្ទាប់ពី២០ឆ្នាំនៃការស្លាប់របស់ ប៉ុល ពត?

ប៉ុល ពត បានស្លាប់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ក្នុងតំបន់ដាច់ស្រយាលក្បែរព្រំដែនកម្ពុជា-ថៃ នៃស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ប៉ុល ពត គឺជាមេដឹកនាំកំពូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ របបខ្មែរក្រហម បានធ្វើឲ្យប្រជាជនប្រមាណ២លាននាក់ស្លាប់ ដោយសារការសម្លាប់ ធ្វើការហួសកម្លាំង អត់អាហារ ឈឺគ្មានថ្នាំព្យាបាលជាដើម ។ ទោះបីជា ប៉ុល ពត បានស្លាប់ មិនមែនមានន័យថា យុត្តិធម៌ដែលប្រជាជនកម្ពុជាកំពុងទន្ទឹងរង់ចាំ បានផុតរលត់ទៅជាមួយការស្លាប់របស់ ប៉ុល ពត ឡើយ ។ ក្នុងកំឡុងពេល ២០ឆ្នាំកន្លងមកនេះ មានមេដឹកនាំខ្មែរក្រហម៦រូប (តាម៉ុក អតីតអនុលេខាទី២ នៃបក្សកុម្មុយនីស្តកម្ពុជា និងជាលេខាភូមិភាគនិរតី នៃរបបកម្ពុជាប្រជាធិបតេយ្យ កាំង ហ្គេចអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខ ស-២១ នួន ជា អតីតអនុលេខានៃបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាប្រជាជន ខៀវ សំផន អតីតប្រធានគណៈប្រធានរដ្ឋរបបកម្ពុជាប្រជាធិបតេយ្យ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបរបបកម្ពុជាប្រជាធិបតេយ្យ និង អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបប កម្ពុជាប្រជាធិបតេយ្យ) ត្រូវបានចាប់ខ្លួន ។ ក្នុងចំណោមមេដឹកនាំខ្មែរក្រហម៦រូប មាន៣រូប (ឌុច នួន ជា និង ខៀវ សំផន) ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតអំពីបទឧក្រិដ្ឋ ដែលគាត់បានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំណែកមេដឹកនាំខ្មែរក្រហម៣រូបផ្សេងទៀតរួមមាន តាម៉ុក អៀង សារី និង អៀង ធីរិទ្ធ បានស្លាប់នៅមុន និងក្នុងអំឡុងពេលសវនាការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តាមរយៈអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏បានសម្រេចផ្តល់សំណងរដ្ឋប្បវេណីជាលក្ខណៈសមូហភាពមួយចំនួន ដូចជា ការសាងសង់ស្តូបជនរងគ្រោះនៅក្នុងបរិវេណសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសាលារៀននៅទូទាំងប្រទេសជាដើម ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏បានបើកការស៊ើបអង្កេតទៅលើជនសង្ស័យចំនួន៥នាក់បន្ថែមទៀតនៅក្នុងសំណុំរឿង០០៣ និង០០៤ ។ ទោះជាយ៉ាងណា ក៏នៅមានការចោទប្រកាន់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកាត់ទោសតែមេដឹកនាំមួយចំនួនតូចមានភាពយឺតយ៉ាវក្នុងដំណើរការកាត់ក្តីពាក់ព័ន្ធនឹងអំពើពុករលួយ ថែមទាំងមានការជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាលើដំណើរការកាត់ក្តីជាដើម ។



ប៉ុល ពត

នោ មីន ភេទប្រុស ជនជាតិចាម មានទីលំនៅក្នុងស្រុក

ក្រូចឆ្មា ខេត្តត្បូងឃ្មុំ ដែលជាជនរងគ្រោះម្នាក់ធ្លាប់បានធ្វើការនៅកងចល័តក្នុងរបបខ្មែរក្រហម ។ មីន យល់ឃើញថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធផ្សេងៗទៀតដែលធ្វើការទាក់ទងនឹងរបបខ្មែរក្រហម បានខិតខំធ្វើការដើម្បីស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះ និងអ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម បើទោះជា ប៉ុល ពត ដែលជាមេដឹកនាំកំពូលនៃរបបនោះបានស្លាប់តាំងពីមុនការចាប់ផ្តើមការកាត់ទោសខ្មែរក្រហមក៏ដោយចុះ ។ មីន បន្តថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ ដោយបាននាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសស្របទៅតាមច្បាប់ និងជាគំរូមួយដល់អ្នកដឹកនាំជំនាន់ក្រោយ ។ តែទោះបីជាយ៉ាងណាសម្រាប់ មីន គ្មានយុត្តិធម៌ណាអាចកម្រិតបានថា គ្រប់គ្រាន់សម្រាប់គាត់ឡើយ ព្រោះអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម បានធ្វើឲ្យប្រជាជនជួបប្រទះការលំបាកវេទនាយ៉ាងខ្លាំង ហើយស្ទើរតែប្រែក្លាយប្រទេសមួយជាទីកន្លែងគ្មានមនុស្សរស់នៅ ។ ក្នុងនាមជាជនរងគ្រោះ មីន មិនទាមទារអ្វីឡើយសម្រាប់បំពេញភាពយុត្តិធម៌របស់គាត់ ហើយគាត់ពិតជាពេញចិត្តនឹងសំណងជាសមូហភាពដែលតុលាការបានសម្រេចដូចជាកន្លែងគោរពវិញ្ញាណក្ខន្ធសម្រាប់ជនរងគ្រោះ ទិវានៃការចងចាំដែលជាអនុស្សាវរីយ៍ និងជាភស្តុតាងមួយសម្រាប់ក្មេងជំនាន់ក្រោយ ។

ទន្ទឹមនឹងនេះ ហ៊ឹម ហ៊ុយ ភេទប្រុស ជាអតីតកម្មាភិបាលខ្មែរក្រហម មានតួនាទីជាអនុប្រធានកងការពារអ្នកទោសនៅមន្ទីរស-២១(គុកទួលស្លែង) បានរៀបរាប់ថា ទោះបីជាគាត់ជាអតីតកម្មាភិបាលខ្មែរក្រហមក៏គាត់ត្រូវការយុត្តិធម៌ដែរ ។ គាត់ពិតជាទទួលបានយុត្តិធម៌មួយកម្រិត នៅពេលដែល កាំង ហ្គេកអ៊ាវ ហៅឌុច ត្រូវបានតុលាការនាំយកមកកាត់ទោសដាក់ពន្ធនាគារអស់មួយជីវិត ព្រោះ ឌុច នេះហើយជាអ្នកបញ្ជាឲ្យកងការពារយកអ្នកទោសនៅក្នុងគុកទួលស្លែងទៅសម្លាប់ មិនមែនកងការពារធ្វើដោយចិត្តឯង



ប៉ុល ពត ស្លាប់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ នៅលើភ្នំដងរែក ។

ទេ ។ ប្រសិនបើគាត់មិនធ្វើតាមបញ្ជាគឺគាត់នឹងត្រូវសម្លាប់ដូចអ្នកទោសដែរ ។ ហ៊ុយ ជំរុញឲ្យមានការកាត់ទោសលើសំណុំរឿង ០០៣ និងសំណុំរឿង០០៤ បន្តទៀត ដើម្បីជាគំរូដ៏ល្អមួយដល់ក្មេងជំនាន់ក្រោយ និងទុកជាមេរៀនប្រវត្តិសាស្ត្រមួយសម្រាប់ប្រទេសកម្ពុជា ក៏ដូចជាគំរូដល់ប្រទេសដ៏ទៃទៀត ។ ការស្វែងរកយុត្តិធម៌ ពិតជាមានសារសំខាន់ណាស់សម្រាប់ជីវិតរស់នៅសព្វថ្ងៃរបស់ជនរងគ្រោះ ទោះជា ប៉ុល ពត និងមេដឹកនាំផ្សេងទៀតបានស្លាប់ក៏ដោយ ក៏ត្រូវកាត់ទោសមេដឹកនាំដែលនៅរស់ផ្សេងទៀតដែរ ព្រោះគ្មាននរណាម្នាក់អាចជៀសផុតពីការរស់នៅដោយការគេចវេះពីអតីតកាលដែលកើតមានចំពោះខ្លួនបានឡើយ ។

ចំពោះ ចាន់ ឡេត ភេទស្រី និស្សិតឆ្នាំទី១ នៃសាកលវិទ្យាល័យអន្តរជាតិ មានស្រុកកំណើតនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ជាតំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហមប្រាប់ថាផ្ទះរបស់គាត់មានចម្ងាយប្រហែល៣០គីឡូម៉ែត្រពីផ្នូររបស់ ប៉ុល ពត ។ ជារឿយៗ ឡេត បានទៅទស្សនាផ្នូររបស់ ប៉ុល ពត ដោយសារតែបានឮពីរឿងរ៉ាវ និងបញ្ហាផ្សេងៗក្រោមការដឹកនាំរបស់ ប៉ុល ពត ក្នុងរបបខ្មែរក្រហម ពីឪពុកម្តាយនិងអ្នកជិតខាងរបស់ខ្លួន ។

ឡេត និយាយថា ការកាត់ទោសមេដឹកនាំខ្មែរក្រហម ពិតជាគ្រប់គ្រាន់ក្នុងការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ព្រោះប្រជាជនខ្មែរជឿទៅលើបុណ្យ និងបាប ហើយជនរងគ្រោះភាគច្រើនចង់ឃើញអ្នកដែលធ្វើខុសទទួលបានផលអាក្រក់តបស្នងវិញ ដូចដែលមេដឹកនាំខ្មែរក្រហមត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារអស់មួយជីវិត ។ ឡេត យល់ឃើញថា ការជំរុញឲ្យមានការចាប់ខ្លួនមេដឹកនាំខ្មែរក្រហមជាបន្តបន្ទាប់អាចធ្វើឲ្យកម្មាភិបាលខ្មែរក្រហមនិងសាច់ញាតិរបស់កម្មាភិបាលខ្មែរក្រហមមួយចំនួនមិនពេញចិត្តដែលអាចនាំមកនូវបញ្ហាផ្សេងៗទៅថ្ងៃអនាគត ។ មិនតែប៉ុណ្ណោះ ឡេត បន្ថែមថា យុត្តិធម៌ និងការផ្សះផ្សា មិនមែនពឹងផ្អែកទៅលើការកាត់ទោសទាំងស្រុងទេ តែតម្រូវការជាក់ស្តែងគឺជាការអភិវឌ្ឍន៍ប្រទេសឲ្យមានការរីកចម្រើន ដូចជាការអភិវឌ្ឍន៍ស្រុកអន្លង់វែងសព្វថ្ងៃនេះជាដើម ។ ទោះបីជាស្រុកអន្លង់វែង ជាកន្លែងដែលធ្លាប់តែមានការរើសអើងគ្នារវាងកម្មាភិបាលខ្មែរក្រហម និងប្រជាជនថ្មីក៏ដោយ តែសព្វថ្ងៃនេះ ប្រជាជនភាគច្រើនបានរស់នៅជាមួយគ្នាយ៉ាងសុខសាន្តដោយសារតែស្រុកអន្លង់វែងមានការអភិវឌ្ឍន៍ ទាក់ទាញមនុស្សជាច្រើនទៅរស់នៅ និងចេះយោគយល់គ្នាទៅវិញទៅមក ។

លើសពីនេះ មី បូរី ភេទស្រី ជានិស្សិតឆ្នាំទី២ ផ្នែកប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានស្រុកកំណើតនៅខេត្តកំពង់ស្ពឺ មានយោបល់ថា តុលាការបានផ្តល់ភាពយុត្តិធម៌យ៉ាងពិតប្រាកដទាំងសម្រាប់ពេលបច្ចុប្បន្ន និងអនាគត ព្រោះតុលាការបានជួយព្យាបាលរបួសផ្លូវចិត្ត ជាគំរូមួយសម្រាប់ប្រទេសនីតិរដ្ឋ និងបានដាក់ឈ្មោះមេដឹកនាំខ្មែរក្រហម ជាឧក្រិដ្ឋជនក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ ទោះជា ប៉ុល ពត បានស្លាប់មុនការកាត់ទោសក៏ដោយ ក៏ ប៉ុល ពត នៅតែជាប់ឈ្មោះជាមេដឹកនាំអាក្រក់នៅក្នុងប្រវត្តិសាស្ត្រដែរ ។ បូរី បានបន្ថែមថា មិនចង់ឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមបន្ថែមទៀតទេ ព្រោះការនាំមេដឹកនាំខ្មែរក្រហមមកកាត់ទោសកាន់តែច្រើន អាចបណ្តាលឲ្យមានការបែកបាក់រវាងប្រជាជន និងអតីតកម្មាភិបាលខ្មែរក្រហមកាន់តែច្រើនទៀត ។

ចំពោះ បូរី ការសម្ភាសន៍ជនរងគ្រោះ និងការអប់រំតាមរយៈសាសនា គឺជាចំណែកមួយក្នុងការជួយរំលែកការឈឺចាប់ក្នុងចិត្តរបស់ជនរងគ្រោះ ។ នៅក្នុងថ្ងៃអនាគត បូរី មាន បំណងចង់ក្លាយជាអ្នកសិក្សាស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រ ព្រោះ បូរី គិតថាការសិក្សាអំពីប្រវត្តិសាស្ត្រសព្វថ្ងៃនៅមានកម្រិតនៅឡើយ ។

ចំណែកឯនិស្សិតឆ្នាំទី២ ផ្នែកប្រវត្តិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឈ្មោះ រី ក្រវ៉ាន់ ភេទស្រី មានស្រុកកំណើតនៅខេត្តកណ្តាល យល់ឃើញថាការកាត់ទោសមេដឹកខ្មែរក្រហមនៅក្នុងតុលាការគឺផ្តល់យុត្តិធម៌បានតែមួយផ្នែកទេ ព្រោះប្រជាជនខ្មែរប្រមាណ២លាននាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម គឺមានលក្ខណៈធំធេងណាស់ ។ យុត្តិធម៌ គឺមិនអាចពឹងផ្អែកតែលើប្រព័ន្ធតុលាការតែម្យ៉ាងឡើយ តែការអប់រំក្មេងៗជំនាន់ក្រោយឲ្យយល់ដឹងពីរបបខ្មែរក្រហមឲ្យកាន់តែច្បាស់ក៏ជាផ្នែកមួយយ៉ាងសំខាន់បំផុតក្នុងការចូលរួមរកយុត្តិធម៌ទៅថ្ងៃអនាគតដែរ ។

**អ៊ុន សុជាទី**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិន សុធីតា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthsothida.s@dccam.org ។



















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ ៖ ០០ ព្រឹក*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ស៊ាង ចិន្តា ទូរសព្ទលេខ ៖ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល ៖ truthchenda.s@dccam.org*

# រដូវចូលឆ្នាំខ្មែរជាខែដែល យន ចាំមិនភ្លេច

ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃមហាជោគជ័យរបស់កងទ័ពរំដោះខ្មែរក្រហមលើរដ្ឋាភិបាល លន់ នល់ ទាំងស្រុង ។ ប៉ុន្តែ សម្រាប់ប្រជាជនកម្ពុជា ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃចាប់ផ្តើមនៃការព្រាត់ប្រាស់ក្រុមគ្រួសារ មនុស្សជាទីស្រឡាញ់ចាកឆ្ងាយពីផ្ទះសម្បែងទៅរស់នៅក្នុងពិភពមួយទៀតដែលពោរពេញដោយក្តីវេទនា ។

វត្តមានរបស់កងទ័ពរំដោះមកដល់ទីក្រុងភ្នំពេញ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បានទទួលការអបអរសាទរយ៉ាងច្រើនកុះករពីសំណាក់អ្នករស់នៅទីក្រុង ។ ប្រជាជនម្នាក់ៗ បានយកក្រណាត់ពណ៌សមកចងខាងមុខផ្ទះ ជាសញ្ញានៃសន្តិភាពហើយអ្នកខ្លះទៀតបាននាំគ្នាទៅឈរអមសងខាងផ្លូវ និងស្រែកជ័យឃោសស្វាគមន៍កងទ័ពខ្មែរក្រហម ។ ប្រជាជនគ្រប់រូបបានគិតក្នុងចិត្តថា សង្គ្រាមនឹងត្រូវបានបញ្ចប់ ហើយក៏សង្ឃឹមថានឹងអាចរស់នៅក្នុងសុខសន្តិភាពជាក់ជាមិនខាន ។ ទន្ទឹមនឹងការស្វាគមន៍នេះ មានការប្រកាសព័ត៌មានមួយបានបន្លឺឡើងតាមរយៈវិទ្យុជាតិមកថា “ជ័យជម្នះនេះគឺទទួលបានដោយចុងអាវុធមិនមែនបានមកដោយការចរចាទេ” ។

មិនយូរប៉ុន្មានសំឡេងសើចសប្បាយបានប្រែក្លាយទៅជាសំឡេងហៅរកប្រពន្ធ កូន ឪពុកម្តាយដែលពោរពេញទៅដោយភាពតក់ស្លុត ភ័យខ្លាច បន្ទាប់ពីពួកយោធាខ្មែរក្រហមគំរាម និងបញ្ជាឲ្យរៀបចំអីវ៉ាន់ចាកចេញពីផ្ទះ ។ គ្រប់គ្នាស្រឡាំងកាំងនឹងបញ្ជានេះ ។ យោធាខ្មែរក្រហមបានប្រកាសទៀតថា អ្នកទាំងអស់គ្នាមិនចាំបាច់យករបស់របរទៅជាមួយច្រើនទេ ព្រោះការចាកចេញនេះមានរយៈពេលតែបីថ្ងៃប៉ុណ្ណោះ នឹងបានត្រឡប់មកវិញហើយ ។ គ្មាននរណាម្នាក់បានដឹងថា បីថ្ងៃដែលខ្មែរក្រហមបាននិយាយក្លាយជាបីឆ្នាំនោះទេ ។

បើយោងតាមឯកសារ D00៧១០ បានឲ្យដឹងថា ខ្មែរក្រហមមានផែនការរួចជាស្រេចក្នុងការវាយរំដោះទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញនៅចំពេលថ្ងៃបុណ្យចូលឆ្នាំខ្មែរ ។ “ខ្មែរក្រហមបានយកផ្សារធំថ្មីធ្វើជាចំណុចកណ្តាលដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទៅកាន់បណ្តាខេត្ត



ហង់ យន នៅវិទ្យាស្ថានជាតិអប់រំ ។

នានា តាមមុខសញ្ញារបស់ភូមិភាគនីមួយៗ ដូចជា ភ្នំពេញភាគខាងកើត និងភាគខាងត្បូង ៖ ប្រជាជនភាគនេះត្រូវចេញទៅភូមិភាគបូព៌ាទិស រួមមាន ខេត្តព្រៃវែង និងខេត្តស្វាយរៀង ។ រីឯភ្នំពេញភាគខាងកើត និងភាគខាងជើង ៖ ប្រជាជនភាគនេះត្រូវចេញទៅភូមិភាគឧត្តរទិស និងត្រូវឆ្ពោះទៅខេត្តកំពង់ចាម កំពង់ធំ និងខេត្តសៀមរាប ។ ចំពោះភ្នំពេញភាគខាងលិច និងភាគខាងជើង ៖ ប្រជាជនភាគនេះត្រូវចេញទៅភូមិភាគពាយ័ព្យទិស រួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបង ។ សម្រាប់ភ្នំពេញ ភាគខាងលិច និងភាគខាងត្បូង៖ ប្រជាជនភាគនេះត្រូវចេញទៅភូមិភាគបស្ចិមទិស ឆ្ពោះទៅខេត្តកំពង់ឆ្នាំង និងកំពង់ស្ពឺ ។ រីឯភ្នំពេញភាគខាងត្បូង និងភាគខាងលិច៖ ប្រជាជនភាគនេះត្រូវចេញទៅភូមិភាគនិរតីទិស ឆ្ពោះទៅខេត្តកំពត និងតាកែវ ។ ជាចុងក្រោយ ភ្នំពេញភាគខាងត្បូងភាគ និងខាងកើត ប្រជាជនភាគនេះត្រូវចេញទៅភូមិភាគពិសេស ឆ្ពោះទៅខេត្តតាកែវតាមផ្លូវជាតិលេខ២ ។

អំឡុងពេលជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ ប្រជាជនម្នាក់ៗ បានចាកចេញដោយភាពភ័យខ្លាច ហើយក៏ជឿជាក់ចំពោះការបោកបញ្ឆោតរបស់ខ្មែរក្រហមដែលសន្យាថា នឹងឲ្យវិលត្រឡប់មកផ្ទះវិញក្នុងរយៈពេលបីថ្ងៃក្រោយ ។ ជាក់ស្តែង ហង់ យន សព្វថ្ងៃ អាយុ៦២ឆ្នាំ ជាបុគ្គលិកនៅវិទ្យាស្ថានជាតិអប់រំ បានរម្លឹកថា នៅថ្ងៃ១៧ មេសា ១៩៧៥ គាត់បានឮខ្មែរក្រហមប្រកាសប្រាប់ថា «សូមបងប្អូនចេញពីទីក្រុងភ្នំពេញត្រឹមរយៈពេលបីថ្ងៃ ហើយយើងនឹងឲ្យវិលត្រឡប់មកភ្នំពេញវិញ» ។ យន និងក្រុមគ្រួសារបានចាកចេញពីផ្ទះតាមការបញ្ជារបស់ខ្មែរក្រហម ដោយធ្វើដំណើរទៅស្រុកកំណើតនៅខេត្តកណ្តាល ។ យន និងគ្រួសារធ្វើដំណើរដោយមិនស្រូតខ្លាំងនោះទេ ព្រោះនឹកគិតថា ខ្មែរក្រហមឲ្យចេញតែបីថ្ងៃប៉ុណ្ណោះ ។ គាត់ធ្វើដំណើរពីមួយថ្ងៃទៅមួយថ្ងៃដោយមិនមានឮការប្រកាសហៅឲ្យប្រជាជនចូលក្នុងក្រុងភ្នំពេញវិញឡើយ ។ គាត់ក៏ដូចជាអ្នកជម្លៀសដទៃទៀត ចាប់ផ្តើមអស់សង្ឃឹម និងភ័យខ្លាច ។ អ្វីដែលសំខាន់នោះ គឺស្បៀងហូបចុក ព្រោះគាត់មិនបានយកមកច្រើននោះទេ ។ មួយសប្តាហ៍ក្រោយមកគាត់ និងគ្រួសារបានធ្វើដំណើរមកដល់ស្រុកកំណើត ។ យនស្នាក់នៅទីនោះអស់រយៈពេលជិតមួយសប្តាហ៍ ទើបខ្មែរក្រហមជម្លៀសគាត់បន្តទៅកន្លែងផ្សេងទៀត ។ ខ្មែរក្រហមបានយកឡានកាមីញ៉ុងបិទដំបូលមកដឹក យន និងប្រជាជនជម្លៀសដទៃទៀតបន្តដំណើរឆ្ពោះទៅខេត្តសៀមរាប ។ ពេលនោះ ខ្មែរក្រហមបានប្រកាសប្រាប់ប្រជាជនជម្លៀសម្តងទៀតថា «បងប្អូនទាំងអស់មិនចាំបាច់ព្រួយបារម្ភអ្វីទេ ព្រោះពេលទៅដល់ទីនោះ យើងទាំងអស់គ្នាមិនខ្វះអ្វីហូបឡើយ ដោយសារតំបន់នោះ សម្បូរស្រូវអង្ករសម្រាប់យើងទាំងអស់គ្នា» ។ ប៉ុន្តែ សម្រាប់ យន ផ្ទាល់មិនជឿនូវពាក្យបោកបញ្ឆោតរបស់ខ្មែរក្រហមទាំងនេះទៀតទេ ។ យន បានឃ្លាតឆ្ងាយពីស្រុកកំណើតដោយពុំមានអ្វីជាប់នឹងខ្លួន គឺមានត្រឹមតែខោអាវមួយកំផ្លេរប៉ុណ្ណោះ ។ យនតែងគិតក្នុងចិត្តថា គាត់មិនមានសេចក្តីរំពឹងរួចផុតជីវិតមកជួបជុំបងប្អូនវិញឡើយ ។ ប៉ុន្មានថ្ងៃក្រោយមក យន បានទៅដល់ខេត្តសៀមរាប ហើយអង្គការបានចាត់តាំង យន ឲ្យចូលក្នុងកងចល័ត ដោយមាននាទីលើកទំនប់ និងភ្ជឺស្រែ ។ យន ធ្វើការក្នុងកងចល័តរហូតដល់កងទ័ពវៀតណាមវាយចូលទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៩ ។ ពេលនោះ យន បានត្រឡប់មកស្រុកកំណើតវិញ ដោយគាត់ធ្វើដំណើរថ្មើរជើងអស់រយៈពេលជាច្រើនថ្ងៃ ។ បន្ទាប់ពី យន ទៅដល់ស្រុកកំណើត ផ្ទះរបស់គាត់ត្រូវបានអ្នកផ្សេងរស់នៅ រីឯសាច់ញាតិបងប្អូន គឺគាត់បានជួបតែម្តាយ និងបងស្រីម្នាក់ប៉ុណ្ណោះ ។ យន បានរៀបរាប់ថា នៅខែមេសា ឈានមកដល់ គាត់តែងតែនឹករឮកដល់សាច់ញាតិបងប្អូនដែលបានស្លាប់ក្នុងអំឡុងពេលខ្មែរក្រហមជម្លៀសទៅតំបន់ផ្សេងៗ ។ យន តែងតែមានអារម្មណ៍សោកស្តាយយ៉ាងខ្លាំងព្រោះគាត់បានបាត់បង់សាច់ញាតិបងប្អូនអស់ជាច្រើននាក់ ។

បច្ចុប្បន្ននេះ សម្រាប់ យន ខែមេសា ដែលជារដូវចូលឆ្នាំប្រពៃណីជាតិ គាត់មានចិត្តសប្បាយរីករាយណាស់ ដោយបានសម្រាកពីការងារមកជួបជុំបងប្អូនញាតិមិត្តជិតឆ្ងាយប្រកបដោយក្តីរីករាយ ។ ប៉ុន្តែ គាត់ក៏មិនអាចបំភ្លេចបានដែរនូវទិដ្ឋភាពដែលគាត់បានឃើញ និងបានជួបប្រទះនាពេលដែលខ្មែរក្រហមបានជម្លៀសគ្រួសារគាត់ ក៏ដូចជាប្រជាជនដទៃទៀត ក្នុងអំឡុងរដូវចូលឆ្នាំខ្មែរ បើទោះបីជារឿងរ៉ាវដ៏ខ្លោចផ្សានេះបានកន្លងទៅជាង៤០ឆ្នាំហើយក៏ដោយ ។ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នៅតែដក់ជាប់ក្នុងចិត្តគាត់ជានិច្ច ។ **ហូ ថុនា**

# ថា សែន អតីតកម្មាភិបាលខ្មែរក្រហម ជនជាតិចារ៉ាយ រស់នៅស្រុកត្រពាំងប្រាសាទ

## ប្រវត្តិគ្រួសារ

ញ៉ាង សែន ហៅ បោះ មានឈ្មោះចូលបដិវត្តន៍ថា ជា សែន ។ សែន ជាជនជាតិចារ៉ាយ ភេទប្រុស អាយុ៥៧ឆ្នាំ (ក្នុងឆ្នាំ ២០១៣) មានទីកន្លែងកំណើតនៅភូមិកែត ឃុំញាង ស្រុកអណ្ដូងមាស ខេត្តរតនគិរី ។ សែន មានឪពុកឈ្មោះ ញ៉ាង ធ្លាប់ធ្វើទាហានរបបសង្គមរាស្ត្រនិយម និងម្ដាយឈ្មោះ ដើស ស្លាប់នៅឆ្នាំ១៩៨១ ។ សែន មានបងប្អូនបង្កើតចំនួន៥នាក់ក្នុងនោះ ប្រុស ៤នាក់និងស្រី១នាក់ ។ សែន ជាកូនទីបីក្នុងចំណោមបងប្អូនបង្កើត ៥នាក់ ។

បងប្អូនរបស់ សែន បានរស់នៅទីកន្លែងផ្សេងគ្នា បងទី១ ឈ្មោះ ដៀង នៅស្រុកម៉ាឡៃ បងទី២ឈ្មោះ ដេញ នៅភូមិកែត ខេត្តរតនគិរី ប្អូនបន្ទាប់ឈ្មោះ ឈាង រស់នៅប្រទេសវៀតណាម និងប្អូនស្រីពៅរស់នៅក្នុងភូមិតាឡាវ ខេត្តរតនគិរី ។ សែន មានប្រពន្ធឈ្មោះ ប្រាក់ សុភី ។ សែន មានកូនចំនួន៥នាក់សុទ្ធតែស្រី ហើយកូនរបស់ សែន បានរៀបគ្រួសារចំនួនពីរនាក់ និងបីនាក់ទៀតស្ថិតនៅក្នុងបន្ទុក ។ សព្វថ្ងៃ សែន រស់នៅក្នុងភូមិសែនសុខ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ ។

## ប្រវត្តិរៀនសូត្រ និងចូលបដិវត្តន៍ខ្មែរក្រហម

កាលពីនៅក្មេង សែន មិនបានទៅសាលារៀនសូត្រទេ ។ នៅឆ្នាំ១៩៦៨ ពេល សែន មានអាយុ១៥ឆ្នាំ សែន បានចូលបដិវត្តន៍ជាមួយឈ្មោះ ឡៅ ដែលជាគណៈភូមិភាគឦសាន ដឹកនាំក្នុងព្រៃនៅជិតភូមិកែត ។ សែន បានធ្វើជានីរសាររបស់ឈ្មោះ ឡៅ បានកន្លះឆ្នាំ សែនក៏ត្រូវបានបញ្ជូនឲ្យទៅមន្ទីរនីរសារ ឬហៅថា ន-៥ ដែលមានឈ្មោះ ឆេន ជាប្រធាន ។ កាលនោះមន្ទីរ១០០ ដែលជាមន្ទីររបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាស្ថិតនៅក្នុងឃុំម-៤ ស្រុកវើនសៃ ក្បែរព្រំប្រទល់ជាមួយស្រុកអណ្ដូងមាស ។

នៅឆ្នាំ១៩៧២ សែន បានផ្លាស់មកនៅ ស-១ នៅភូមិគង់ឡែ កន្លែងសេដ្ឋកិច្ចតំបន់របស់ភូមិភាគឦសានជាមួយឈ្មោះ ហុង ។ នៅឆ្នាំ១៩៧៣ សែន បានទៅខាងមន្ទីរគមនាគមន៍របស់ភូមិភាគឦសានដោយធ្វើការដឹកជញ្ជូនទំនិញតាមទូកមកពីស្ទឹងត្រែង ដែលកាលនោះមានការទម្លាក់គ្រាប់បែកយ៉ាងខ្លាំង ។

## ការងារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ១៩៧៥-១៩៧៩

នៅឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមដណ្ដើមបានទីក្រុងភ្នំពេញ សែន បានមកភ្នំពេញដោយគ្រប់គ្រងមន្ទីររបស់ភូមិភាគឦសានប្រចាំនៅទីក្រុងភ្នំពេញ ។ ខ្មែរក្រហមបានឲ្យ សែនដឹកជ័យភ័ណ្ឌចែកតាមខេត្តនៅភូមិភាគឦសានដែលមានឈ្មោះ ទុំ ជាប្រធាន ។

សែន នៅក្នុងកងតូចមានសមាជិក៣០នាក់ ។ ដោយសារ ទុំ មិននៅជាប់ជាមួយការងារ ដូច្នេះ សែន ជាអ្នកចាត់ចែងជំនួសដឹកឥវ៉ាន់ទៅតាមតំបន់នីមួយៗរបស់ភូមិភាគឦសាន ។ ក្រោយពី សែន បានបម្រើការងារនៅភ្នំពេញរយៈពេលកន្លះឆ្នាំមក ខ្មែរក្រហមបានបញ្ជូនគាត់ឲ្យត្រឡប់ទៅខេត្តក្រចេះវិញ ។ មកនៅខេត្តក្រចេះបានមួយខែ សែន ត្រូវបានចាត់តាំងឲ្យទៅធ្វើពេទ្យ ។ បន្ទាប់មក ខ្មែរក្រហមបានផ្លាស់ សែន ឲ្យទៅរតនគិរីដោយធ្វើការនៅក្រុងបានលុង ។

នៅចុងឆ្នាំ១៩៧៦ សែន ផ្លាស់មកធ្វើការនៅចម្ការកៅស៊ូ ។ នៅឆ្នាំ១៩៧៧ សែន បានរៀបការប្រពន្ធដែលជាអ្នកភូមិខ្វាវ ខេត្តស្ទឹងត្រែង ។ នៅឆ្នាំ១៩៧៨ សែន មានឋានៈជាអ្នកគ្រប់គ្រងចម្ការកៅស៊ូមួយភូមិ និងចម្ការកប្បាសទាំងអស់ ។ សែន បានក្ដាប់ប្រជាជនប្រមាណជិត១.០០០នាក់ ដែលធ្វើការងារនៅចម្ការកៅស៊ូ និងចម្ការកប្បាស ។ គណៈភូមិភាគឦសានមានឈ្មោះ យ៉ា និង ឈ្មោះ វង់ ហើយមាន តាឡៅ គ្រប់គ្រងតំបន់១០១ និង តាផាត់

គ្រប់គ្រងតំបន់១០៧ ។ នៅពេលប្រជុំ សែន បានទៅប្រជុំជាមួយ តាទុំ នៅមន្ទីរប្រជុំរួម ។ ការរត់គេចខ្លួន និងការវាយទប់ទល់ជាមួយ កងទ័ពវៀតណាមនៅឆ្នាំ១៩៧៩ ពេលដែលកំពុងរត់គេចពីកងទ័ព វៀតណាម កូនរបស់ សែន បានស្លាប់ ហើយ សែន និងប្រពន្ធបាន បែកបាក់គ្នា ។ ប្រពន្ធរបស់ សែន បានរៀបគ្រួសារថ្មីទៀត ។ នៅ ឆ្នាំ១៩៧៩ ដដែល សែន បានធ្វើកងទ័ពខ្មែរក្រហម ។ សែន និង កងទ័ពខ្មែរក្រហមប្រមាណជា៣០០នាក់ទៀត បានទប់ទល់ជាមួយ កងទ័ពវៀតណាមនៅម្តុំទន្លេស្រែពក អស់រយៈពេល១ថ្ងៃ ១យប់ ។ នៅខណៈពេលដែលកងទ័ពវៀតណាមវាយឈ្នះ សែន មិនបានដឹង ថាកងទ័ពខ្មែរក្រហមផ្សេងទៀតបានរត់ចោលជួរ ហើយកងទ័ព វៀតណាមបានចូលដល់ទេ ។ សែន បានឆ្លងទៅឡាវនៅដុំក្រឡ ដែលមានចម្ងាយប្រមាណជា៣០គីឡូម៉ែត្រ ពីព្រំដែនជាមួយកង ទ័ពប្រមាណ៣០នាក់ទៀត ដោយជិះទូកឆ្លងកាត់ទន្លេមេគង្គ ។ បន្ទាប់ពីឆ្លងចូលមកព្រំប្រទល់ប្រទេសឡាវ សែន បានចូលវរ សេនាធំ១០២ មានឈ្មោះ តាឡេ ជាប្រធាន និងកងពលលេខ ៨០១ មានឈ្មោះ តា០៥ ជាប្រធាន និងអនុប្រធានឈ្មោះ តាវ៉ែន និង ធិន ។ សែន បានទៅដុំក្រឡកន្លះឆ្នាំ និងបានដើរធ្វើ នយោបាយបញ្ចុះបញ្ចូលប្រជាជនឲ្យចូលជាមួយខ្មែរក្រហម ។

## ជីវិតនៅលើភ្នំដងរែក និងការបន្តធ្វើសង្គ្រាម

នៅឆ្នាំ១៩៨១ សែន បានទៅដល់ព្រំប្រទល់ប្រទេសថៃ-ឡាវ-កម្ពុជា ម្តុំមុំបីនៅលើភ្នំដងរែក ឬហៅថាច្រក១០០១ ដោយ មាន សុន សេន ជាអ្នកគ្រប់គ្រង ។ ចំណែកច្រក១០០២ និង ១០០៣ មាន តាម៉ុក ជាអ្នកគ្រប់គ្រង ។ សែន នៅច្រក១០០១ បានកន្លះឆ្នាំ ក៏បានចូលជាមួយកងពល៦១២ ដោយមានឈ្មោះ តាហឿន ជាប្រធានកងពល និង តាឈាន ជាអនុប្រធាន ។ បន្ទាប់ មក សែន បានផ្លាស់មកនៅពើយព្រេចនៅភាគខាងកើតនៃប្រាសាទ ព្រះវិហារវិញ ។ នៅពើយព្រេច សែន មិនមានតួនាទីអ្វីធំដុំទេ គឺសែនត្រូវបានចាត់តាំងឲ្យនៅមើលការខុសត្រូវនៅក្នុងមន្ទីរអនុ សេនាធំ ក្រៅពី សែន កងទ័ពផ្សេងៗទៀតត្រូវចាត់តាំងឲ្យចុះទៅ ធ្វើការនៅស្រុកជាំក្សាន្ត ។ ក្រោយមក សែន បានទៅនៅជួរដាន មានទីតាំងនៅភាគខាងលិចនៃពើយព្រេចជិតបង្គោលឡាក់លេខ ប្រាំបី ហើយ សែន ស្ថិតនៅក្នុងកងកាំភ្លើងធំជាមួយ តាអ៊ឹម ។

ឆ្នាំ១៩៨៦ សែន បានផ្លាស់ទៅធ្វើការនៅខេត្តកំពង់ចាម វិញ ព្រោះកម្លាំងខ្មែរក្រហមត្រូវបានបែងចែកតាមវរសេនាធំ ហើយវរសេនាធំនីមួយៗត្រូវចុះទៅធ្វើការនៅទីនោះ ។ ពេលទៅ កំពង់ចាម សែន ស្ថិតនៅក្នុងវរសេនាធំ របស់ តាស៊ិន ដែលកាន់ ខាងនយោបាយចំណែក សែន ខាងយោធា ។ នៅខណៈពេលនោះ សែន ទទួលទិសវាយនៅស្រុកត្បូងឃ្មុំ តែមិនសូវប្រើកម្លាំងទេ ។ ភាគច្រើន សែន ទៅធ្វើនយោបាយជាមួយប្រជាជន លើកលែង តែករណីទាល់ច្រកទើបប្រើកម្លាំង ។

## រៀបការប្រពន្ធថ្មី និងការរស់នៅក្នុងស្រុកត្រពាំងប្រាសាទ

នៅឆ្នាំ១៩៩១ សែន បានរៀបការប្រពន្ធទី២ ឈ្មោះ ប្រាក់ សុភី ។ សែន រៀបការនៅក្នុងព្រៃនៅក្នុងភូមិយាង ស្រុក ក្រូចឆ្មារ ខេត្តកំពង់ចាម ។ សែន នៅធ្វើចម្ការនៅក្នុងព្រៃផ្សុយ ស្ថិត ក្នុងភូមិយាង ។ ក្រោយមកនៅឆ្នាំ១៩៩៣ សែន បានត្រឡប់ទៅ ភ្នំដងរែកវិញ ហើយបានផ្លាស់មកនៅក្នុងវរសេនាធំឯករាជ្យជា មួយឈ្មោះ តាកែវ ។ នៅពេលនោះ សែន មិនបាននាំប្រពន្ធកូន មកជាមួយទេ ព្រោះបារម្ភពីសុវត្ថិភាព ។ សែន មកដល់ត្រពាំង ប្រាសាទដំបូង រស់នៅម្តុំអូរស្វាយ ដែលមានឈ្មោះ វ៉ា ជាអ្នក ដឹកនាំ ។

សែន រស់នៅត្រពាំងប្រាសាទបានកន្លះឆ្នាំ គាត់ក៏បានទៅ យកប្រពន្ធកូនមករស់នៅជាមួយ ។ ក្រោយពី សែន ដាច់ខ្លួនចុះ ចូលជាមួយរាជរដ្ឋាភិបាលនៅឆ្នាំ១៩៩៨ គាត់ក៏បានលាឈប់ ពីកងទ័ព ។ បងប្រុសរបស់ សែន ដែលរស់នៅខេត្តរតនគិរី បាន មកលេង សែន នៅត្រពាំងប្រាសាទ និងបបួល សែនឲ្យត្រឡប់ទៅ រស់នៅស្រុកកំណើតនៅភូមិកែតវិញតែ សែន មិនព្រមទៅព្រោះ សែន មិនមានដីសម្រាប់ធ្វើស្រែចម្ការ ។ ម្យ៉ាងវិញទៀតដោយ សារតែភូមិកំណើតរបស់ សែន មានព្រំទល់កៀកជាមួយប្រទេស វៀតណាមពេក ។

ទោះបីសែនជាជនជាតិភាគតិចចារ៉ាយក៏ដោយ ក៏សែនបាន សម្របខ្លួន និងរស់នៅយ៉ាងសុខសាន្តជាមួយប្រជាជនខ្មែរឯទៀត ដែលបានមកតាំងទីលំនៅក្នុងស្រុកត្រពាំងប្រាសាទ ។ សែន បាន សម្រេចចិត្តប្រតិបត្តិព្រះពុទ្ធសាសនាដូចប្រជាជនខ្មែរទូទៅទៀត ផង ។ **ជារ៉ារដ្ឋ មេត្តា**

# ការជម្លៀសគ្រូបង្រៀន និង មន្ត្រីរាជការ នៅខេត្តប៉ៃលិន ក្នុងឆ្នាំ១៩៧៥

ខែកញ្ញា ឆ្នាំ១៩៧៣ ឪពុកខ្ញុំឈ្មោះ គឹម សុវណ្ណ រៀនចប់មហាវិទ្យាល័យគរុកោសល្យ ក៏ទៅធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាតាស្រី តំបន់អធិការកិច្ចប្រាសាទភាសន៍ ស្រុកថ្មពួក ខេត្តបាត់ដំបង នៅក្នុងឆ្នាំ១៩៧៣ ដែលសព្វថ្ងៃនេះហៅថា ខេត្តបន្ទាយមានជ័យ ។ នៅឆ្នាំ១៩៧៤ គាត់បានផ្លាស់ទៅសាលាបឋមសិក្សាប៉ៃលិនខាងលិច តំបន់អធិការកិច្ចប៉ៃលិន ខេត្តប៉ៃលិន ដោយសារតែម្តាយខ្ញុំឈ្មោះ អ៊ា ប៊ុនអេង នៅប្រកបរបររកស៊ីនៅទីនោះ ។ នៅខេត្តប៉ៃលិន មិនមានព្យុះសង្គ្រាម ឬខ្លាំងអុកឡុកអ្វីទេ និយាយរួមគឺជាខេត្តដែលមានសន្តិភាពបរិបូរណ៍ ប៉ុន្តែចំពោះការធ្វើដំណើរពីខេត្តបាត់ដំបងមកខេត្តប៉ៃលិនមិនមានសន្តិសុខតាមផ្លូវទេ ដោយសារតែខ្មែរក្រហមស្ទាក់កាត់វាយតាមពាក់កណ្តាលផ្លូវ ។ ប្រជាពលរដ្ឋនៅខេត្តប៉ៃលិន ប្រកបរបរធ្វើត្បូង ជាពិសេសគឺត្បូងខៀវ និងត្បូងក្រហម មានការផលិតបានច្រើន ដូច្នេះធ្វើឲ្យការប្រកបមុខរបរនេះមានការរីកចម្រើនខ្លាំង ដែលធ្វើឲ្យប្រជាពលរដ្ឋនៅទីនោះមានជីវភាពធូរធារ និងចូលចិត្តការសប្បាយ ។


ឪពុកម្តាយរបស់ គឹម សុវណ្ណដានី

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខេត្តប៉ៃលិនមិនមានរឿងអ្វីកើតឡើងទេ រហូតដល់ពេលយប់ក៏នៅតែមិនដឹងថា ខ្មែរក្រហមបានវាយចូលទីក្រុងភ្នំពេញដែរ ប៉ុន្តែហេតុចម្លែកត្រង់ថា ស្អែកឡើងនាថ្ងៃទី១៨ ខែដដែល លោក សេក សំអៀត ចៅហ្វាយខេត្តបាត់ដំបង បានជិះយន្តហោះទៅចុះនៅខេត្តប៉ៃលិន ហើយបានបបួលចៅហ្វាយខេត្តប៉ៃលិន លោក ហ៊ុល ទោន ប្រជុំដោយបានកោះហៅមន្ត្រីរាជការទាំងអស់នៅក្នុងខេត្តប៉ៃលិន គាត់ (ចៅហ្វាយខេត្តបាត់ដំបង) បាននិយាយក្នុងអង្គប្រជុំថា "អ្នកចង់ទៅតាមគាត់អញ្ជើញរៀបចំខ្លួនទៅ យកល្អនាំគ្នាទៅមើលសភាពការណ៍នៅថៃមួយរយៈសិន ប្រទេសចប់សង្គ្រាមហើយខ្មែរក្រហមកាន់កាប់ភ្នំពេញហើយ" ។ លុះយប់ឡើងក្រោយពេលប្រជុំចប់ គាត់បានធ្វើដំណើរទៅប្រទេសថៃ មានអមដោយរថក្រោះ ឡានទាហានដង្ហែជាក្បួនផង ។ ចំណែកឪពុក និងម្តាយខ្ញុំបានសម្រាកនៅលើផ្ទះមើលក្បួនដង្ហែរហើយគិតថា "ប្រទេសសន្តិភាពហើយ មិនគិតនៅក្នុងប្រទេសទេ បែរជារត់ចោលស្រុកទៅវិញ អញ្ចឹងទុកឲ្យគេទៅចុះ ព្រោះអ្នកដែលទៅនោះសុទ្ធតែអ្នកជិះជាន់គេ និងបានធ្វើមិនល្អក្នុងសម័យមុន (សម័យ លន់ នល់)" ។

បីថ្ងៃក្រោយមក ស្រាប់តែអង្គការខ្មែរក្រហមបានចូលមកដល់ប៉ៃលិន ហើយក៏បានប្រមូលកងទ័ពដែលមានបណ្តាសក្តិ ដើម្បីឡើងឡានទៅទទួលសម្តេចឪ ព្រោះសម្តេចឪបានធ្វើមាតុភូមិ

និវត្តន៍ត្រឡប់ចូលស្រុកវិញ ។ មួយថ្ងៃពេញ ខ្មែរក្រហមប្រមូលបានអ្នកមានសក្តិជាច្រើនឡាន មានទាំងសក្តិ១ សក្តិ២ សក្តិ៣ ខ្លះចេញមកពីព្រៃ ខ្លះនៅក្នុងខេត្តរួចក៏ចេញដំណើរទៅបាត់រហូតទៅ ។ នៅថ្ងៃទី២១ ខ្មែរក្រហមចាប់ផ្តើមប្រមូលប្រជាជននៅក្នុងខេត្តឲ្យជម្លៀសទៅធ្វើស្រែចម្កា ដោយស្រែកប្រកាសតាមមេក្រូថា "អ្នកណានៅស្រុកណា ឲ្យត្រឡប់ទៅស្រុកនោះវិញ" តែមន្ត្រីរាជការនិងគ្រូបង្រៀនទាំងអស់ក្នុងខេត្តប៉ៃលិន មិនទាន់ឲ្យទៅទេ គឺឲ្យមកជុំគ្នាសាលាបឋមសិក្សាប៉ៃលិនខាងកើតដើម្បីរង់ចាំស្តាប់អង្គការដាក់ទិស ។ ដូច្នេះ ម្តាយ យាយ តា ពូ មីង របស់ខ្ញុំទាំងអស់គ្នា នាំគ្នាធ្វើដំណើរទៅមុនតាមផ្លូវជាតិលេខ១០ ដែលមានទិសដៅតម្រង់ទៅតាមគ្រែង ស្ទឹង ស្វាយជាតិ មោងឫស្សី ស្វាយដូនកែវ រហូតដល់ពោធិ៍សាត់ ។ ពេលនោះដែរ ជីតារបស់ខ្ញុំឈ្មោះ អ៊ា ស្រេង និងមិត្តភក្តិរបស់គាត់ពីរនាក់ទៀត ឈ្មោះ ហាង ឈួង និង ហាង ជីវ ជាជនជាតិចិនដែលបានធ្វើដំណើរមកពីប្រទេសចិន ក្នុងបដិវត្តន៍ម៉ៅ សេទុង មករស់នៅប្រទេសកម្ពុជាដឹងភ្លាមថា ផែនការនេះគឺផែនការដូចប្រទេសចិនហើយ ពេលដែលជម្លៀសទៅហើយមិនបានមកវិញទេ គេប្រាកដជាឲ្យទៅធ្វើស្រែហើយដូចបដិវត្តន៍ស្រុកចិនហើយ ហើយពួកគាត់បានប្រាប់កូនៗឲ្យប្រមូលឥវ៉ាន់ដែលមាន ដាក់ទៅតាមខ្លួនទាំងអស់ ក៏ដូចជាបានរៀបចំឥវ៉ាន់ដាក់ពេញមួយរទេះគ្រប់គ្នា ដោយមានរបស់របរគ្រប់បែបយ៉ាង ដូចជា អង្ករ ប៊ីចេង ស្ករ ពូថៅ កាំបិត ចបកាប់ ។ល ។ គ្រួសារឪពុកម្តាយខ្ញុំមានរបស់របរគ្រប់បែបយ៉ាង ។ ដោយឡែកប្រជាជនខ្លះ មានតែឥវ៉ាន់បន្តិចបន្តួច វែកម្នាក់មួយអំរែកតែប៉ុណ្ណោះ ។

លុះយប់ថ្ងៃទី២១ដដែល ក៏ឃើញម្តាយ យាយ ប្អូនប្រុសម្នាក់ និងប្អូនស្រី៣នាក់របស់ម្តាយខ្ញុំ បានត្រឡប់មកជួបឪពុករបស់ខ្ញុំនៅក្នុងសាលាបឋមសិក្សាប៉ៃលិនខាងកើតវិញ ដោយសារមានការកកស្ទះផ្លូវទៅមុខមិនរួច ហើយពួកគាត់បានបែកពីជីតានិងពូរបស់ខ្ញុំ ព្រោះពួកគាត់មានកម្លាំងគ្រប់គ្រាន់អាចដើរអូសរទេះទៅមុខបានលឿន ។ រយៈពេលមួយយប់មួយថ្ងៃបានកន្លងផុត ឪពុកម្តាយរបស់ខ្ញុំ និងក្រុមគ្រួសារ នៅតែពុំមានដំណឹងអ្វីពីការដាក់ទិសរបស់អង្គការចំពោះគ្រូបង្រៀន គ្រូពេទ្យ និងមន្ត្រីរាជការផ្សេងនៅទីនោះដដែល ។ ស្រាប់តែយប់បន្ទាប់ ប្រហែលថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥ នាម៉ោង៣ទៀបភ្លឺ មាននីរសាររបស់ខ្មែរក្រហមម្នាក់ បានជិះសេះចូលមកប្រាប់គ្រូម្នាក់ដែលនៅជុំគ្នាជាមួយឪពុកខ្ញុំ នឹងត្រូវជាគ្រូរបស់អ្នកជិះសេះ ដោយការគោរពក្នុងនាមជាសិស្សថា "លោកគ្រូបានរួចជីវិតហើយ អង្គការលើកលែងទោសឲ្យលោកគ្រូហើយ តែលោកគ្រូត្រូវប្រយ័ត្នខ្លួន និងខំធ្វើការ លោកគ្រូមិនអាចប្រឆាំងនឹងគេបានទេ តែប្រឆាំង គឺស្លាប់ហើយ ។ លោកគ្រូខំកសាងខ្លួនទៅ អង្គការប្រជុំគ្នាសម្រេចថា មិនកម្ទេចទេ" ។ ពេលនោះទើបឪពុកខ្ញុំភ្ញាក់ខ្លួនព្រឺត ហេតុដូច្នេះហើយទើបគ្រូបង្រៀននៅខេត្តប៉ៃលិនភាគច្រើននៅជំនាន់ខ្មែរក្រហម បានលាក់ប្រវត្តិរូប ។

ក្រោយមកពេលភ្លឺឡើងខ្មែរក្រហមបានជម្លៀសគ្រូបង្រៀន គ្រូពេទ្យ និងមន្ត្រីរាជការទាំងអស់ ទៅតាមផ្លូវចម្ការកាហ្វេ សាលាក្រៅ កំរៀង ចង្ហូរវែង ស្រែអន្ទាក់ ខ្លាយ ដែលស្របតាមបណ្តោយទល់ដែនថៃ ។ ការធ្វើដំណើរទាំងថ្ងៃទាំងយប់ ដោយសម្រាកខ្លះ ធ្វើដំណើរខ្លះ និងរកអាហារហូបនៅតាមផ្លូវខ្លះ ប៉ុន្តែមិនមានការបង្ខិតបង្ខំ ឬរឹបអូសយកសម្ភារអ្វីឡើយ ។ យូរៗម្តងឃើញកងទ័ពខ្មែរក្រហមម្នាក់នៅតាមផ្លូវ ដូច្នេះគាត់អាចសម្រាកប៉ុន្មានថ្ងៃក៏បាននៅតាមផ្លូវ ហើយចង់បេះបន្លែផ្លែឈើតាមភូមិហូបក៏បាន មិនដូចការជម្លៀសនៅទីក្រុងភ្នំពេញទេ ។ លើសពីនេះទៀត អំឡុងពេលជម្លៀស ឪពុកម្តាយខ្ញុំអាចប្រើក្រដាស់ប្រាក់ដើម្បីទិញម្ហូបអាហារពីប្រជាជនមូលដ្ឋានបានថែមទៀត ។ ដើរបានមួយថ្ងៃ ឪពុកម្តាយ និងក្រុមគ្រួសាររបស់គាត់ទៅដល់សាលាក្រៅ ហើយនៅថ្ងៃបន្ទាប់ទៅដល់ខ្លាយដែលជាទីកន្លែងបំបែក ។ យើងធ្វើដំណើរទៅត្រង់ទៅខាងស្រែអន្ទាក់ កំប្រ៉ង់ តាគ្រែ និងបត់ឆ្វេងទៅចង្ហូរវែង ដែលកៀកនឹងទល់ដែនថៃ ជាកន្លែងដែលឪពុកម្តាយឆ្ពោះទៅក្នុងគោលបំណងចង់រត់ទៅប្រទេសថៃ ។ ពេលនោះគ្រូបង្រៀន និងមន្ត្រីរាជការទាំងអស់បានបែកផ្លូវគ្នាតាមគោលដៅរៀងៗខ្លួន ។

ពេលទៅដល់ភូមិចង្ហូរវែង មានស្ទឹងមួយហូរកាត់ភូមិ ហើយពេលឆ្លងស្ទឹងនោះរួច ប្រហែលចម្ងាយ៨គីឡូទៀតពីស្ទឹង គឺទៅដល់ប្រទេសថៃ ប៉ុន្តែឪពុកម្តាយ និងគ្រួសារមិនអាចបន្តទៅបានទៀតទេ ព្រោះខ្មែរក្រហមបានចាត់ជាក្រុមសាមគ្គីដើម្បីធ្វើស្រែនៅភូមិ

ចង្ហូរវែងនោះ ។ នៅទីនោះបានប្រហែលមួយអាទិត្យទៅកន្លះខែ ខ្មែរក្រហមបានចាត់តាំងអ្នកមូលដ្ឋានឲ្យដឹកនាំទៅធ្វើស្រែចម្ការទាំងអស់គ្នា (ប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី) ហើយប្រធានភូមិ ប្រធានក្រុមចាប់ផ្ដើមចុះស្ថិតិក្នុងភូមិ ហើយប្រជាជនថ្មីក៏មិនបានលាក់ប្រវត្តិរូបដែរ លើកលែងតែទាហាន លន់ នល់ គឺមិនហ៊ានប្រាប់ត្រង់ ព្រោះនឹងត្រូវយកទៅសម្លាប់ ។ ផ្សេងពីគ្រូពេទ្យ គ្រូបង្រៀន មន្ត្រីរាជការផ្សេងៗ គឺប្រាប់ការពិតទាំងអស់ ព្រោះខ្មែរក្រហមនៅទីនោះមិនបានយកទៅសម្លាប់ទេ ។ ទោះជាយ៉ាងនេះក្ដី ក៏មានការស៊ើបការណ៍ដើម្បីស្វែងរកទាហាន លន់ នល់ យកទៅសម្លាប់ដែរ គ្រាន់តែសមាជិកគ្រួសាររបស់អ្នកស្លាប់ មិនត្រូវបានស៊ើបអង្កេតចាប់កំហុសយកទៅសម្លាប់បន្ត ។

នៅភូមិចង្ហូរវែងបាន៣ទៅ៤ខែ ស្រាប់តែ ជីតា និងពូរបស់ខ្ញុំមកពីស្រុកមោងឫស្សីបានមកតាមរកគ្រួសារ ។ គាត់មកដល់ភូមិតាគ្រែ ស្រុកបវេលតាមរថភ្លើងដែលមានតែក្រដាស់មួយសន្លឹកសរសេរដោយកម្មាភិបាលខ្មែរក្រហម ជាលិខិតអនុញ្ញាតឲ្យគាត់ និងកូនប្រុសទៅរកប្រពន្ធកូននៅស្រុកបវេល ។ ពេលទៅដល់ភូមិតាគ្រែ កងឈ្លបក៏បានមកស៊ើបរកឃើញថា មានឈ្មោះឪពុកម្ដាយនៅភូមិចង្ហូរវែង ។ បន្ទាប់មក កងឈ្លបនោះក៏យករទេះគោមកដឹកឪពុកម្ដាយ និងក្រុមគ្រួសារទៅជួបជីតា និងពូនៅភូមិតាគ្រែ ហើយមិនបានអនុញ្ញាតិឲ្យត្រឡប់ទៅភូមិចង្ហូរវែងវិញទេ គណៈឃុំនៅទីនោះឈ្មោះ ពុកឡោ ។ នៅភូមិតាគ្រែបានប្រហែល២ ទៅ៣ខែ អ្នកភូមិចង្ហូរវែងជាច្រើនគ្រួសារបានរត់ទៅប្រទេសថៃ ពេលនោះខ្មែរក្រហមក៏បានជម្លៀសប្រជាជនពីភូមិចង្ហូរវែង មកភូមិតាគ្រែ ហើយក៏ជួបក្រុមគ្រួសាររបស់ឪពុកម្ដាយវិញ ។ គ្រួសារឪពុកម្ដាយខ្ញុំរស់នៅទីរហូតដល់ដើមឆ្នាំ១៩៧៦ ខ្មែរក្រហម ក៏ចាប់ផ្ដើមបង្កើតសហករណ៍ ដែលក្នុងមួយសហករណ៍មាន១០០ គ្រួសារ និងចាប់ផ្ដើមហូបបាយរួម ប៉ុន្តែមិនមានការបែងចែកកងបុរស ឬកងនារី ឬកងកុមារ ឬកងចាស់ នោះទេ មានតែការបែងចែកជាក្រុមជនជាតិកូឡា ក្រុមជនជាតិខ្មែរ និងក្រុមជនជាតិចិន ហើយជនជាតិនីមួយៗសង់ផ្ទះនៅជុំគ្នាតាមជនជាតិរៀងៗខ្លួន ដោយចាត់តាំងជនជាតិនីមួយៗជាប្រធាន និងអនុប្រធានក្រុម ដោយសារការប្រើប្រាស់ភាសាខ្មែរ ។ ឪពុកម្ដាយខ្ញុំ និងគ្រួសារត្រូវបានចាត់ចូលក្នុងក្រុមជនជាតិចិន ដែលឪពុកខ្ញុំត្រូវចាត់តាំងជាអនុប្រធានក្រុមចិន ។ សហករណ៍មួយអាចមានពី១០០ ឬ ២០០ ឬ ៣០០គ្រួសារ ដូចជា សហករណ៍តាគ្រែ សហករណ៍ដំណាក់សាលា សហករណ៍ មានល័ក្ខ សហករណ៍កំប្រ៉ង់ តាមភូមិមួយៗ ។

ពេលដែលកំពុងស្ថិតនៅក្នុងរបបខ្មែរក្រហម ឪពុកខ្ញុំមិនបានដឹងទេថា ហេតុអ្វីទើបគេមិនគាបសង្កត់ខ្លាំងនៅតំបន់ដែលគាត់រស់នៅ ទើបតែក្រោយរំដោះឆ្នាំ១៩៧៩ ទើបគាត់ដឹងថាខ្មែរក្រហមខ្លាចប្រជាជនរត់ទៅថៃ ។ ដោយខ្មែរក្រហមបានអនុញ្ញាតឲ្យប្រជាជនឈប់សម្រាកមួយថ្ងៃក្នុងពេលដប់ថ្ងៃ ថែមទាំងមានសិទ្ធិរកម្ហូបហូបបានតាមចិត្ត លើកលែងតែរបបអាហារជាប្រចាំថ្ងៃ គឺហូបបបរលាយដំឡូងឈើ ។ បបរមិនរាវទេ គឺខាប់តែពេលច្រូតកាត់ ឬមានបាយលាយសណ្ដែកខៀវហូបរយៈពេល៣ខែ រួចចាប់ផ្ដើមហូបបបរវិញ ។ ប៉ុន្តែម្ហូបមានជាប្រចាំមិនដាច់ទេ ព្រោះមានការចាត់តាំងឲ្យរកម្ហូប គ្រាន់តែមិនមានសាច់ជ្រូក សាច់គោ គឺមានតែបន្លែ ឬប្រហុក ។ នៅទីនោះម្ដាយខ្ញុំបានពរពោះបងប្រុសច្បងរបស់ខ្ញុំ ។ ខ្មែរក្រហមបានឲ្យម្ដាយទៅធ្វើការធម្មតា តែក៏មានការអនុគ្រោះដល់គាត់ដែលមានផ្ទៃពោះដែរ និងផ្ដល់របបបំប៉នឲ្យបានហូបឆ្អែត និងឲ្យសម្រាកនៅពេលដែលម្ដាយខ្ញុំហត់នឿយអស់កម្លាំងម្ដងៗ ។ នៅពេលសម្រាលកូនរួច ខ្មែរក្រហមមានរបបអាហារសម្រាប់ទារក គឺមួយថ្ងៃមួយកំប៉ុងអង្ករសម្រាប់ហូបបីពេល ប៉ុន្តែសម្រាប់ម្ដាយ ហូបរបបអាហារនៅឯរោងបាយរួមជាធម្មតា ។ នៅពេលម្ដាយខ្ញុំឈឺពោះសម្រាលកូន ប្រជាជននៅក្នុងភូមិបានជួយហៅឆ្មបភូមិមកជួយបង្កើត ប៉ុន្តែសំណាងល្អ ឪពុកខ្ញុំស្គាល់មិត្តភក្តិរបស់គាត់ដែលជាពេទ្យឆ្មបពីសង្គមចាស់ គាត់ក៏បានទៅតាមឲ្យមកជួយម្នាក់ទៀត ចៃដន្យម្ដាយខ្ញុំពិបាកក្នុងការបង្កើតកូន ពេលនោះបានពេទ្យដែលជាមិត្តភក្តិឪពុកខ្ញុំជួយបង្កើត ដោយប្រើប្រាស់ថ្នាំពេទ្យដែលឪពុកម្ដាយខ្ញុំប្រមូលយកពីផ្ទះពេលដែលជម្លៀសមក ទើបអាចសង្គ្រោះម្ដាយ និងបងប្រុសរបស់ខ្ញុំបានរួចផុតពីគ្រោះថ្នាក់នេះ ។ ពេលបងប្រុសអាយុបាន៣ ទៅ៤ខែ ខ្មែរក្រហមចាប់ផ្ដើមចាត់តាំងមនុស្សចាស់ ដែលធ្វើការធ្ងន់មិនបានឲ្យមើលកូនង៉ាក្នុងម្នាក់មើល១ ឬ២នាក់ ហើយឲ្យម្ដាយទៅធ្វើការស្ទូងដកវិញ ។

ដោយឡែក បើកូនយំគេអនុញ្ញាតឲ្យម្តាយមកបំបៅកូន ហើយជួនកាលក៏អនុញ្ញាតឲ្យមេដោះយកកូនមកឲ្យម្តាយបំបៅដល់កន្លែងធ្វើការនៅឯស្រែទៀត ។ ពេលក្រោយមកទៀត ឪពុកម្តាយក៏បានស្នើសុំយកបងប្រុសមកផ្ទះ ដោយស្នើឲ្យមេដោះដែលមើលថៅគាត់នៅក្បែរនោះជួយមើលថែថែមទៀត ។

ក្រោយមកចុងឆ្នាំ១៩៧៦ ទើបបែងចែកក្រុមយុវជនឈានមុខ ដែលជាកម្លាំងស្រួចឲ្យទៅធ្វើស្រែនៅអំពិលប្រាំដើម ដែលមានចំងាយពីភូមិតាគ្រែជិត២០គីឡូ ហើយ១២គីឡូពីស្រុកបវេល ដោយបែងចែកតាមគ្រួសារ ដូចជាឪពុកម្តាយដែលទើបតែមានកូនម្នាក់ ត្រូវទៅនៅភូមិអំពិលប្រាំដើម ដែលពេលនោះចាប់ផ្តើមមានសហករណ៍ និងកងច្បាស់លាស់ គឺមួយសហករណ៍មាន១.០០០គ្រួសារ ហើយមួយកងមានពី៣០ ទៅ៤០គ្រួសារ ។ តាមការសង្កេតរបស់ឪពុកខ្ញុំ ប្រជាជនមូលដ្ឋានដែលគាត់បានជួបគ្រប់ភូមិដែលគាត់បានទៅដល់មានការរីករាយ និងរាក់ទាក់ខ្លាំងចំពោះប្រជាជនថ្មីដោយសារមានរបស់របរដូចជា ខោអាវសម្រាប់ដូរ មិនតែប៉ុណ្ណោះប្រជាជនមូលដ្ឋាន មានការអាណិតអាសូរដល់


រូបរាប់ពីឆ្វេង : អ៊ា ប៊ុនអេង និងប្អូនៗ

ប្រជាជនថ្មីដោយបានលើកឡើងថា “ដោយសារតែសង្គ្រាមទើបត្រូវជម្លៀសប្រជាជន បានធ្វើបាបប្រជាជនថ្មីដែលនៅទីនោះមានលុយសប្បូរសប្បាយហើយ ឲ្យមកធ្វើស្រែ” ហើយសូម្បីតែប្រធានសហករណ៍ក៏បាននិយាយដូច្នេះដែរ ។ ជាក់ស្តែង ប្រធានសហរណ៍តាគ្រែ ឈ្មោះ ពុកឡោ បាននិយាយប្រាប់ប្រជាជនមូលដ្ឋានទាំងអស់ថា “មិនឲ្យរើសអើងទេ ព្រោះអ្នកដែលជម្លៀសមកសុទ្ធតែអ្នកមានជីវភាពធូរធារ និងបានមកដាក់ខ្លួនដើម្បីហូបរួមជាមួយយើងហើយ ដូច្នេះយើងត្រូវតែរាប់អាន រាក់ទាក់មិនឲ្យអ្នកណាធ្វើផ្តេសផ្តាស់លើប្រជាជនថ្មីទាំងអស់នោះទេ” ។

ទោះបីជាក្រោយមកទៀត មានការផ្លាស់ប្តូរអ្នកដឹកនាំដោយខាងកម្មាភិបាលភូមិភាគបស្ចិម នាចុងឆ្នាំ១៩៧៦ និងក្រោយមកបានមួយឆ្នាំខាងភូមិភាគនិរតីក៏ដោយ ក៏មិនមានការរឹតបន្តឹងច្រើនដែរ ។ ដោយសារធ្លាប់មានទាហាននៅតាមទល់ដែនចូលរួមប្រជុំជាមួយកម្មាភិបាលខ្មែរក្រហម ហើយបានព្រមានដល់កម្មាភិបាលនៅក្នុងសហករណ៍កុំឲ្យមានការបង្អត់អាហារប្រជាជន បើមានប្រជាជនរត់ទៅដោយសារការខ្វះខាតអាហារទៀត និងយកកម្មាភិបាលទាំងនោះទៅសម្លាប់ចោលទាំងអស់ ព្រោះមានប្រជាជនរត់ទៅថៃច្រើនណាស់ ម៉្លោះហើយទើបកម្មាភិបាលដែលមកបន្តមិនហ៊ានប្តូររបៀបគ្រប់គ្រង ដោយយល់ថា ការដឹកនាំពីមុន គឺមានការរៀបចំបានល្អហើយ ។ ឪពុកខ្ញុំបានដឹងពីការគំរាមរបស់កងទ័ពខ្មែរក្រហមតាមទល់ដែន ព្រោះពេលនៅខាងភូមិតាគ្រែ ឪពុកខ្ញុំជាអនុប្រធានក្រុមជនជាតិចិន គាត់ថែមទាំងធ្លាប់បានចូលរួមប្រជុំនិងបោះឆ្នោតរើសតំណាងរាស្ត្រទៀតផង ពេលនោះសមមិត្ត អ៊ុយ ជាតំណាងរាស្ត្រមណ្ឌលបវេល នាចុងឆ្នាំ១៩៧៥ ឬនៅដើមឆ្នាំ១៩៧៦ ។ ការបោះឆ្នោតនោះមានលក្ខណៈចម្លែក ដោយមានតំណាងរាស្ត្រតែម្នាក់គត់ដែលឈរឈ្មោះ ហើយពេលបោះឆ្នោតមានប្រូកតែមួយទេឲ្យចូលទៅបោះ ដោយបត់ក្រដាស់ចូលហិបឆ្នោត រួចចេញមកវិញក៏មានចែកបារីសេកឲ្យម្នាក់មួយកញ្ចប់ ។ ការបោះឆ្នោតនោះទៀតសោត មានលាយចម្រុះទាំងប្រជាជនថ្មី និងប្រជាជនចាស់ តែប្រជាជនថ្មីមានចំនួនតិច ដោយសារប្រជាជនថ្មីមានតែប្រធាន និងអនុប្រធានក្រុមជនជាតិកូឡា ជនជាតិចិន និងជនជាតិខ្មែរតែប៉ុណ្ណោះ ។ ចំណែកខាងប្រជាជនចាស់មានច្រើន

នាក់ មានតំណាងសហករណ៍ តំណាងក្រុមយុវជន តំណាងក្រុមបុរស តំណាងក្រុមនារី ។ល ។

ដោយឡែកការរៀបអាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម ឪពុកខ្ញុំធ្លាប់ឃើញតែម្តងគត់ គឺនៅក្នុងឆ្នាំ១៩៧៦ ដោយមានការស្នើរៀបការម្តងមួយគូរ ដោយរៀបការតាមប្រពៃណី ដែលមានឪពុកម្តាយចូលរួមដូចធម្មតា ។ ចាប់ពីពេលនោះមក ឪពុកខ្ញុំមិនដែលបានឃើញទៀតទេ ព្រោះឪពុកម្តាយខ្ញុំនៅក្នុងភូមិ ហើយកងចល័តនារី និងបុរសមិននៅក្នុងភូមិទេ ដូច្នេះគាត់មិនដឹងថា តើមានការប្តេជ្ញាក្នុងការរៀបការដែលបុយ៉ាងនោះ ។ ចំពោះការសម្លាប់នៅទីនោះឪពុកខ្ញុំមិនដែលបានឃើញទេ ចំពោះអ្នកខ្ជិលច្រអូសមិនធ្វើការ គឺគ្រាន់តែធ្វើការស៊ុយទិតៀនចំបុគ្គល និងមិនមានការដាក់ទារុណកម្មអ្វីឡើយ ។ តែឈ្មោះ ថាច សាមឿន ជាមិត្តភក្តិរបស់ឪពុកខ្ញុំដែលជាគ្រូបង្រៀនជាមួយគ្នា ត្រូវបានខ្មែរក្រហមយកទៅ ហើយអ្នកមូលដ្ឋាននៅទីនោះប្រាប់ថា ខ្មែរក្រហមច្រឡំថាគាត់ជាគិញ ។ ពេលនោះហើយដែលមានមិត្តភក្តិរបស់ឪពុកខ្ញុំមួយចំនួនទៀតមានការប្រុងប្រយ័ត្នខ្លាំង និងខ្លះទៀតរត់ទៅប្រទេសថៃ ។ ក្រោយមកទៀត មានមិត្តភក្តិរបស់ឪពុកម្នាក់ទៀតធ្វើទាហាន លន់នល់ បាននិយាយពិភាក្សាគ្នាពីការស៊ើបការណ៍ ក៏ត្រូវបានគេស៊ើបដឹងរួចក៏យកគាត់ទៅបាត់ទៀត ដោយយកលេសចាត់តាំងឲ្យគាត់បររទេះគោដឹកស្រូវជាមួយខ្មែរក្រហម ។ ស្រាប់តែពីរថ្ងៃក្រោយមក ឃើញតែរទេះ និងគោត្រឡប់មកវិញប៉ុណ្ណោះ ។ ក្នុងការស្វែងរកខ្លាំងនៅកន្លែងឪពុកម្តាយខ្ញុំរស់នៅ គឺតាមរយៈការស្រង់ស្ថិតិ



អ៊ា ប៊ុនអេង និង មិត្តភក្តិរៀននៅសាលាចិន ដើរលេងនៅពេលចូលឆ្នាំចិន នៅខេត្តប៉ៃលិន

សួរនាំនៅរោងបាយពេលយប់ម្តងហើយម្តងទៀត គឺធ្វើឡើងពីរដងនៅចុងឆ្នាំ១៩៧៥ម្តង និងឆ្នាំ១៩៧៧ម្តង ។ លើកលែងតែកម្មាភិបាលខ្មែរក្រហមត្រូវបានសម្លាប់ ពេលមានការផ្លាស់ប្តូរកម្មាភិបាលមកពីភូមិភាគបស្ចិម ។ នាចុងឆ្នាំ១៩៧៦ និងចុងឆ្នាំ១៩៧៨ មានការផ្លាស់ប្តូរកម្មាភិបាលភូមិភាគនិរតីចូលមក ហើយបានសម្លាប់កម្មាភិបាលពីភូមិភាគបស្ចិមមគ្មានសល់ម្នាក់ឡើយ ។ ចំណែកកម្មាភិបាលខាងពាយ័ព្យមួយចំនួនបានរត់គេចខ្លួន ស្រប ពេលមានការប្រកាសតាមចាប់ខ្លួនជាមួយគ្នានោះដែរ ។

នៅចុងឆ្នាំ១៩៧៨ មានហេតុការណ៍មួយចម្លែកកើតឡើង ដែលឪពុកក៏ដូចជាអ្នកភូមិដទៃទៀតត្រូវបានដាក់ទិសឲ្យដឹកស្រះពេលយប់ ។ បន្ទាប់ពីហូបបាយល្ងាចរួច ប្រជាជនត្រូវដឹកស្រះរហូតដល់ម៉ោងប្រហែល៩យប់ទើបឈប់ ហើយខ្មែរក្រហមបានប្រាប់ថា ពេលដឹករួចនឹងមានការជប់លៀងនំបញ្ចុក ។ អ្នកនៅក្នុងភូមិ ក៏ដូចជាឪពុកខ្ញុំមិនមានការចាប់អារម្មណ៍អ្វីទាំងអស់ ដោយស្មានតែខ្លាចមានការខ្វះទឹកប្រើប្រាស់ ។ លុះពេលដែលគាត់បែកមកតាមផ្លូវ ស្រាប់តែឮប្រជាជនគ្រប់កន្លែងទាំងអស់ប្រាប់ពីការដឹកស្រះ និងគម្រោងជប់លៀងហូបនំបញ្ចុកដូចៗគ្នាទាំងអស់ ដូច្នេះហើយទើបមនុស្សគ្រប់គ្នាយល់ថា ផែនការរបស់ខ្មែរក្រហម គឺចង់សម្លាប់ប្រជាជនថ្មីចោលទាំងអស់ ដោយខ្មែរក្រហមគិតថា អប់រំលែងបានហើយ និងចាត់ទុកជាខ្មាំង (ឪពុកខ្ញុំបានដឹងរឿងនេះនៅពេលដែលគាត់បានទៅរៀននយោបាយក្នុងជំនាន់ ហេង សំរិន) ដោយទុកតែក្មេងៗ ដែលជាកូនរបស់អង្គការ ហើយចាស់រកតែបះបោរ ។ តែជាសំណាងល្អមានការរំដោះបានមុន បើមិនដូច្នោះទេ គឺត្រូវសម្លាប់ប្រជាជនទាំងអស់ហើយ ។

នៅឆ្នាំ១៩៧៩ ប្រជាជនភូមិអំពិលប្រាំដើមដឹងថារបបខ្មែរក្រហមបានដួលរលំនៅក្នុងខែកុម្ភៈ ព្រោះកម្មាភិបាលខ្មែរក្រហមរត់បាត់អស់ពីក្នុងភូមិ ដោយឪពុកគ្រាន់ចាំថា មុននឹងបែកមានសំឡេងគ្រាប់កាំភ្លើងផ្លោងចូលមកក្នុងភូមិ១២គ្រាប់ ហើយព្រឹកឡើងបាត់កម្មាភិបាលខ្មែរក្រហមអស់ដោយមិនដឹងថាទៅណា ។ បន្ទាប់មក ក៏បានចាត់តាំងរកអ្នកដែលធ្លាប់ធ្វើជាទាហាន លន់ នល់ បីនាក់ឲ្យទៅស៊ើបនៅស្រុកបរវេលពីមូលហេតុនៃការបាត់ខ្លួនរបស់កម្មាភិបាលខ្មែរក្រហម ។ ពេលកំពុងរង់ចាំដំណឹង ប្រជាជនបាននាំគ្នាទៅប្រូតស្រូវតាមធម្មតា រយៈពេលបីថ្ងៃទើបដឹងថា គេរំដោះហើយប្រជាជននៅទីរួមស្រុកបរវេល មានការសប្បាយរីករាយ ទើបនាំគ្នាធ្វើដំណើរទៅស្រុកបរវេល ។ ពេលមកដល់ទីរួមស្រុកបរវេលប្រជាជនដឹកស្រា រាំច្រៀង ជប់លៀងយ៉ាងទ្រហឹងអឹងកងបានតែ២ថ្ងៃ ស្រាប់តែខ្មែរក្រហមត្រឡប់មកវិញ ប្រជាជននាំគ្នារត់មកខាងថ្មគោល ខេត្តបាត់ដំបង ដោយមានការបាញ់តាមពីក្រោយរបស់កងទ័ពខ្មែរក្រហម ។ ការត្រឡប់មកវិញនោះដែរ គឺមកកៀរប្រជាជនទៅជាមួយ តែឪពុកខ្ញុំមិនបានដឹងថាខ្មែរក្រហមប្រកាសយ៉ាងណានោះទេ ។ ពេលមកដល់ស្រុកថ្មគោល ប្រជាជននៅទីនេះមានការរស់នៅធម្មតាវិញ ហើយមានអ្នកខ្លះក៏រត់កង់ឌុប អ្នកខ្លះក៏ធ្វើស្រែចម្ការឡើងវិញ អ្នកខ្លះរកស៊ីយកស្ករ ប៊ីចេង សារ៉ុងពីប៉ោយប៉ែតមកដូរ ។ល ។ ឪពុកម្តាយខ្ញុំ និងក្រុមគ្រួសារបានមកស្នាក់នៅក្នុងខេត្តបាត់ដំបង ហើយឪពុកបានទៅនេសាទត្រីនៅបឹងទន្លេសាបជាមួយប្អូន ដែលមកពីខាងបឹងទន្លេសាប ហើយម្តាយនិងយាយរបស់ខ្ញុំលក់ឥវ៉ាន់ចាប់ហួយនៅផ្សារសាលា តាអន ។ ពេលឪពុកខ្ញុំនេសាទត្រីបានក៏យកមកធ្វើប្រហុក ធ្វើត្រីឆ្អើរួច ហើយម្តាយយកទៅលក់នៅផ្សារ ។ លុះបានដំណឹងថា ឪពុកម្តាយរបស់ឪពុកខ្ញុំនៅរស់ទើបគាត់នាំគ្នាត្រឡប់មកទីក្រុងវិញ តាមរយៈឡានដឹកទំនិញវៀតណាមទៅឈប់នៅសៀមរាប រួចបន្តមកខេត្តកំពង់ចាម រួចហើយជិះកាណូតពីកំពង់ចាមមកភ្នំពេញ ក្នុងខែតុលា ឆ្នាំ១៩៧៩ ។ នៅខែធ្នូឆ្នាំ១៩៧៩ ឪពុកខ្ញុំបានចូលធ្វើជាគ្រូបង្រៀនវិញ ដោយសារគាត់ធ្លាប់ជាគ្រូបង្រៀន ហើយមានឈ្មោះក្នុងបញ្ជីរបស់រដ្ឋ ទើបក្រសួងហៅឪពុកខ្ញុំឲ្យទៅបង្ហាញខ្លួន ។ ឪពុកខ្ញុំបង្រៀនថ្នាក់ទី៣បឋមសិក្សាបានរយៈពេល២ឆ្នាំ គាត់ក៏បានទៅធ្វើជាប្រធានរោងចក្រដីស ។ ក្រោយមកទៀតគាត់ក៏បានបង្កើតរោងជាងផលិតសម្ភារខបទ្រុស និងធ្វើជានាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមិត្តភាពកម្ពុជាជប៉ុន ។

ក្រោយរបបខ្មែរក្រហមដួលរលំ សមាជិកគ្រួសារម្តាយខ្ញុំដែលមានបងប្អូន៧នាក់ ត្រឡប់មកវិញតែ៥នាក់ និងយាយតារបស់ខ្ញុំ ហើយមីងរបស់ខ្ញុំឈ្មោះ អ៊ា ប៊ុនហួរ ស្លាប់ (ប្រហែលជាលង់ទឹកស្លាប់) និងប្អូនប្រុសម្តាយខ្ញុំម្នាក់ឈ្មោះ អ៊ា គីមហ៊ុន ហៅអ៊ុយ ស្លាប់ (ដោយសារគ្រាំក្នុង) ។ **គីម សុខណ្ណជានី**

# សិលាចារិកមួយផ្ទាំងត្រូវបានរកឃើញ នៅស្រុកអន្លង់វែង

សិលាចារិកមួយផ្ទាំងដ៏កម្រត្រូវបានប្រទះឃើញនៅក្នុងស្រុកអន្លង់វែង ដែលជាតំបន់តស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហម ។ ផ្ទាំងថ្មបញ្ឈរនិងធ្វើអំពីថ្មភក់កំពស់១.២ម៉ែត្រ និងទទឹង៤១សង់ទីម៉ែត្រមួយនេះមានចារិកអក្សរនៅជ្រុងម្ខាង ហើយត្រូវបានជឿជាក់ថាបានយកចេញពីទីតាំងប្រាសាទបន្ទាយស្រី ដែលមានឈ្មោះល្បីល្បាញអំពីក្បាច់ចម្លាក់ដ៏ល្អឯកក្នុងលោក ។

នៅវេលាម៉ោង៥ល្ងាច នៃថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨ យ៉ា ប៊ុន ដែលជាសមាជិកក្រុមការងាររបស់ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលដំណឹងអំពីការប្រទះឃើញសិលាចារិកមួយផ្ទាំងនៅក្នុងដីចម្ការមួយកន្លែងក្នុងភូមិរបស់ខ្លួនគឺភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ខណៈពេលដែលកសិករឈ្មោះ ឡុង ងិល អាយុ២៨ឆ្នាំ កំពុងបញ្ឆោត្រាក់ទ័រដើម្បី ពូនរងដាំដំឡូងមី សិលាមួយផ្ទាំងនេះបានផុសឡើង ។ ឡុង ងិល ក៏បានរាយការណ៍អំពីការរកឃើញ នេះដល់ យ៉ា ប៊ុន ដើម្បីអនុញ្ញាតឲ្យស្ថាប័នពាក់ព័ន្ធទាំងឡាយជ្រាបពីកិច្ចការនេះ និងត្រៀមថែរក្សាទុកជាសម្បត្តិបេតិកភ័ណ្ឌវប្បធម៌របស់ប្រទេសកម្ពុជា ។ ខ្ញុំបាទ លី សុខឃាង បានជូនដំណឹងតាមទូរស័ព្ទទៅកាន់ឯកឧត្តមបណ្ឌិត ស ថាវី អភិបាលនៃគណៈអភិបាលខេត្ត



ក្រុមការងារមកពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តឧត្តរមានជ័យ កំពុងវាស់ និងធ្វើកំណត់ត្រាសិលាចារិកមួយផ្ទាំងដែលប្រជាជនប្រទះឃើញនៅភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ខេត្តឧត្តរមានជ័យ លោក ហោ ជិនវិរយុទ្ធ អភិបាលនៃគណៈអភិបាលស្រុកអន្លង់វែង លោក ហុង ឃឿន ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ឧត្តរមានជ័យ លោក ជុក ជំនោរ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍នៃក្រសួងទេសចរណ៍ និងលោកស្រី ធិនធី មុនីរស្មី ប្រធានមន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យព្រមទាំងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលកំពុងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាមួយលោក ដេង ពង្សរ៉ាស៊ី ក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តព្រៃវែង ដល់លោកគ្រូអ្នកគ្រូប្រវត្តិសាស្ត្រមកពីខេត្តស្វាយរៀង និងព្រៃវែង ចំនួន៥២នាក់ ។

តាមការអះអាងជំហានដំបូងរបស់លោកសាស្ត្រាចារ្យ វង្ស សុធារ៉ា នៃដេប៉ាតឺម៉ង់ប្រវត្តិវិទ្យាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បន្ទះស្តម្ភត្រូវបានចារិកអក្សរស្តីពីការត្រាស់បង្គាប់របស់ព្រះបាទជ័យវរ្ម័នទី៥ នៅក្នុងអំឡុងចុងទសវត្សរ៍ឆ្នាំ៩៦០ (គឺចន្លោះពីឆ្នាំ៩៦៨ដល់៩៧០) ។ លោកសាស្ត្រាចារ្យបានបកស្រាយទៀតថា "អង្គព្រះមហាក្សត្របានចេញព្រះរាជបញ្ញា ព្រះរាជទានដីធ្លី និងភូមិដ្ឋានអនុគ្រោះថ្វាយប្រាសាទ (ប្រហែល) បន្ទាយស្រី ដោយសារមានបញ្ជាក់នាមថា "ឥស្វរបុរៈ" *(Isvarapura)* និងបោះគោលកំណត់ព្រំប្រទល់ដែនដីទាំងអស់នោះថ្វាយប្រាសាទ ព្រមទាំងតង្វាយភ័ស្តុភារជាច្រើនទៀតសម្រាប់ព្រះនោះ" ។ បើទោះជាលោកសាស្ត្រាចារ្យបានអានសិលាចារិកនេះតាមរយៈរូបភាពដែលថតមិនសូវច្បាស់យ៉ាងណាក៏ដោយ លោក យាន យ៉ា មន្ត្រីនៃការិយាល័យបេតិកភណ្ឌ ខេត្តឧត្តមានជ័យ បានយល់ឃើញស្រដៀងគ្នានេះដែរ ។ ការបកប្រែសិលាចារិកនេះនឹងត្រូវធ្វើឡើងបន្តទៀត ។

ដោយសារតែសិលាចារិកនេះមានសារសំខាន់ផ្នែកវប្បធម៌បេតិកភណ្ឌ និងទាមទារឲ្យមានកិច្ចសហការដ៏ល្អដើម្បីរង់ចាំស្ថាប័នពាក់ព័ន្ធមកទទួលយកសិលាចារិក ក្រុមការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានថែរក្សាទុកនៅក្នុងកន្លែងមានសុវត្ថិភាពចំនួនពីរថ្ងៃ ។ លុះដល់វេលាម៉ោង១២ រហូតដល់១ថ្ងៃត្រង់នៃថ្ងៃទី៧


ក្រុមការងារមកពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តឧត្តរមានជ័យ កំពុងវាស់ និងធ្វើកំណត់ត្រាសិលាចារិកមួយផ្ទាំងដែល ប្រជាជនប្រទះឃើញនៅភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ខែមេសា ឆ្នាំ២០១៨ យ៉ា ប៊ុន បានប្រគល់សិលាចារិកនេះជូនទៅ លោក ដួង លុច អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តឧត្តរមានជ័យ លោក អ៊ីង ពៅ ប្រធានការិយាល័យបេតិកភណ្ឌ និង លោក សុខ ចាន់ថន ប៉ូលីសបេតិកភ័ណ្ឌ ។ វត្តមាននៅក្នុងពិធីប្រគល់សិលាចារិកនេះមានដូចជា លោក ថន កុត អភិបាលរងស្រុកអន្លង់វែង, លោក ទៀង សាលីវ ប្រធានភូមិរំចេកខាងកើត និង ខ្ញុំបាទ (លី សុខឃាង) ។ ស្របពេលជាមួយគ្នានេះដែរ លោក វ៉ាន់ថា ពៅដារ៉ា នាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានសរសេរលិខិតមួយច្បាប់ជូនទៅលោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីជម្រាបអំពីការរកឃើញ និងការប្រគល់សិលាចារិក នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៨ នេះដែរ ។

គួរបញ្ជាក់ថា មានប្រាសាទបុរាណ និងទីទួលបុរាណជាច្រើនទៀតនៅក្នុងស្រុកអន្លង់វែង ហើយក៏កំពុងតែទទួលរងនូវការខូចខាត និងបាត់បង់ដែរ ។ កន្លងមក ក្រុមការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលជាគំនិតផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងទេសចរណ៍ ធ្លាប់ចុះទៅចងក្រង និងថតខ្សែវីដេអូឯកសារអំពី “ប្រាសាទដា” នៅខាងក្រោយភូមិរំចេកនេះ ។ ការបន្លាស់ទីរបស់សិលាចារិកពីទីតាំងប្រាសាទបន្ទាយស្រីនេះ (តាមការអះអាងដំហានដំបូង) ឆ្ពោះទៅព្រំដែនកម្ពុជាថៃ បាននិងកំពុងក្លាយជាភ័ស្តុតាងមួយដែលអាចឆ្លុះបញ្ចាំងអំពីការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌បេតិកភណ្ឌ ខណៈដែលប្រទេសកម្ពុជាកំពុងធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលចាប់ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩៨ ។ ប្រទេសកម្ពុជាក៏មានការអនុវត្តច្បាប់ និងផ្តន្ទាទោសចំពោះជនណាដែលលួចសម្បត្តិបេតិកភ័ណ្ឌវប្បធម៌របស់ជាតិដែរ ។ សិលាចារិកមួយផ្ទាំងនេះ ប្រហែលជាសារដ៏មានតម្លៃ ដែលទាមទារឲ្យមានការរួបរួមគ្នាជាធ្លុងមួយដើម្បីថែរក្សានិងការពារ ព្រមទាំងការសិក្សាស្រាវជ្រាវស៊ីជម្រៅដើម្បីស្វែងយល់អំពីការខូចខាត និងការបាត់បង់សម្បត្តិវប្បធម៌បេតិកភណ្ឌជាច្រើនរបស់ប្រទេសកម្ពុជានាពេលកន្លងមក ។ **លី សុខឃាង**


ក្រុមការងារមកពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តឧត្តរមានជ័យ មកទទួលសិលាចារិកមួយផ្ទាំងដែលប្រជាជនប្រទះឃើញនៅភូមិរំចេក យកទៅរក្សាទុក ។

# អំណះអំណាងមេធាវីការពារក្តីរបស់ នួន ជា ក្នុងការមិនបញ្ចប់សវនាការសួរដេញដោលនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**(តចប់)**

មេធាវីការពារក្តីរបស់ នួន ជា ដូវេន ចាន់ បាននិយាយថា អ្នកទោសទាំងនោះត្រូវបានចាប់ខ្លួនដោយស្របច្បាប់ និងមានការស៊ើបអង្កេតយ៉ាងត្រឹមត្រូវ ។ ការចាប់ខ្លួនជននានា គឺធ្វើទៅតាមច្បាប់ រួមជាមួយការតាមដានជាច្រើន ។ សាក្សីម្នាក់បាននិយាយថា នាងត្រូវបានគេសួរនាំតែម្តងគត់ ហើយត្រូវបានគេដោះលែងមួយសប្តាហ៍បន្ទាប់ពីនោះ ។ គាត់បានបន្ថែមថា គាត់មិនត្រូវបានគេធ្វើទារុណកម្មកំឡុងពេលដែលត្រូវបានសាកសួរនោះទេ ។

មេធាវី ដូវេន ចាន់ បានបន្តថា មិនមានភ័ស្តុតាងណាអាចបញ្ជាក់ថា គេបានប្រើប្រាស់ទារុណកម្មនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ នោះទេ ។ ព្រះរាជអាជ្ញាបានប្រើប្រាស់កំណត់ត្រាដែលមិនមានភាពជឿជាក់ លើសពីនេះទៅទៀតគេក៏បានប្រើប្រាស់នូវភ័ស្តុតាងពីដើមបណ្តឹងរដ្ឋប្បវេណីដែលពោរពេញទៅដោយកង្វះខាតដូចគ្នា ។ លើសពីនេះទៅទៀត ព្រះរាជអាជ្ញាក៏បានពឹងផ្អែកទៅលើសេចក្តីថ្លែងការណ៍របស់ជនបីរូប ដែលមិនបានឆ្លងកាត់ការផ្តល់ចម្លើយនៅក្នុងតុលាការ ហើយមានម្នាក់នៅក្នុងចំណោម៣នាក់បានស្លាប់ ។ ភ័ស្តុតាងដែលនៅសល់តែមួយគត់គឺមកពីសាក្សីម្នាក់ដែលបានឮសូរគេធ្វើទារុណកម្ម ប៉ុន្តែខ្លួនមិនដែល




អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានជួបប្រទះរឿងនេះដោយផ្ទាល់នោះទេ។ ចម្លើយរបស់នាងគឺមិនសូវមានភាពជាក់លាក់ ហើយក៏មិនសូវមានទម្ងន់ដែរ ប្រសិនបើយោងទៅតាមច្បាប់ ដូចនេះមិនមានភ័ស្តុតាងណាអាចបញ្ជាក់ថាការធ្វើទារុណកម្មត្រូវបានគេប្រើប្រាស់នៅមន្ទីរសន្តិសុខក្រាំងតាចាន់នោះទេ។ ភ័ស្តុតាងបានបញ្ជាក់ថា ជនដែលត្រូវបានគេឃុំខ្លួនមិនអាចដឹងអំពីសកម្មភាពក្នុងការសាកសួររបស់ជនផ្សេងទៀតនោះទេ ដូចនេះភ័ស្តុតាងដែលព្រះរាជអាជ្ញាបានលើកឡើង គឺហួសពីវិមតិសង្ស័យ។

មេធាវី ដូវេន ចាន់ បាននិយាយថា មានតែជនដែលប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរប៉ុណ្ណោះ ដែលត្រូវបានគេយកទៅឃុំនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ ឧទាហរណ៍ ជនដែលត្រូវបានចោទថាបានចូលរួមរៀបចំផែនការសម្ងាត់ដើម្បីផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ឬជនដែលបានប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈ។ ព្រះរាជអាជ្ញាបានព្យាយាមបន្ថយបទល្មើសរបស់ជនជាប់ចោទនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ហើយបន្ថែមនូវចំណាប់អារម្មណ៍ទៅលើទោសស្រាលដែលមានដូចជាធ្វើឲ្យបាត់ស្វាបព្រា ឬធ្វើឲ្យបាក់ចបជីកជាដើម។ សហព្រះរាជអាជ្ញាខកខានមិនបានលើកឡើងពីអត្ថហេតុថា ប្រជាជនទាំងនោះប្រព្រឹត្តបទល្មើសម្តងហើយម្តងទៀត ហើយត្រូវបានបញ្ជូនទៅអប់រំកែប្រែ។ ទីពីរ បរិបទរបស់ប្រទេសយើងគឺមានសារសំខាន់ខ្លាំងណាស់សម្រាប់ការកាត់ក្តីមួយនេះ។ កម្ពុជាប្រជាធិបតេយ្យ គឺជារដ្ឋដែលស្ថិតនៅក្នុងស្ថានភាពប្រកាសអាសន្នដោយសារកង្វះស្បៀង រួមទាំងសម្ភារប្រើប្រាស់ផ្សេងៗ។ ទាំងនេះគឺជាហេតុផលដែលរដ្ឋាភិបាលសម័យនោះបានប្រើប្រាស់នូវវិប្បធម៌សមូហភាព។ នៅក្នុងស្ថានភាពរីកវរដូច្នេះ ការលួចអាហារ ឬការធ្វើឲ្យបែកបាក់ស្វាបព្រាជាដើម គឺជាទង្វើដែលត្រូវបានមើលឃើញថាជាការបក្កការគំរាមកំហែងដល់ស្ថិរភាពសង្គម ដោយសារតែកង្វះខាតអាហារនាសម័យនោះ។ ដូច្នេះមានមនុស្សជាច្រើនត្រូវបានចាប់ខ្លួន និងយកទៅឃុំឃាំងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដោយសារបានប្រព្រឹត្តកំហុសទាំងនេះ។

បន្ទាប់មក ព្រះរាជអាជ្ញាបានលើកឡើងនូវអំណះអំណាងថា ជនដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខក្រាំងតាចាន់ភាគច្រើនគឺជាក្រុមគោលដៅរបស់កម្ពុជាប្រជាធិបតេយ្យ រួមមានប្រជាជនចំណូលថ្មី ជនជាតិវៀតណាម ឬជាប្តីប្រពន្ធរបស់ជនដែលត្រូវបានខ្មែរក្រហមឃុំខ្លួន ជាអតីតទាហានរបប លន់ នល់ ឬមន្ត្រីរដ្ឋការ។ អំណះអំណាងដែលបានលើកឡើងទាំងនេះមិនត្រឹមត្រូវទេ។ មានដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ប៉ុណ្ណោះបាននិយាយថា ជនជាតិវៀតណាមត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ប៉ុន្តែមិនមានភ័ស្តុតាងអាចបញ្ជាក់ថា អ្នកនោះជាជនជាតិវៀតណាម ឬអំពីមូលហេតុនៃការចាប់ខ្លួននោះទេ ដូច្នេះការលើកឡើងនេះមិនមានអំណះអំណាងគ្រប់គ្រាន់ក្នុងការបញ្ជាក់ពីការឃុំខ្លួន ឬសញ្ជាតិរបស់ជននោះទេ។ សាក្សីបាននិយាយថា ខ្មែរក្រហមបានឃុំឃាំងជនចំណូលថ្មីនៅក្រាំងតាចាន់ ប៉ុន្តែសក្ខីកម្មរបស់សាក្សីមិនមានអត្ថហេតុបញ្ជាក់ច្បាស់លាស់នោះទេ។ សាក្សីជានារីម្នាក់បាននិយាយថា នាងត្រូវបានខ្មែរក្រហមនាំទៅសួរចម្លើយ នៅទីនោះដោយសារទង្វើល្មើសច្បាប់របស់នាង មិនមែនដោយសារនាងជាប្រពន្ធរបស់ជនរងគ្រោះដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខនោះទេ។ នៅសប្តាហ៍បន្ទាប់យើងនឹងធ្វើបទបង្ហាញលម្អិតនិយាយអំពីមន្ត្រីនិងទាហាននៃរបបសាធារណរដ្ឋខ្មែរ។ ខ្មែរក្រហមបានឃុំខ្លួនជនទាំងនោះនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដោយយោងទៅតាមកំហុសដែលអ្នកទាំងនោះបានប្រព្រឹត្ត មិនមែនដោយសារអត្តសញ្ញាណពិសេសរបស់អ្នកទាំងនោះទេ។

មេធាវី ដូវេន ចាន់ បានលើកឡើងថា លក្ខខណ្ឌរស់នៅ និងធ្វើការងារនៅមន្ទីរសន្តិសុខក្រាំងតាចាន់ នៅអំឡុងពេលនោះត្រូវប្រឈមនឹងស្ថានភាពលំបាក ដោយសារកម្ពុជាប្រជាធិបតេយ្យស្ថិតនៅក្នុងស្ថានភាពប្រកាសអាសន្ន ប៉ុន្តែមិនបានប៉ះពាល់ដល់ជនដែលត្រូវបានបក្សកុម្មុយនីសកម្ពុជាចាប់ខ្លួននោះទេ។ បក្សកុម្មុយនីស្តកម្ពុជាបានព្យាយាមខិតខំកែប្រែស្ថានការណ៍ ឧទាហរណ៍បក្សកុម្មុយនីស្តកម្ពុជាបានបាញ់ថ្នាំដើម្បីការពារជំងឺគ្រុនចាញ់នៅមន្ទីរក្រាំងតាចាន់ ករណីនេះបានបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាមិនមានចិត្តព្យាយាមធ្វើបាបជនដែលជាប់ឃុំឃាំងនោះទេ។ សាក្សីម្នាក់បានបញ្ជាក់ពីការលំបាករបស់នាង ប៉ុន្តែការផ្តល់សក្ខីកម្មរបស់នាងមិនមានភ័ស្តុតាងគ្រប់គ្រាន់សម្រាប់ចោទប្រកាន់ទាក់ទងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬការធ្វើឲ្យទៅទាសករទេ។ បទរំលោភសេពសន្ថវៈដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា

នោះមិនបានរាប់បញ្ចូលជាភស្តុតាងដែលអាចបញ្ជាក់ឲ្យហួសពីវិមតិសង្ស័យនោះទេ ។ អតីតអ្នកយាមគុក២នាក់បាននិយាយថា រឿងនេះមិនដែលកើតមានឡើងនោះទេ ឯដើមបណ្តឹងរដ្ឋប្បវេណីម្នាក់និយាយថារឿងមួយនេះធ្លាប់កើតមានឡើង ប៉ុន្តែការលើកឡើងរបស់គេនៅតែមិនអាចយកមកប្រើប្រាស់បានដដែល ។ ដូច្នេះ អង្គចៅក្រមមិនមានភស្តុតាងណាអាចបញ្ជាក់ថាអង្គហេតុមួយនេះបានកើតឡើងនៅមន្ទីរក្រាំងតាចាន់នោះទេ ។

សហព្រះរាជអាជ្ញាបានចោទថា មនុស្សប្រហែល១៥.០០០នាក់ ត្រូវបានខ្មែរក្រហមសម្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ប៉ុន្តែមិនមានភស្តុតាងគាំទ្រក្នុងការចោទនោះទេ ។ មានមនុស្សពីរនាក់ បានបញ្ជាក់ថា ខ្លួនបានឃើញសាកសពនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ប៉ុន្តែសម្តីអ្នកទាំងពីរនេះមិនអាចយកជាការបាននោះទេ ។ ក្រៅពីនេះ មិនមានបុគ្គលណាអាចបញ្ជាក់រឿងរ៉ាវនេះបានទេ ។ សហព្រះរាជអាជ្ញាបានយោងទៅលើការសិក្សាពីឆ្អឹងរបស់អ្នកជំនាញដែលយកមកពីមន្ទីរសន្តិសុខក្រាំងតាចាន់ ប៉ុន្តែមិនបានបង្ហាញពីការធ្វើកោសល្យវិច័យឆ្អឹងទាំងនោះឲ្យបានត្រឹមត្រូវទេ ដោយសារអ្នកជំនាញមិនបានធ្វើកំណត់ត្រាច្បាស់លាស់ពីឆ្អឹងដែលខ្លួនវិភាគ ដូច្នេះអង្គជំនុំជម្រះមិនអាចដឹងច្បាស់ថា អ្នកជំនាញយកឆ្អឹងទាំងនេះមកពីកន្លែងណាទេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូច្នេះការសិក្សានេះគឺមានតម្លៃទាបណាស់ ។ ដោយសារមន្ទីរសន្តិសុខក្រាំងតាចាន់ មានទីតាំងស្ថិតនៅជិតរណ្តៅសាកសពរួម និងមន្ទីរពេទ្យ ដូច្នេះឆ្អឹងដែលបានប្រមូលយកមកប្រហែលអាចមកពីមនុស្សដែលបានស្លាប់ដោយសារគ្រោះធម្មជាតិ ឬស្លាប់ក្រោយរបបខ្មែរក្រហម ដូច្នេះមានហេតុផលដែលគួរឲ្យសង្ស័យថាឆ្អឹងទាំងនោះយកមកពីមន្ទីរសន្តិសុខក្រាំងតាចាន់ ។ ការបង្កើតមន្ទីរសន្តិសុខក្រាំងតាចាន់ គឺធ្វើឡើងដើម្បីអប់រំ ហើយមានជនដែលជាប់ឃុំឃាំងនៅទីនេះភាគច្រើនត្រូវបានដោះលែង ។ សាក្សីបាននិយាយថា ការបង្កើតមន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងគោលបំណងដើម្បីដោះស្រាយវិវាទ និងកសាងសាមគ្គីភាពឡើងវិញ ។ សាក្សីរស់បានបញ្ជាក់ថា មានមនុស្សជាច្រើនត្រូវបានដោះលែងបន្ទាប់ពីឆ្មាំគុកបានសាកសួរ ប៉ុន្តែព្រះរាជអាជ្ញាបែរជាធ្វើមិនដឹងមិនឮ ។ តាមពិតទៅ មន្ទីរសន្តិសុខក្រាំងតាចាន់ គឺជាមជ្ឈមណ្ឌលអប់រំកែប្រែ និងកន្លែងដោះលែង ។

**មន្ទីរសន្តិសុខអូរកន្សែង ភូមិភាគឦសាន**

មេធាវីដូរេនចាន់ បានលើកឡើងថា ការកំណត់លើភស្តុតាងក្នុងការចោទប្រកាន់ទាក់ទងទៅនឹងមន្ទីរសន្តិសុខគួរតែមាន ។ មេធាវីការពារក្តីនឹងផ្តោតសំខាន់ទៅលើហេតុផលជាក់ច្បាស់ ដែលសហព្រះរាជអាជ្ញាផ្អែកទៅលើ ។ ដំបូង តើមានភស្តុតាងអ្វីខ្លះដែលត្រូវលើកមកបង្ហាញពីការចាប់ខ្លួនដោយយោងទៅភាពស្របច្បាប់ ដែលអ្នកទោសត្រូវតែឆ្លងកាត់ការសួរចម្លើយដោយសារទង្វើដែលខ្លួនបានប្រព្រឹត្ត ។ អតីតអ្នកទោសមួយចំនួនបានផ្តល់សក្ខីកម្មថា ខ្លួនមិនត្រូវបានឆ្មាំគុករំលោភបំពាននោះ ទាំងនេះបានធ្វើឲ្យយើងដឹងពីការពិតថាវាជាប្រព័ន្ធដើម្បីអនុវត្តនៅមន្ទីរសន្តិសុខអូរកន្សែង ហើយចុងបញ្ចប់ភស្តុតាងតិចតួចដែលបានលើកឡើងថា មិនមានភាពមិនប្រក្រតីសម្រាប់លក្ខខណ្ឌចំពោះអ្នកទោសនៅពេលនោះទេ គឺមិនត្រឹមត្រូវទេ ។ ហេតុការណ៍ទាក់ទងការចាប់ខ្លួន និងការសម្លាប់ជនជាតិចារ៉ាយ សាក្សី៣នាក់បានផ្តល់សក្ខីកម្មជាមួយនឹងសារទូរលេខមួយដែលត្រូវបានរកឃើញ បានបញ្ជាក់ថា នួន ជា ក៏បានដឹងនូវហេតុការណ៍នេះដែរ ។ សារទូរលេខនោះបានផ្ញើចេញនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ និងបានចម្លងជូន នួន ជា ផងដែរ ។ សារទូរលេខនេះត្រូវបានរាយការណ៍អំពីការចាប់ខ្លួនទាហានវៀតណាមចំនួន២០៩ ដែលភាគច្រើនជាជនជាតិចារាយ នៅក្នុងតំបន់១០៧ ។ អ្នកទាំងនោះបានកាន់កាំភ្លើងដែលផលិតនៅប្រទេសអាមេរិក ដែនទីប្រទេសវៀតណាម គ្រាប់បែកដៃ រួមជាមួយនឹងសម្ភារយោធាជាច្រើនទៀត ។ អ្នកទាំងនេះត្រូវបានប៉ាន់ស្មានថាបាននិយាយភូតកុហក នៅពេលពួកគេនិយាយថាជាប្រជាជនវៀតណាមធម្មតា ។ សាក្សីបាននិយាយថា ទាហានទាំងនេះត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៨ ហើយសាក្សីពីរនាក់ក្នុងចំណោមសាក្សីទាំងនោះបាននិយាយថា ការចាប់ខ្លួនត្រូវបានធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ១៩៧៨ ដូចនេះយើងអាចនិយាយបានថា ការចាប់ខ្លួនត្រូវបានគេធ្វើឡើងជាច្រើនខែបន្ទាប់ពី នួន ជា ទទួលបានសារទូរលេខនៅខែមិថុនា ឆ្នាំ១៩៧៧ ។ ប៉ុន្តែ មិនមានពត៌មានជាក់លាក់ណាមួយដែលនិយាយអំពីក្រុមជនជាតិចារ៉ាយនោះទេ ។ សាក្សីទាំងនោះបាននិយាយអំពីមនុស្សមួយចំនួន រីឯសារទូរលេខបាន

និយាយអំពីចំនួនទាហានវៀតណាម២០៩នាក់ ដូចនេះមិនមានភ័ស្តុតាងណាអាចបញ្ជាក់លើការចោទប្រកាន់នេះឲ្យហួសពីវិមតិសង្ស័យដែលថាការលើកឡើងទាំងពីរនិយាយពីមនុស្សដូចគ្នា ។ សាក្សីទាំងនោះមិនបានឃើញខ្មែរក្រហមសម្លាប់មនុស្សដោយផ្ទាល់នោះទេ ហើយសារទូរលេខក៏មិនបាននិយាយថា អ្នកទាំងនោះត្រូវបានខ្មែរក្រហមសម្លាប់ដែរ ។ ការចាប់ខ្លួនជនជាតិវៀតណាមដែលត្រូវបានចោទប្រកាន់ថាជាទាហាន និងមានកាន់អាវុធដែលផលិតនៅប្រទេសអាមេរិក រួមជាមួយដែនទឹប្រទេសវៀតណាម គឺត្រូវបានធ្វើឡើងដោយស្របច្បាប់ មិនមែនដោយសារអត្តសញ្ញាណរបស់អ្នកទាំងនោះទេ ។

ការចោទប្រកាន់ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាស្តាប់ទៅហាក់បីដូចជាមិនសមហេតុផល ហើយផ្ទុយទៅវិញ វាបានបង្ហាញនូវកង្វះខាតចំណេះដឹងផ្នែកច្បាប់របស់សហព្រះរាជអាជ្ញាទៅវិញ ដោយសារបើទោះបីជនជាតិចាវ៉ាយមានសញ្ជាតិវៀតណាមក្តី ក៏ប៉ុន្តែដើមកំណើតរបស់ជនជាតិចាវ៉ាយ មិនមែនជាអំបូរខ្មែរ ឬវៀតណាមពិតប្រាកដនោះទេ ដូច្នេះការចាប់ខ្លួននេះមិនទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍របស់ជនជាតិវៀតណាមទេ ។

ជាចុងក្រោយ សារទូរលេខនោះមិនអាចបញ្ជាក់បានថា នួន ជា បានប្រព្រឹត្ត ឬចូលរួមក្នុងការសម្លាប់ទេពីព្រោះក្នុងសារទូរលេខបានបញ្ជាក់ថា អាជ្ញាធរមូលដ្ឋានបានចាប់ខ្លួនជនសង្ស័យជាច្រើន រួមជាមួយការរឹបអូសនូវសព្វាវុធក្នុងកំឡុងពេលសង្គ្រាមជាមួយវៀតណាម ហេតុផលទាំងនេះបានបង្ហាញថា នួន ជា មិនបានប្រព្រឹត្តឧក្រិដ្ឋកម្មទៅលើជនជាតិចាវ៉ាយទេ ។

មេធាវី ដូរេន ចាន់ បាននិយាយបន្តពីមន្ទីរសន្តិសុខភ្នំក្រោលថា វាគឺជាទីតាំងដែលបានកំណត់នៅក្នុងដីការបញ្ជូនរឿងឲ្យស៊ើបសួរថា ជាប់ទាក់ទងក្នុងតំបន់ស្វយ័ត១០៥ ដែលរាប់បញ្ចូលជាមួយទីតាំងបី ដែលនៅដាច់ដោយឡែកពីគ្នាមានដូចជា មន្ទីរសន្តិសុខភ្នំក្រោល មន្ទីរ ក-១១ និង ក-១៧ ។ មានសាក្សីចំនួន៦រូប បានផ្តល់សក្ខីកម្មរឿងនេះ ប៉ុន្តែក្នុងចំនោមសាក្សីទាំងនេះមានតែពីរនាក់ប៉ុណ្ណោះដែលបាននិយាយពីភស្តុតាងដែលទាក់ទងផ្ទាល់ទៅនឹងមន្ទីរសន្តិសុខភ្នំក្រោល ។ រីឯសាក្សីចំនួន៤នាក់ទៀតបានផ្តល់ព័ត៌មានទាក់ទងទៅនឹងតំបន់១០៥ ប៉ុន្តែមិនបាននិយាយជាប់ទាក់ទងទៅនឹងមន្ទីរសន្តិសុខទេ ហើយក៏ជាប់ទាក់ទងជាមួយករណីនេះដែរ ។ មានសាក្សីម្នាក់ប៉ុណ្ណោះដែលធ្លាប់នៅមន្ទីរ ក-១៧ ដូចនេះពត៌មានដែលសហព្រះរាជអាជ្ញាទទួលបានគឺត្រឹមតែអគារនោះប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញាព្យាយាមពង្រីកនិយមន័យរបស់មន្ទីរសន្តិសុខភ្នំក្រោលឲ្យកាន់តែធំ ដោយប្រៀបធៀបជាមួយទីតាំងផ្សេងៗ ។ សាក្សីដែលមិនធ្លាប់ឃុំខ្លួននៅជិតមន្ទីរសន្តិសុខភ្នំក្រោល ដូច្នេះសហព្រះរាជអាជ្ញាព្យាយាមនិយាយសង្ខេបនៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនថា មន្ទីរភ្នំក្រោលនោះមានអាគារជាច្រើន រួមជាមួយនឹងអគារដែលសាក្សីត្រូវបានគេឃុំខ្លួនជំនួសឲ្យការស្នាក់នៅក្នុងដីការបញ្ជូនរឿងឲ្យស៊ើបសួរ ។ សហព្រះរាជអាជ្ញាមិនអាចពង្រីកនិយមដូចទៅនឹងការចង់បានរបស់ខ្លួនឡើយ ខណៈដែលភ័ស្តុតាងនៅក្នុងដៃនៅមានភាពខ្វះខាត ។ អង្គជំនុំត្រូវតែច្រានចោលនូវរាល់ភ័ស្តុតាងទាំងអស់ដែរមិនមានទំនាក់ទំនងជាមួយនឹងអគារទាំង៣នោះ ។ បន្ថែមលើនេះ សាក្សីពីររូបដែរបានផ្តល់សក្ខីកម្មហាក់បីដូចជាមើលស្រាលរឿងក្តីនេះណាស់ព្រោះការអះអាងរបស់អ្នកទាំងនេះមានអត្ថន័យខុសពីការពិត ទាក់ទងការចោទប្រកាន់ពីមន្ទីរសន្តិសុខភ្នំក្រោល ។

សាក្សីទាំងនេះបាននិយាយអំពីមូលហេតុនៃការចាប់ខ្លួនរបស់ពួកគេដោយសារពួកគេមានទំនាក់ទំនងទៅនឹងប្រធានមន្ទីរពាណិជ្ជកម្ម ក-១៦ ដែលត្រូវបានសង្ស័យថាជាជនក្បត់ ហើយបានរកឃើញថាស្លាប់នៅភ្នំពេញ ។ បន្ទាប់ពីនេះ មានមនុស្ស១៧នាក់ផ្សេងទៀត បានគេចខ្លួនទៅប្រទេសវៀតណាមដោយមិនដឹងពីមូលហេតុ ។ ព្រឹត្តិការណ៍ទាំងពីររួមបញ្ចូលជាមួយជម្លោះប្រដាប់អាវុធជាមួយ ឬប្រទេសវៀតណាមបានធ្វើឲ្យស្ថានការណ៍ប្រែជាច្របូកច្របល់នៅក្នុងតំបន់នេះ ដូច្នេះកម្មាភិបាល និងយោធានៅក្នុងតំបន់ត្រូវតែបញ្ចេញសកម្មភាពដើម្បីបង្ក្រាបហេតុការណ៍នេះ ។ សាក្សីទាំងពីរបានអះអាងថា ខ្លួនត្រូវបានដោះលែងបន្ទាប់ពីត្រូវបានគេឃុំខ្លួនរយៈពេលមួយខែ ហើយខ្លួនត្រូវបានគេឃ្លាំមើលរហូតដល់រឿងរ៉ាវស្ងប់ទៅវិញ ។ សាក្សីទាំងពីរនេះមិនត្រូវបានគេធ្វើទារុណកម្មនោះទេ ។ សរុបមក មិនមានសាក្សីណាម្នាក់ឃើញគេសម្លាប់ ឬធ្វើទារុណកម្មអ្នកទោសនៅមន្ទីរសន្តិសុខភ្នំក្រោលទេ ។

**វ៉ានិត អារី**

# យុត្តិធម៌អន្តរកាល និងសុខភាពផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជា


***សេចក្តីសង្ខេប***

អត្ថបទនេះព្យាយាមបង្ហាញថា ការវិនិយោគលើការថែទាំសុខភាពផ្លូវចិត្តគឺជាជំហានសំខាន់មួយនៅក្នុងដំណើរយុត្តិធម៌អន្តរកាលរបស់ប្រទេសកម្ពុជា ។ វាជាការវាយតម្លៃផលប៉ះពាល់ផ្លូវចិត្តក្នុងរបបខ្មែរក្រហមទៅលើប្រជាជនកម្ពុជា ហើយបង្ហាញពីភាពមិនមានប្រសិទ្ធភាពនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ក្នុងការកែលម្អផលប៉ះពាល់ដែលបានបង្កឡើង ។ វាជាគំរូក្នុងការគាំទ្រដល់ការស្តារឡើងវិញយុត្តិធម៌អន្តរកាលវប្បធម៌ដែលមានមូលដ្ឋានលើសិទ្ធិ ត្រូវបានបង្កើតឡើងដើម្បីឲ្យមានស្តង់ដារថែរក្សាសុខភាពផ្លូវចិត្តខ្ពស់បំផុតសម្រាប់ប្រជាជនកម្ពុជា ។ អត្ថបទនេះវិភាគពីដំណើរការអន្តរកាលរបស់ប្រទេសកម្ពុជាក្នុងពេលដ៏សំខាន់ ការជំនុំជម្រះចុងក្រោយនៅ (អ.វ.ត.ក) ទើបតែបញ្ចប់ ប៉ុន្តែការផ្លាស់ប្តូររបស់កម្ពុជាមិនមានទេ ។ សហគមន៍អន្តរជាតិ និងរដ្ឋាភិបាលកម្ពុជាត្រូវតែបន្តការវិនិយោគរបស់ខ្លួនក្នុងការស្តារវិស័យសុខភាពផ្លូវចិត្តឲ្យបានប្រសើរឡើងសម្រាប់ប្រទេសក្រោយជម្លោះដូចជាកម្ពុជា ហើយក៏ត្រូវធ្វើឲ្យវិស័យនេះក្លាយជាវិស័យអាទិភាពផងដែរ ។ ដើម្បីជួយដល់កិច្ចការនេះ បទសម្ភាសន៍ដែលរៀបចំដោយអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្ត




ប្រជាជនទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

កម្ពុជាត្រូវបានអនុវត្ត និងប្រើប្រាស់ជាមួយនឹងការវិភាគទៅលើប្រភពឯកសារបន្ទាប់បន្សំដើម្បីកំណត់ពីបញ្ហាសំខាន់ៗក្នុងការផ្ដល់សេវាថែទាំសុខភាពផ្លូវចិត្តនៅកម្ពុជា និងដើម្បីណែនាំពីដំណោះស្រាយ ។

## សេចក្ដីផ្ដើម

ការគ្រប់គ្រងរបស់ខ្មែរក្រហមលើរបបកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ បានបណ្ដាលឲ្យប្រជាជនប្រមាណ ២លាននាក់ស្លាប់បាត់បង់ជីវិត ។ របួសផ្លូវចិត្តបានដិតដាមទៅលើអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជាកេរដំណែលដ៏យូរអង្វែងបន្សល់ពីរបបនេះ ។ ការប៉ះទង្គិចបន្ទាប់ពីការលុកលុយរបស់វៀតណាម នៅឆ្នាំ១៩៧៩ មានន័យថា យុត្តិធម៌សម្រាប់ទសវត្សរ៍នេះត្រូវបានគេដឹងតិច ។ ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ក្នុងឆ្នាំ២០០៦ គឺជាការខិតខំប្រឹងប្រែងប្រកបដោយអត្ថន័យដំបូងបំផុតសម្រាប់យុត្តិធម៌ ។ វាត្រូវបានអះអាងថាយុត្តិធម៌សម្រាប់ប្រទេសកម្ពុជាមិនទាន់ពេញលេញទេ រហូតទាល់តែសុខុមាលភាពផ្នែកចិត្តសាស្ត្ររបស់ប្រទេសនេះត្រូវបានស្ដារឡើងវិញ ប៉ុន្តែសុខភាពផ្លូវចិត្តគឺជាធាតុមួយនៃដំណើរយុត្តិធម៌អន្តរកាលរបស់កម្ពុជានាពេលបច្ចុប្បន្ន ។ ខណៈដែលសំណេរនេះគាំទ្រទស្សនៈថា ផលប៉ះពាល់ផ្លូវចិត្តវិជ្ជមានលើជនរងគ្រោះដែលចូលរួមនៅក្នុង (អ.វ.ត.ក) ក៏មានឥទ្ធិពលអវិជ្ជមានដែរ រួមមានវិធីសាស្ត្រនៃការចូលរួមត្រូវបានដាក់បញ្ចូលគ្នាជាមួយនឹងការខ្វះខាតឱកាសសម្រាប់ការគាំទ្រខាងស្មារតីបង្ហាញថាការព្យាបាលរបួសផ្លូវចិត្តគឺ មិនមែនជាក្ដីបារម្ភចម្បងរបស់សាលាក្ដីនោះទេ ។ ដោយមិនគិតពីអត្ថប្រយោជន៍ណាមួយដល់អ្នកចូលរួមដោយផ្ទាល់ពីដំណើរការរបស់ (អ.វ.ត.ក) នោះត្រូវការធ្វើការងារច្រើនថែមទៀតដើម្បីគាំទ្រដល់ប្រទេសកម្ពុជាទាំងមូល ។ អត្ថបទនេះបានអះអាងថា (អ.វ.ត.ក) ត្រូវបានគេចាត់ទុកថា ជាជំហានទីមួយនៃដំណើរការយុត្តិធម៌អន្តរកាលនៃប្រទេសកម្ពុជា ជំហានទីពីរ គឺការអនុវត្តវិធានការស្ដារឡើងវិញយុត្តិធម៌ដែលនឹងផ្ដល់ការព្យាបាលផ្លូវចិត្តដល់ប្រទេសកម្ពុជា ។ ការស្ដារយុត្តិធម៌ឡើងវិញនៅក្នុងបរិបទនេះគឺការបង្កើតនូវវប្បធម៌ការពារសិទ្ធិមនុស្សដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិទទួលបានសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់កម្ពុជាក្នុងការសម្រេចឲ្យបាននូវស្តង់ដារសុខភាពដែលត្រូវតែផ្ដល់ជូនប្រជាពលរដ្ឋ ។ អាស្រ័យហេតុនេះផ្នែកចុងបញ្ចប់នៃអត្ថបទនេះ នឹងពិនិត្យមើលពីការថែទាំសុខភាពផ្លូវចិត្តនៅកម្ពុជា និងជាមធ្យោបាយដើម្បីកែលម្អ ។

## ផ្នែកទី១ ផលប៉ះពាល់ផ្លូវចិត្តក្នុងរបបខ្មែរក្រហមវិធីសាស្ត្រនៃការបំផ្លាញផ្លូវចិត្ត

ទុកមិនចំណេញ ដកចេញក៏មិនខាត នេះគឺជាទ្រឹស្ដីដែលបានកំណត់ទំនាក់ទំនងរវាងអង្គការក្នុងរបបខ្មែរក្រហម និងប្រជាជនរបស់ខ្លួន ។ លោក អ៊ីណាស្ស ម៉ាទីន បារ៉ូ បានឲ្យហេតុផលថា ផលវិបាកនៃការគាបសង្កត់ខាងនយោបាយគឺថា “រចនាសម្ព័ន្ធសង្គម និងស្ថាប័ន ត្រូវបានប៉ះពាល់ ហើយបទដ្ឋានគុណតម្លៃ និងគោលការណ៍ត្រូវបានបំផ្លាញ” ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមែនជាផលវិបាកនៃការគៀបសង្កត់ទេ ប៉ុន្តែចេតនាច្បាស់លាស់មួយ គឺការប្រែក្លាយប្រទេសកម្ពុជាទៅឆ្នាំសូន្យ ។ រចនាសម្ព័ន្ធគ្រួសារប្រពៃណីត្រូវបានលុបបំបាត់ ដោយការរស់នៅបែបសហករណ៍ ហើយវប្បធម៌កម្ពុជារួមទាំងព្រះពុទ្ធសាសនាត្រូវបានបំផ្លិចបំផ្លាញ ។ ការបង្ខំឲ្យធ្វើការ ការធ្វើទារុណកម្ម និងការសម្លាប់បានចាប់ផ្ដើមភ្លាមៗ ហើយក្ដីស្រមៃបង្កើតកន្លែងមួយឲ្យទៅជាការពិត ដូចដែលលោក ប្រ៊ែនដុន ហាមប័រ បានពិពណ៌នាថា ជា


ខៀវ សំផន នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ពិភពលោកមួយ “ដែលគ្មានសុវត្ថិភាព និងជាខ្សែបន្ទាត់រវាងការស្លាប់ និងការឈឺចាប់យ៉ាងខ្លាំង ហើយការរស់នៅបែបសាមញ្ញ គឺ

ត្រូវបានបំបាត់ចោល» ។

## វិសាលភាពនៃការរងរបួសផ្លូវចិត្ត

ការប្រែក្លាយកម្ពុជាទៅជាឆ្នាំសូន្យបានធ្វើឲ្យរបួសផ្លូវចិត្តប្រជាជនមានលក្ខណៈពីរយ៉ាង

១) សម្រាប់បុគ្គលម្នាក់ៗ ជាការប៉ះពាល់ដោយផ្ទាល់ដោយសារជំងឺធ្លាក់ទឹកចិត្ត ទាំងការប៉ះទង្គិចផ្លូវកាយ និងផ្លូវចិត្ត ។

២) សម្រាប់សង្គមទាំងមូល តាមរយៈការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសុខភាព និងការបំផ្លាញការអប់រំរបស់ប្រទេសទាំងមូល ។

ទីមួយគឺពិបាកក្នុងការវាយតម្លៃឲ្យច្បាស់ដោយសារតែលក្ខណៈបុគ្គលដែលមានការប៉ះទង្គិចផ្លូវចិត្តដែលអាចផ្ទេរចូលទៅក្នុងសង្គមទាំងមូលយ៉ាងស្ងាត់នៃជំងឺធ្លាក់ទឹកចិត្ត ពីមនុស្សមួយជំនាន់ទៅមួយជំនាន់ទៀត ។ ទោះបីជាយ៉ាងណាក៏ដោយមានការសិក្សាមួយចំនួនបានវាយតម្លៃពីឥទ្ធិពលការប៉ះពាល់ផ្លូវចិត្តក្នុងរបបខ្មែរក្រហមដែរ ។ ភាពស្មុគស្មាញជំងឺធ្លាក់ទឹកចិត្តដែលបានរកឃើញដោយ សូនីស និងសហការីរបស់គាត់បង្ហាញថា ១១.២ ភាគរយ នៃប្រជាជនដែលរស់នៅក្នុងប្រទេសកម្ពុជាមានជំងឺបាក់ស្បាត ទោះបីយ៉ាងណាលោក ដេ ជុង រកឃើញថា អត្រានៃជំងឺបាក់ស្បាតមាន ២៨.៤ភាគរយ នៅក្នុងគំរូចៃដន្យដែលបានមកពីសហគមន៍មួយក្នុងប្រទេសកម្ពុជា ។ ជំងឺបាក់ស្បាតនៅក្នុងប្រទេសកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយជំងឺផ្លូវចិត្ត (៤០.២ ភាគរយ) ។ លើសពីនេះទៅទៀត លោក ស្តេមមែល និងមិត្តរួមការងាររបស់គាត់បានរកឃើញថា ១៤.៣ភាគរយ ក្នុងចំណោមមនុស្ស៧៧៥នាក់ ក្នុងគំរូចៃដន្យបានបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ប្រភេទជំងឺ ជំងឺទុក្ខព្រួយរយៈពេលយូរ (PGD) ជំងឺធ្លាក់ទឹកចិត្ត (៣១.៧ភាគរយ) ជំងឺថប់បារម្ភ (៣៨.៧ភាគរយ) និងជំងឺបាក់ស្បាត (PTSD) (១១.២ភាគរយ) ។ ផលប៉ះពាល់ផ្លូវចិត្តក្នុងរបបខ្មែរក្រហមមិនអាចយល់ដឹងបានគ្រប់ជ្រុងជ្រោយ និងលក្ខណៈដោយគ្រាន់តែជាការលើកឡើងដោយអ្នកចិត្តសាស្រ្តលោកខាងលិចនោះទេ ។ វប្បធម៌ខ្មែរមានលក្ខណៈវិនិច្ឆ័យខុសពីលោកខាងលិចទាំងជំងឺចិត្តសាស្រ្ត និងមូលហេតុដែលបណ្តាលឲ្យទទួលការប៉ះពាល់ផ្លូវចិត្ត ។ លោក ដេវីដ ផេនជីសិន បានលើកឡើងថា គំរូនៃជំងឺបាក់ស្បាត មិនអាចចាប់យកវិធីស្មុគស្មាញដែលបុគ្គលម្នាក់ៗ សហគមន៍ និងក្រុមមនុស្សជាច្រើនដែលមានបទពិសោធន៍ជាមួយជំងឺបាក់ធ្ងន់ធ្ងរនោះទេ ។ ទាំងនេះគឺស្របគ្នានឹងការអះអាងរបស់លោក អែសិនប្រាច ដែលថា អ្នកត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានជំងឺបាក់ស្បាត ហើយនៅក្នុងប្រទេសកម្ពុជាអាចត្រូវបានគេយល់កាន់តែច្បាស់ថាជា «ជាការបាត់បង់យ៉ាងធំធេង» ។ ការសុបិន្តឃើញខ្មោចលងជាញឹកញាប់ អាចត្រូវបានគេដឹងថាជាលទ្ធផលនៃការរំខានខាងវិញ្ញាណរវាងមនុស្សនៅរស់និងមនុស្សស្លាប់ ហើយមានជំនឿថាអ្នកដែលបានស្លាប់ដោយសារអំពើហិង្សា ប្រហែលជាមិនអាចរកសន្តិភាពបានទេលុះត្រាតែមានពិធីបុណ្យសមស្របតាមបែបប្រពៃណីសាសនាត្រូវបានអនុវត្ត ។ វេជ្ជបណ្ឌិត ឈឹម សុធារ៉ា បានអះអាងថា គោលគំនិតរបស់អ្នកមានជំងឺបាក់ស្បាត (មិនមានភាពក្លាហាន) ត្រូវបានគេព្រងើយកន្តើយ ។ រោគសញ្ញាទាំងនោះរួមមានការមិនទុកចិត្តលើអ្នកដទៃ និងអារម្មណ៍ភ័យខ្លាច ។ ដូចគ្នានេះដែរ លោក ម៉ូលីកា និងសហការីរបស់គាត់បានកំណត់ពីស្ថានភាពសុខភាពផ្លូវចិត្តរបស់ប្រជាជនកម្ពុជា ដូចជា ជំនឿអរូបិយ ទារុណកម្ម និងព្រួយចិត្ត ។

ការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសុខភាពរបស់ប្រជាជនកម្ពុជា និងការសម្លាប់រង្គាលអ្នកចេះដឹង គឺមិនពិបាកក្នុងការវាយតម្លៃទេ ។ ខ្មែរក្រហមគ្មានការអាណិតអាសូរប្រជាជន ខ្មែរក្រហមខិតខំប្រឹងប្រែងក្នុងការងារកសិកម្មសង្គមនិយម និងបានសម្លាប់អ្នកប្រាជ្ញ បញ្ញវន្តរបស់កម្ពុជា រួមមាន គ្រូពេទ្យ និងអ្នកអប់រំដែលខ្មែរក្រហមយល់ថា ជាសត្រូវរបស់ខ្លួន ។ សង្គ្រាមស៊ីវិលក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការងារស្តារហេដ្ឋារចនាសម្ព័ន្ធសុខភាពផ្លូវចិត្តរបស់ប្រទេសកម្ពុជា ដែលមិនបានកសាងឡើងវិញរហូតដល់ឆ្នាំ១៩៨៨ ហើយអវត្តមាននៃថ្នាក់រៀនដែលមានការអប់រំ បានបន្ទាយពេលយ៉ាងយូរ ។ ផលប៉ះពាល់នៃការបំផ្លិចបំផ្លាញរបស់ខ្មែរក្រហមលើហេដ្ឋារចនាសម្ព័ន្ធសុខភាពផ្លូវចិត្តរបស់ប្រទេសកម្ពុជានឹងត្រូវបានលើកមកពិភាក្សានៅក្នុងផ្នែកទីបី ។

## ផ្នែកទី២ យុត្តិធម៌អន្តរកាល និងសុខភាពផ្លូវចិត្ត

ការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសុខភាពផ្លូវចិត្តរបស់

ប្រទេសកម្ពុជា និងការរីករាលដាលនៃជំងឺផ្លូវចិត្តទាក់ទងនឹងរបបខ្មែរក្រហម ទាំងផ្នែកវេជ្ជវិកលចរិត និងផ្លូវចិត្ត ដែលមានន័យថា យុត្តិធម៌សម្រាប់ប្រជាជនកម្ពុជាមិនបានពេញលេញទេរហូតទាល់តែសុខុមាលភាពផ្លូវចិត្តរបស់ប្រជាជនត្រូវបានស្តារឡើងវិញ ។ ផ្នែកនេះមានគោលបំណងបី៖

១) វិភាគពីប្រសិទ្ធភាពរបស់ អ.វ.ត.ក ក្នុងការធ្វើឲ្យជាសះស្បើយជំងឺផ្លូវចិត្តនៅកម្ពុជា

២) បង្ហាញថាសុខភាពផ្លូវចិត្តគឺជាធាតុមួយនៃដំណើរការអន្តរកាលរបស់ប្រទេសកម្ពុជា

៣) ការបង្កើតឲ្យមានការផ្សះផ្សាឡើងវិញរវាងជនរងគ្រោះ និងជនដៃដល់ និងសហគមន៍ដែលត្រូវបានបំផ្លាញដោយបទឧក្រិដ្ឋណាមួយត្រូវបានគេយល់ថាជាការបង្កើត «វប្បធម៌ផ្អែកលើសិទ្ធិ» ដែលត្រូវបានប្រើដើម្បីកែលម្អរបួសផ្លូវចិត្តរបស់ប្រជាជនកម្ពុជា ។

## ប្រសិទ្ធភាពរបស់ អ.វ.ត.ក ក្នុងការព្យាបាលរបួសផ្លូវចិត្ត

អ.វ.ត.ក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលត្រូវទទួលខុសត្រូវចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ វាមានលក្ខណៈពិសេសក្នុងចំណោមតុលាការឧក្រិដ្ឋកម្មសង្គ្រាមដែលមានសមត្ថភាពកាន់តែប្រសើរសម្រាប់ការចូលរួមរបស់ជនរងគ្រោះ ។ ជនរងគ្រោះអាចត្រូវបានហៅឲ្យមកធ្វើជាសាក្សី ដាក់ពាក្យសុំជាដើមបណ្តឹង ឬប្រសិនបើជនរងគ្រោះទាំងនេះអាចបង្ហាញថាខ្លួនបានប៉ះពាល់ដោយផ្ទាល់ពីរបបនេះ អាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធី ។ គោលបំណងនៃការបង្កើនការចូលរួមរបស់ជនរងគ្រោះ គឺដើម្បីលើកកម្ពស់សិទ្ធិជនរងគ្រោះ និងការធ្វើឲ្យសះស្បើយផ្លូវចិត្ត ។ ទោះជាយ៉ាងណាក៏ដោយលោក ម៉ូហាន បានអះអាងថា អត្ថប្រយោជន៍នៃការចូលរួមរបស់ជនរងគ្រោះភាគច្រើនមិនត្រូវបានបង្ហាញដោយភ័ស្តុតាងជាក់ស្តែង រួមជាមួយការអះអាងដទៃទៀតថាបទពិសោធន៍នេះ ធ្វើឲ្យមានគ្រោះថ្នាក់ច្រើនជាងផលល្អ ។ ពាក្យបណ្តឹងទាំងនេះត្រូវបានប្រកាសថា នឹងត្រូវបានវាយតម្លៃ ។ ការធ្វើសក្ខីកម្មនៅក្នុងបទឧក្រិដ្ឋកម្មសង្គ្រាម គឺជាការពិបាកដែលមិនអាចប្រកែកបាន ហើយអាចជាបទពិសោធន៍ប៉ះពាល់ផ្លូវចិត្តផងដែរ ។ អ្នកចូលរួមក្នុងការជំនុំជម្រះ ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណីមានអត្រាខ្ពស់ជាងមុននៃជំងឺបាក់ស្បាតច្រើនជាងប្រជាជនកម្ពុជាដែលមិនបានចូលរួមក្នុងតុលាការ ។ ការកើនឡើងប្រហែលជាបណ្តាលមកពីអង្គជំនុំជម្រះដជីកសួរពីការឈឺចាប់របស់ជនរងគ្រោះទាំងនោះ ។ ភាពតានតឹងបណ្តាលមកពីផលប៉ះពាល់ផ្លូវចិត្តដល់ការយល់ដឹង និងការចងចាំធ្វើឲ្យវាកាន់តែលំបាកក្នុងការរក្សាការរៀបរាប់ក្នុងអំឡុងពេលផ្តល់សក្ខីកម្ម និងផ្តោតលើសំណួរវែង និងស្មុគស្មាញ ។ បញ្ហានេះកាន់តែយ៉ាប់យ៉ឺនដោយការបង្ហាញឲ្យឃើញអ្នកដែលថ្លែងតបទៅនឹងការសួរដេញដោលយ៉ាងហ្មត់ចត់ ។ បទពិសោធន៍នៃកសិណសាក្សីដែលឆ្លុះបញ្ចាំងពីសក្តានុពល ត្រូវបានកាត់បន្ថយដោយសារតែការបញ្ជាក់ពីអ្វីដែលស្របច្បាប់ និងនៅក្នុងនីតិវិធីតុលាការ និងភ័ស្តុតាង ។ ទោះជាយ៉ាងណា ការលំបាកទាំងនេះមិនមានន័យថា ការចូលរួមកិច្ចដំណើរការនីតិវិធីមិនមែនជាអត្ថប្រយោជន៍ផ្នែកចិត្តសាស្ត្រនោះទេ ។ ការចង្អុលបង្ហាញយ៉ាងច្បាស់បំផុតនៃការផ្តល់សក្ខីកម្មគឺជាបទពិសោធន៍វិជ្ជមានមួយដែលដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើននៅក្នុងសំណុំរឿង០០១ ត្រូវបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ។ បញ្ហាប្រឈមក្នុងការឆ្លើយតបទៅនឹងការលំបាកក្នុងការផ្តល់សក្ខីកម្មគឺជាការផ្តល់អាទិភាពដល់អ្នកចូលរួមជាច្រើន ហើយមនុស្សជាច្រើនមានអារម្មណ៍ល្អក្នុងការនិយាយពីអតីតកាលរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយលោកវេជ្ជបណ្ឌិត ឈឹម សុធារ៉ា បានកត់សម្គាល់ថា ខណៈពេលដែលកូនក្តីមួយចំនួនរបស់គាត់បានរាយការណ៍ពីការជាសះស្បើយបន្ទាប់ពីផ្តល់សក្ខីកម្ម មានអ្នកជំងឺភាគច្រើនមានអារម្មណ៍ឈឺចាប់ឡើងវិញ ។ ដូច្នេះអាចនិយាយបានថា ទោះបីជាមានការលំបាក អ.វ.ត.ក មានប្រសិទ្ធភាពផ្លូវចិត្តវិជ្ជមានទៅលើអ្នកចូលរួមមួយចំនួន ។

## ប្រសិទ្ធភាពរបស់ អ.វ.ត.ក នៅទូទាំងប្រទេសកម្ពុជា

ភាពជោគជ័យរបស់ អ.វ.ត.ក មិនអាចត្រូវបានវាស់វែងតែលើឥទ្ធិពលរបស់ខ្លួនទៅលើអ្នកចូលរួមដោយផ្ទាល់ក្នុងការជំនុំជម្រះឡើយ តែជាចំណែកនៃជនរងគ្រោះពីរបបខ្មែរក្រហមទាំងអស់ ។ សមត្ថភាពរបស់ អ.វ.ត.ក ដើម្បីព្យាបាលរបួសផ្លូវចិត្ត

របស់ជនរងគ្រោះទាំងអស់ពីរបបខ្មែរក្រហមត្រូវបានវាយតម្លៃ ។ នេះមិនមែនជាកិច្ចការតូចតាចទេ ។ ការសិក្សានៅឆ្នាំ២០០៨ បានរកឃើញថា ប្រជាជនកម្ពុជាជាង៨០ភាគរយ ចាត់ទុកខ្លួនគេជាជនរងគ្រោះនៃរបបខ្មែរក្រហម ទោះបីយ៉ាងណាមាន៦៩ភាគរយប៉ុណ្ណោះ នៃអ្នកដែលបានស្ទង់មតិរស់រានមានជីវិតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសិក្សាស្រាវជ្រាវដែលគាំទ្រយុត្តិធម៌បានលើកឡើងថា តុលាការអាចជួយកាត់បន្ថយរោគសញ្ញាជំងឺផ្លូវចិត្តរបស់ជនរងគ្រោះទាំងអស់ មិនត្រឹមតែអ្នកដែលបានចូលរួមក្នុងការជំនុំជម្រះប៉ុណ្ណោះទេ ។ ការលើកឡើងនេះមិនអាចទៅរួចទេ ។ សូនីស និងមិត្តរួមការងាររបស់គាត់បានរកឃើញថា មានការទាក់ទងកំហឹង និងបំណងប្រាថ្នាដ៏ខ្លាំងក្លាចំពោះការសងសឹកជាមួយជំងឺបាក់ស្បាត ។ លើសពីនេះទៀត អ្នកសិក្សាទាំងនេះបានរកឃើញថា ការយល់ដឹងខ្ពស់ពីយុត្តិធម៌ មានអត្រាថយចុះនៃជំងឺបាក់ស្បាត ។ នេះនឹងបង្ហាញថា ការកាត់ទោសនៅ អ.វ.ត.ក មានសមត្ថភាពព្យាបាលជនរងគ្រោះពីរបបខ្មែរក្រហមដែលមិនចូលរួម ក្នុងករណីនេះប្រសិនបើជនរងគ្រោះទាំងនោះយល់ថា សវនាការនេះមានភាពយុត្តិធម៌ ។ នេះដូចជាមិនទំនងសម្រាប់ហេតុផលដែលបានលើកឡើងខាងលើទេ ។ ដំបូងទោះបីជាមានការខិតខំប្រឹងប្រែងផ្សព្វផ្សាយបន្តដល់សហគមន៍ តាមរយៈអង្គការនានា ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការចិត្តសង្គមអន្តរវប្បធម៌ *(TPO)* ប្រជាជនកម្ពុជាទូទៅមានការយល់ដឹងតិចតួចអំពី អ.វ.ត.ក ។ ការសិក្សាធំបំផុតនៃចំណេះដឹង និងការយល់ដឹងរបស់ប្រជាជនកម្ពុជាអំពីសាលាក្តីនេះត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យកាលីហ្វ័រញ៉ា ដែលជាកម្មវិធីសិក្សា *Berkley* ។ តាមការសិក្សាបានរកឃើញថា នៅឆ្នាំ២០០៨ អ្នកឆ្លើយតបចំនួន៣៩ភាគរយ ពុំមានចំណេះដឹងអំពី អវតក ទេ ហើយ៤៦ភាគរយ មានចំណេះដឹងតិចតួចប៉ុណ្ណោះ ។ ការសិក្សា *Berkley* លើកទី២ ក្នុងឆ្នាំ២០១០ បានរកឃើញថា ខណៈដែលការយល់ដឹង និងចំណេះដឹងរបស់ អវតក បានកើនឡើងបន្តិចក្នុងរយៈពេលពីរឆ្នាំបណ្តោះអាសន្ន ការចាប់អារម្មណ៍លើសាលាក្តីមានការថយចុះ ។ ការគាំទ្ររបស់សាលាក្តីខ្មែរក្រហមពិតជាបានថយចុះបន្ទាប់ពីមានការកាត់ទោស ឌុច ដែលជាប្រធានគុកស-២១ ដ៏ល្បី និងជាប់ទាក់ទងក្នុងសំណុំរឿង០០១ ដែលបង្ហាញពីការមិនពេញចិត្តនឹងដំណើរការរបស់សាលាក្តី ។ ជាអកុសលមិនមានការសិក្សាផ្អែកលើប្រជាជនដែលត្រូវបានធ្វើឡើងចាប់តាំងពីការផ្តន្ទាទោស ខៀវ សំផន និង នួន ជា ឲ្យជាប់គុកអស់មួយជីវិត នៅក្នុងឆ្នាំ២០១៤ ទេ ។ លោក អាបេ បានស្នើសុំការសម្រុះសម្រួលរបស់តុលាការជាមួយអង្គការសហប្រជាជាតិដែលបានគាំទ្រខ្មែរក្រហមនៅទសវត្សរ៍ឆ្នាំ១៩៨០ ដែលជាហេតុផលមួយដែលប្រជាជនកម្ពុជាមិនទុកចិត្តលើ អវតក ។ លោកក៏បានស្នើផងដែរថា ការកាត់ក្តីមិនអាចកាត់ទោសមហាអំណាចពិភពលោកដែលបានគាំទ្រដល់ខ្មែរក្រហម សហរដ្ឋអាមេរិក និងចិន ឬកម្មាភិបាលខ្មែរក្រហមពីថ្នាក់ទាបរហូតដល់ថ្នាក់ខ្ពស់ គឺជាហេតុផលមួយទៀតនៃភាពព្រងើយកន្តើយចំពោះ អវតក ។ ការរួមបញ្ចូលគ្នានៃកង្វះការយល់ដឹង និងការព្រងើយកន្តើយចំពោះសាលាក្តីខ្មែរក្រហមមិនអាចមានន័យថា "អារម្មណ៍យុត្តិធម៌" ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាដែលប្រឆាំងនឹងលទ្ធភាពដែលថា ការកាត់ក្តីបានជួយដល់ប្រជាជនកម្ពុជាដែលរងទុក្ខវេទនាផ្លូវចិត្តជាទូទៅនោះទេ ។

## សុខភាពផ្លូវចិត្ត៖ ធាតុផ្សំនៃដំណើរការអន្តរកាលរបស់ប្រទេសកម្ពុជា

ការព្យាបាលផ្លូវចិត្តមិនត្រូវបានព្យាបាលដោយសហគមន៍អន្តរជាតិ ឬរដ្ឋាភិបាលកម្ពុជាទេ ដែលជាធាតុដ៏សំខាន់នៃដំណើរការយុត្តិធម៌អន្តរកាលរបស់ប្រទេសកម្ពុជា ។ ទាំងនេះបានបង្ហាញឲ្យឃើញភាពបរាជ័យខាងថវិការបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីបង្វែរធនធានទៅនឹងសេវាកម្មគាំទ្រផ្នែកចិត្តសាស្ត្រ និងការបដិសេធរបស់ អវតក ទទួលយកការផ្តល់ការបណ្តុះបណ្តាលផ្នែកចិត្តសាស្ត្រដល់ចៅក្រម និងបុគ្គលិករបស់ខ្លួន ។ ការយកចិត្តទុកដាក់តូចចង្អៀតនៃសាលាក្តីនេះ គឺមិនសមហេតុផលទេ នៅពេលយល់ថា ការកាត់ទោសមេដឹកនាំដែលនៅរស់រានមានជីវិតក៏មិនអាចឲ្យអ្នកស្លាប់រស់ឡើងវិញ ហើយគួរតែយកចិត្តទុកដាក់ជួយអ្នកដែលនៅរស់រានមានជីវិតវិញ ។ គម្រោងការចូលរួមរបស់ជនរងគ្រោះដែលត្រូវបានគេប្រកាសជាច្រើនលើកមិនមែនជាជ័យជម្នះនៃការចរចារយៈពេលវែងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ (១៩៩៧-២០០៣)

នោះទេ ប៉ុន្តែត្រូវបានគេណែនាំដោយអយុត្តិធម៌នៅក្នុងវិធានផ្ទៃក្នុងឆ្នាំ២០០៧ មួយឆ្នាំបន្ទាប់ពីការបង្កើតតុលាការនេះ ។ ផលវិបាកមិនមែនជាការបង្វែរជំនួយពីថវិកាសម្រាប់ការផ្តល់ជូនជនរងគ្រោះនោះទេ ។ វាជាការងារអង្គការក្រៅរដ្ឋាភិបាលដែលមិនទទួលបានមូលនិធិពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រដល់ជនរងគ្រោះទាំងអស់ ។ ភាពខ្វះខាតទាក់ទងនឹងសុខភាពផ្លូវចិត្តដែលត្រូវបានបាត់បង់នៅក្នុង អវតក ត្រូវបានបង្ហាញជាញឹកញាប់ និងលើសលុបដែលនីតិវិធីតុលាការកាត់បន្ថយសុខុមាលភាពផ្លូវចិត្តរបស់ជនរងគ្រោះ ។ តុលាការបានផ្តល់ភាពរាំងស្ទះដល់ការផ្តល់សក្ខីកម្មរបស់ជនរងគ្រោះ នៅពេលបានបង្ហាញចេញពីអ្វីដែលស្របច្បាប់ ឬនៅពេលដែលជនរងគ្រោះមានអារម្មណ៍រំជួលចិត្តខ្លាំង បើទោះបីជាភ័ស្តុតាង បង្ហាញពីអារម្មណ៍យ៉ាងពុះកញ្ជ្រោលខ្លាំងក្នុងករណីនៃការសងសឹក អាចផ្តល់ការធូរស្រាលផ្លូវចិត្តបាន ។ កត្តានៃការធ្វើឲ្យអារម្មណ៍ធូរស្បើយ និងការផ្តល់សិទ្ធិអំណាចដល់ដំណើរការរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកាត់បន្ថយយ៉ាងច្រើនដោយសេចក្តីសម្រេចរបស់តុលាការក្នុងការដាក់កំហិតការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅឲ្យមេធាវីរបស់ខ្លួន ដូចជា សេង ធារី ដែលជាដើមបណ្តឹងរដ្ឋប្បវេណីដំបូង និងចុងក្រោយ ប្តឹងទៅតុលាការដោយផ្ទាល់ ។ វាត្រូវបានបំផ្លិចបំផ្លាញបន្ថែមទៀតដោយការរួមបញ្ចូលនៃដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងអង្គភាពមួយដែលតំណាងដោយក្រុមអ្នកច្បាប់មួយក្រុមក្នុងសំណុំរឿង០០២ ដោយបដិសេធជនរងគ្រោះ រួមជាមួយការមិនទទួលស្គាល់ការឈឺចាប់របស់បុគ្គលម្នាក់ៗ ។ នេះមិនមែនជាការរិះគន់ហួសហេតុចំពោះ អ.វ.ត.ក ឡើយ ។ ការដាក់បញ្ចូលគ្នានៃដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ចំនួន៣.៨៦៦នាក់ចូលជាអង្គភាពតែមួយ គឺជាការចាំបាច់ដើម្បីផ្តល់នូវភាពងាយស្រួលដល់តុលាការដែលត្រូវបានរិះគន់ជាញឹកញាប់ចំពោះការពន្យារពេលរបស់ខ្លួន ។ ការរក្សាដំណើរការតុលាការគឺចាំបាច់ណាស់ចំពោះសុចរិតភាពរបស់សាលាក្តី ហើយមានគោលបំណងដើរតួជាគំរូសម្រាប់យុត្តិធម៌ប្រកបដោយតម្លាភាព និងការលើកកម្ពស់នីតិរដ្ឋ ។ ទោះបីជាយ៉ាងណាក៏ដោយ ផលវិជ្ជមានទៅលើអ្នកចូលរួមជាច្រើន វាច្បាស់ណាស់ថា ការព្យាបាលរបួសផ្លូវចិត្តមិនមែនជាបញ្ហាបឋមសម្រាប់សាលាក្តី ។ ភាពបរាជ័យរបស់សហគមន៍អន្តរជាតិដើម្បីព្យាបាលសុខភាពផ្លូវចិត្ត គឺជាធាតុផ្សំដ៏សំខាន់នៃការផ្លាស់ប្តូររបស់កម្ពុជា ហើយអាចត្រូវបានពន្យល់ដោយការយល់ច្រឡំនូវសុភាសិតមួយថា “យុត្តិធម៌មិនត្រូវបានទទួលពេញលេញទេ ប៉ុន្តែត្រូវបានគេមើលឃើញថាកំពុងធ្វើ” ។ តាមទ្រឹស្តី យុត្តិធម៌ត្រូវបានគេមើលឃើញថា ត្រូវបានធ្វើឡើងដើម្បីលើកកម្ពស់យុត្តិធម៌ប្រកបដោយតម្លាភាព និងនីតិរដ្ឋនៅក្នុងសង្គមក្រោយជម្លោះ ។ ទោះជាយ៉ាងណាក៏ដោយ លោក ហ៊ូហ្គេស បានអះអាងការពិតមួយថា “អន្តរាគមន៍ផ្នែកច្បាប់” គឺជាដំណោះស្រាយរបស់ម្ចាស់ជំនួយ មិនមែនជាពលរដ្ឋទេ ដែលត្រូវមើលឃើញពីយុត្តិធម៌ដែលបានសម្រេចឡើង ។

ទាំងនេះបានជួយពន្យល់ការរក្សាទុករបស់សហគមន៍អន្តរជាតិដើម្បីទទួលបានធនធាននាពេលខាងមុខដោយមើលឃើញពីធាតុផ្សំនៃយុត្តិធម៌ ការកាត់ទោស និងការផ្តន្ទាទោស និងវត្តមានការវិនិយោគនៅក្នុងសមាសភាពជាក់ស្តែងនៃយុត្តិធម៌ដូចជាការព្យាបាលផ្លូវចិត្ត ។ ទឹកប្រាក់២៥០លានដុល្លារអាមេរិក ត្រូវបានចំណាយលើការផ្តន្ទាទោស ប៉ុន្តែមិនទាន់បានផ្តល់ប្រាក់ដោយឡែកដើម្បីផ្តល់ជាសំណងប្រកបដោយអត្ថន័យដល់ជនរងគ្រោះនោះទេ ។ សេវាសុខភាពផ្លូវចិត្តអាចជាទម្រង់សំណងដ៏ល្អប្រសើរ ។ តាមពិត១៨ភាគរយ នៃដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកដាក់ពាក្យស្នើសុំសេវាសុខភាពផ្លូវចិត្តផ្នែកសំណង ។ ខណៈពេលដែលតុលាការឧក្រិដ្ឋកម្មសង្គ្រាមមានការលំបាកជាសកល វាមិនគ្រប់គ្រាន់ទេក្នុងការទទួលយកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាឧទាហរណ៍មួយទៀតនៃការខ្វះចន្លោះយុត្តិធម៌អន្តរកាល ។ ម្ចាស់ជំនួយអន្តរជាតិ និងរាជរដ្ឋាភិបាលកម្ពុជាត្រូវតែមើលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាជំហានមួយនៃដំណើរការយុត្តិធម៌អន្តរកាលរបស់ប្រទេសកម្ពុជា ។ ជំហានទី២ ត្រូវតែជាការស្តារឡើងវិញនូវ “វប្បធម៌ដែលមានសិទ្ធិមូលដ្ឋាន” ដែលសិទ្ធិទទួលបាន “ស្តង់ដារសុខភាពខ្ពស់បំផុត” ត្រូវបានចែកចាយ ។

**ការស្តារយុត្តិធម៌ឡើងវិញ ៖ ការស្តារឡើងវិញនូវវប្បធម៌ដែលផ្អែកលើសិទ្ធិមូលដ្ឋាន**

ការបង្កើត "វប្បធម៌ដែលមានសិទ្ធិមូលដ្ឋាន" ត្រូវបានបង្កើតឡើងនៅក្នុងគោលការណ៍ស្តារយុត្តិធម៌ឡើងវិញ ។ ការស្តារយុត្តិធម៌ឡើងវិញ ស្វែងរកការជួសជុលផលប៉ះពាល់ដែលបណ្តាលមកពីឧក្រិដ្ឋកម្មជំនួសឲ្យការផ្តោតលើការពិន័យចំពោះការដាក់ទណ្ឌកម្មជនល្មើស ។ ការសម្រុះសម្រួលជនរងគ្រោះ គឺជាមធ្យោបាយបឋមដែលបណ្តាលមកពី "ឧក្រិដ្ឋកម្មធម្មតា" ត្រូវបានប៉ុនប៉ងជួសជុលឡើងវិញ ។ នៅក្នុងសង្គមក្រោយជម្លោះដែលបានស៊ូទ្រាំនូវបទល្មើសឧក្រិដ្ឋកម្មធំធេង វិធីកែទម្រង់យុត្តិធម៌ដើម្បីជួសជុលត្រូវធ្វើឡើងវិញ ។ របបដ៏ភ័យខ្លាចមិនត្រឹមតែធ្វើឲ្យប៉ះពាល់ដល់មនុស្សទេ ប៉ុន្តែដល់រចនាសម្ព័ន្ធសង្គម និងស្ថាប័នគុណតម្លៃ និងគោលការណ៍ផងដែរ ។ ស្តារយុត្តិធម៌ឡើងវិញនៅក្នុងសង្គមក្រោយជម្លោះត្រូវតែយកចិត្តទុកដាក់លើបញ្ហានេះ ។ មានការសិក្សាសារសំខាន់ពីទ្រឹស្តីយុត្តិធម៌ស្តារឡើងវិញ នៅក្នុងបរិបទក្រោយជម្លោះ ។ ប្រធានបទទូទៅមួយគឺតម្រូវការដើម្បីលើកកម្ពស់ការផ្សះផ្សា ។ ការអះអាងមួយថា យុត្តិធម៌ស្តារឡើងវិញត្រូវបានសម្រេចតាមរយៈសកម្មភាពផ្សះផ្សា ។ លោក ណោម ជីមមែល ប្រានចោលការភ្ជាប់ជាមួយនៃការស្តារយុត្តិធម៌ឡើងវិញជាមួយការផ្សះផ្សា ពិសេសទស្សនៈរបស់ជនរងគ្រោះ និងការដាក់សម្ពាធទៅលើជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដើម្បីលើកលែងទោសដល់ជនល្មើស ។ ទស្សនៈខុសគ្នា គឺមិនទាក់ទងទៅនឹងអត្ថបទនេះទេ ព្រោះវាមានការព្រួយបារម្ភចំពោះការលើកកម្ពស់ការព្យាបាលចិត្តសាស្ត្រមិនមែនការផ្សះផ្សាទេ ។ ទោះជាយ៉ាងណាក៏ដោយគំនិតទាំងនោះអាចត្រូវបានផ្សារភ្ជាប់គ្នា ។ ខណៈពេលដែលលោក មុកាសិមា និង ម៉ូឡៅ មិនអាចបង្កើតទំនាក់ទំនងរវាងមូលហេតុនៃការផ្សះផ្សា និងសុខភាពផ្លូវចិត្តនៅប្រទេសរ៉្វាន់ដា "នោះគេបានបង្ហាញពីរង្វង់ទំនាក់ទំនងពីរ" នៅពេលការផ្សះផ្សាចាប់ផ្តើមវាបង្កើនសន្តិសុខ និងធ្វើឲ្យការព្យាបាលមានភាពប្រសើរឡើង ។ នៅពេលការព្យាបាលបានរីកចម្រើន ការផ្សះផ្សាក្លាយជាអ្វីដែលអាចធ្វើទៅបាន ។ ហេតុនេះហើយ ក្រៅពីការព្យាបាលផ្លូវចិត្តដែលជាការខិតខំប្រឹងប្រែងដ៏ត្រឹមត្រូវនៅក្នុងសិទ្ធិរបស់ខ្លួនវាអាចធ្វើឲ្យល្អប្រសើរឡើងនូវទស្សនវិស័យនៃការផ្សះផ្សា ។ អត្ថបទនេះ គាំទ្រដល់ការរៀបចំរបស់លោក ឌិច លីត និង ម៉ាលិក នៃការស្តារយុត្តិធម៌ឡើងវិញដែលជាការបង្កើត "វប្បធម៌ការពារសិទ្ធិមនុស្ស" ។ នេះត្រូវបានគាំទ្រដោយនិយមន័យនៃយុត្តិធម៌ស្តារឡើងវិញរបស់ ជីមមែល ថាជាការផ្តោតលើការការពារសិទ្ធិ និងតម្រូវការរបស់អ្នករស់រានមានជីវិត ។ និយមន័យនេះមានលក្ខខណ្ឌសមស្រប ដែលរបបឃោរឃៅបានផ្តល់ឲ្យ និងដកហូតសិទ្ធិរបស់ប្រជាពលរដ្ឋ ។ និយមន័យនេះគឺជាក់ស្តែងដែលមិនអាចប្រកែកបាន មានការផ្លាស់ប្តូរស្មុគស្មាញជាច្រើនដែលបានកើតឡើងដើម្បីពង្រឹងសិទ្ធិមនុស្ស ការពារវប្បធម៌ ពិសេសក្នុងប្រទេសកម្ពុជាដែលជាញឹកញាប់មានការរំលោភបំពានសិទ្ធិរបស់ប្រជាពលរដ្ឋ ។ ទោះបីជាយ៉ាងណាក៏ដោយសិទ្ធិមិនច្បាស់លាស់មួយដែលត្រូវតែលើកកម្ពស់គឺជាសិទ្ធិរបស់ប្រទេសកម្ពុជាចំពោះស្តង់ដារសុខភាពខ្ពស់បំផុត ដែលរួមបញ្ចូលទាំងសុខុមាលភាពផ្លូវចិត្តដែរ ។ ការវិនិយោគលើផ្នែកសុខភាពផ្លូវចិត្តមិនត្រឹមតែបានជួយព្យាបាលបញ្ហាផ្លូវចិត្តក្នុងរបបខ្មែរក្រហមប៉ុណ្ណោះទេ វាបានជួយដល់ដំណើរការអភិវឌ្ឍប្រទេសកម្ពុជា ។ ផ្នែកចុងក្រោយនៃអត្ថបទនេះ និងធ្វើការវាយតម្លៃ ហេដ្ឋារចនាសម្ព័ន្ធសុខភាពផ្លូវចិត្តនៅកម្ពុជានាពេលបច្ចុប្បន្ន និងវិធីណែនាំដែលអាចត្រូវបានកែលម្អ ។

## ផ្នែកទី៣ ៖ ឆ្ពោះទៅរក "វប្បធម៌ផ្អែកលើសិទ្ធិមូលដ្ឋាន" ការកែលម្អការផ្តល់សេវាថែទាំសុខភាពផ្លូវចិត្តនៅកម្ពុជា

ការស្តារហេដ្ឋារចនាសម្ព័ន្ធសុខភាពផ្លូវចិត្តរបស់ប្រទេសកម្ពុជា គឺជាជំហានសំខាន់មួយឆ្ពោះទៅរកការបង្កើតវប្បធម៌ផ្អែកលើសិទ្ធិមូលដ្ឋាន ។ វាគឺហួសពីវិសាលភាពនៃអត្ថបទនេះដើម្បីពិភាក្សាអំពីសុខភាពដែលជាសិទ្ធិមនុស្សយ៉ាងទូលំទូលាយសម្រាប់ការពិភាក្សាបែបនេះ ការងាររបស់ ម៉ាកឡូលីន និង វីកកឺរី គឺមានតម្លៃមិនអាចកាត់ថ្លៃបាន ។ អត្ថបទនេះជំនួសមកវិញតាមរយៈប្រភពទិន្នន័យ និងបទសម្ភាសន៍ជាមួយអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្តក្នុងប្រទេសកម្ពុជា ។ បានកំណត់បញ្ហា និងស្នើជាដំណោះស្រាយដើម្បីកែលម្អការថែទាំសុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជា ។

### ការបំផ្លាញសុខភាពផ្លូវចិត្ត

ឧបសគ្គចម្បងមួយចំពោះការព្យាបាលសុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជា គឺការរីករាលដាល និងការទោរទន់ទៅរកជំងឺផ្លូវ

ចិត្ត ។ នេះគឺជាបញ្ហាលើកដំបូងដែលលើកឡើងដោយអ្នកដែលចូលរួមសម្ភាសន៍ផ្សេងទៀត ។ ប្រទេសកម្ពុជាត្រូវរងទុក្ខដោយការយល់ឃើញថា បញ្ហាសុខភាពផ្លូវចិត្តមិនអាចដោះស្រាយបាន និងមានភាពស្របច្បាប់ តិចជាងជំងឺរាងកាយដែលនាំឲ្យខូចសុខភាពផ្លូវចិត្តជាអាទិភាពរបស់រដ្ឋាភិបាល ។ ការមាក់ងាយធ្វើឲ្យខូចទឹកចិត្តដល់វេជ្ជបណ្ឌិតកម្ពុជាពីជំនាញផ្នែកចិត្តសាស្ត្រ ពីព្រោះវេជ្ជបណ្ឌិតទាំងនោះត្រូវបានគេចាត់ទុក និងមាក់ងាយដោយសហសេវិករបស់គេដោយជារឿយៗគេហៅថា "គ្រូពេទ្យឆ្កួតៗ" ។ បញ្ហានេះធ្វើឲ្យអ្នកខ្វះជំនាញផ្នែកសុខភាពផ្លូវចិត្តរបស់កម្ពុជាកាន់តែខ្វះខាត ។ មធ្យោបាយដែលបានស្នើឡើងដើម្បីទប់ទល់បញ្ហានេះ គឺតាមរយៈការលើកកម្ពស់ស្មារតីសហគមន៍ ។ នេះត្រូវបានគាំទ្រយ៉ាងខ្លាំងក្លាដោយសាស្ត្រាចារ្យ ការ ស៊ុនប៊ុនណាត អតីតប្រធានផ្នែកចិត្តសាស្ត្រនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងលោកវេជ្ជបណ្ឌិត ឈឹម សុធារ៉ា នាយកប្រតិបត្តិនៃអង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) ។ អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) បានដំណើរការកម្មវិធីព្យាបាលផ្លូវចិត្ត និងកម្មវិធីព្យាបាលសហគមន៍ដ៏ល្អនៅក្នុងភូមិដែលជាទិសដៅ ។ នេះរួមបញ្ចូលទាំងការផ្តល់ការអប់រំ សិក្ខាសាលា ការរៀបចំការព្យាបាលតាមក្រុម និងការបណ្តុះបណ្តាលមេដឹកនាំសហគមន៍នៅក្នុងបច្ចេកទេសប្រឹក្សាជាមូលដ្ឋាន ។ ទោះជាយ៉ាងណាក៏ដោយការអនុវត្តកម្មវិធីតាមសហគមន៍ដោយអង្គការក្រៅរដ្ឋាភិបាលមានភាពមិនទៀងទាត់នៅលើការកម្រទទួលជំនួយហិរញ្ញវត្ថុ ។ អង្គការចិត្តសង្គមអន្តរវប្បធម៌ មានលទ្ធភាពអនុវត្តកម្មវិធីរបស់ខ្លួននៅក្នុងចំនួនភូមិដែលមានកំណត់ ។ ការពង្រីកនិរន្តរភាពនៃកម្មវិធីដ៏សំខាន់ទាំងនេះ អាចត្រូវបានធានាដោយការផ្តល់មូលនិធិពីរដ្ឋាភិបាលកម្ពុជា ។ ការខ្វះការយកចិត្តទុកដាក់លើការរៀបចំកញ្ចប់ថវិកាសម្រាប់សុខភាពផ្លូវចិត្តការប្រកួតប្រជែងដ៏មុះមុតសម្រាប់ជំនួយអន្តរជាតិមានន័យថា រដ្ឋាភិបាលកម្ពុជាត្រូវតែរៀបចំដើម្បីដាក់ទុនក្នុងហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន ។ នៅក្នុងពេលបច្ចុប្បន្ននេះ គឺមិនមានឡើយថវិកាលើសុខភាពផ្លូវចិត្តមានត្រឹមតែ០.០២ភាគរយនៃថវិកាសុខភាពជាតិសរុបតែប៉ុណ្ណោះ ប្រមាណជា៣០ ០០០ ដុល្លារសហរដ្ឋអាមេរិក យោងតាមលោកបណ្ឌិត ចិត្ត សុផល ប្រធានមន្ទីរសុខភាពផ្លូវចិត្ត នឹងមិនអាចធានានិរន្តរភាពបានទេ ។ ទាំងនោះគឺជាលទ្ធផលដែលបង្ហាញយ៉ាងច្បាស់ពីស្លាកស្នាមដែលនៅជុំវិញសុខភាពផ្លូវចិត្តក្នុងប្រទេសកម្ពុជា និងផលវិបាកនៃការមិនឲ្យតម្លៃលើសុខភាពផ្លូវចិត្តថា ជាអទិភាពចម្បងរបស់រដ្ឋាភិបាល ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែបង្វែរអារម្មណ៍មើលការវិនិយោគក្នុងការថែទាំសុខភាពផ្លូវចិត្តជាផលប្រយោជន៍រួម ក្រៅពីកាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិ ។ ការសិក្សាជាច្រើនបានបង្ហាញថា រាល់ថវិកាដែលវិនិយោគលើសុខភាពផ្លូវចិត្តមានប្រមាណពី៦ ទៅ៧ដុល្លារ ។

លើសពីនេះទៅទៀត ការកែលម្អសុខភាពផ្លូវចិត្តបានកាត់បន្ថយជំងឺផ្សេងៗ ដូចជា ជំងឺអេដស៍ និងជំងឺបេះដូង ។ នេះជាព័ត៌មានដែលអាចរកបានសម្រាប់រដ្ឋាភិបាលកម្ពុជា ។ របាយការណ៍ដែលមានឥទ្ធិពលរបស់ ម៉ាកឡូលីន និង វិចកីរី ដែលអត្ថបទនេះពឹងផ្អែកលើបានបោះពុម្ពនៅឆ្នាំ២០១២ ។ អ្នកនិពន្ធបានរៀបចំការសម្ភាសន៍ក្នុងឆ្នាំ២០១៧ ជាមួយអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្តមួយចំនួន រួមមាន សុផល និង ឈឹម សុធារ៉ា ចំណែក៦លទ្ធភាពគ្មានការផ្លាស់ប្តូរក្នុងរយៈពេលប្រាំឆ្នាំក្រោយនេះ ទោះជាដូច្នេះក្តី រដ្ឋាភិបាលកម្ពុជានៅតែមិនបានចាត់ទុកសុខភាពផ្លូវចិត្តជាបញ្ហាចម្បងនៅឡើយ ។ ម្ចាស់ជំនួយអន្តរជាតិគួរតែលើកកម្ពស់ការពឹងផ្អែករបស់កម្ពុជាលើជំនួយអន្តរជាតិសម្រាប់កញ្ចប់ថវិកាផ្នែកសុខភាពដើម្បីទាមទារការវិនិយោគបន្ថែមលើសេវាសុខភាពផ្លូវចិត្ត ។ ជាអកុសល ម្ចាស់ជំនួយមួយចំនួនមិនមានចំណាប់អារម្មណ៍លើការផ្តល់ជំនួយលើសេវាសុខភាពផ្លូវចិត្តនោះទេ គឺគ្រាន់តែជាការបំពេញចិត្តរបស់អ្នកទាំងនោះលើសមាសធាតុនៃយុត្តិធម៌តែប៉ុណ្ណោះ ម្ចាស់ជំនួយផ្នែកសុខភាពចង់បានលទ្ធផលឆាប់រហ័ស និងលទ្ធផលដែលអាចងាយស្រួលកំណត់ ដូចជាការកាត់បន្ថយមេរោគអេដស៍ ហើយមិនមែនលក្ខណៈជាក់ស្តែងតិចតួច និងត្រូវការការវិនិយោគលើការថែរក្សាសុខភាពផ្លូវចិត្តរយៈពេលយូរ ។

### សមាហរណកម្មវប្បធម៌កម្ពុជា និងចិត្តសាស្ត្រលោកខាងលិច

ការខ្វះខាតថវិកាសម្រាប់វិស័យសុខភាពផ្លូវចិត្តមានន័យថា ប្រជាជនកម្ពុជាដែលមានជំងឺផ្លូវចិត្តប្រមាណជា ៨០

ភាគរយមិនបានទទួលការព្យាបាល ។ ចំណែក៦២០ភាគរយដែលទទួលបានការព្យាបាលជាទូទៅគឺមិនមានការថែទាំត្រឹមត្រូវនោះទេ ។ វិធីសាស្ត្រព្យាបាលអាចកែលម្អតាមរយៈសមាហរណកម្មវប្បធម៌កម្ពុជា ពោលគឺព្រះពុទ្ធសាសនាជាមួយនឹងការប្រណិប័តន៍ចិត្តសាស្ត្រលោកខាងលិច ។ សាស្ត្រចារ្យ ការ ស៊ីនប៊ុនណាគ និងវេជ្ជបណ្ឌិត សុធារ៉ា បានលើកឡើងថា នេះមានសារសំខាន់ ដោយសារវប្បធម៌កម្ពុជាមានផលប៉ះពាល់ប្រជាជនដែលមានជំងឺផ្លូវចិត្តដូចដែលមានបង្ហាញនៅក្នុងផ្នែកទីមួយ ។ ចំណុចនេះអាចធ្វើទៅបានដោយសារការចែករំលែកធាតុផ្សំរវាងព្រះពុទ្ធសាសនា និងចិត្តសាស្ត្រលោកខាងលិច ។ ការព្យាបាលដោយការយល់ដឹង (CBT) បានចាត់ទុកថាជាឧបករណ៍ចិត្តសាស្ត្រនៃលោកខាងលិចដែលបានអះអាងដោយសាស្ត្រាចារ្យ ការ ស៊ីនប៊ុនណាគ ថាមានឫសគល់នៅក្នុងព្រះពុទ្ធសាសនា ។ ស្រដៀងគ្នានេះដែរ ការប្រណិប័តន៍ព្រះពុទ្ធសាសនាតាមប្រពៃណីត្រូវបានប្រើប្រាស់ជាទូទៅដោយអ្នកចិត្តសាស្ត្រនៅប្រទេសលោកខាងលិច ។ សមាហរណកម្មនៃព្រះពុទ្ធសាសនា និងចិត្តវិទ្យានឹងបង្កើនប្រសិទ្ធភាពនៃការព្យាបាល និងលើកកម្ពស់ឲ្យប្រជាជនស្វែងរកជំនួយសម្រាប់ការព្យាបាលជំងឺផ្លូវចិត្ត ។ ទាំងនេះផ្តល់ឱកាសក្នុងការប្រមូលផ្តុំព្រះសង្ឃ និងគ្រូពេទ្យខ្មែរបុរាណដើម្បីបំពេញកង្វះខាតរបស់អ្នកជំនាញផ្នែកសុខភាពផ្លូវចិត្តដែលទទួលការបណ្តុះបណ្តាលសម្រាប់ប្រជាជនកម្ពុជាដែលស្វែងរកជំនួយ ។ ព្រះសង្ឃអាចទទួលបានការបណ្តុះបណ្តាលលក្ខណៈមូលដ្ឋាននៃចិត្តសាស្ត្រដើម្បីបន្ថែមលើការប្រណិប័តន៍បែបប្រពៃណី ប៉ុន្តែក៏ត្រូវដឹងថានៅពេលណាដើម្បីសំដៅលើអ្នកជំងឺដែលមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ ដូចជាអ្នកដែលមានបញ្ហាផ្លូវចិត្តឬគំនិតធ្វើអត្តឃាត គួរតែទៅរកអ្នកជំនាញខាងវេជ្ជសាស្ត្រ ។

## ចលនាលើសពីការស្រាវជ្រាវពីបញ្ហាប៉ះទង្គិចផ្លូវចិត្ត

ទំនាស់យុត្តិធម៌របស់កម្ពុជាមិនអាចសម្រេចបានទេ រហូតដល់សុខមាលភាពចិត្តសាស្ត្រត្រូវបានស្តារឡើងវិញដោយមិនមែនទាំងស្រុងលើការព្យាបាលស្នាកស្នាមរបស់បុគ្គលម្នាក់ៗ តែដើម្បីការស្តារឡើងវិញនៅស្ថាប័នដែលខ្មែរក្រហមបំផ្លាញបន្ទាប់ពីឆ្នាំ១៩៧៥ ។ ខណៈដែលឯកសារនេះផ្តោតលើសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះពីរបបខ្មែរក្រហម វាក៏ជាការគាំទ្រកិច្ចការដែលលើសពីការស្រាវជ្រាវ ការប៉ះទង្គិចផ្លូវចិត្តពីរបបខ្មែរក្រហម ឆ្ពោះទៅកាន់ការសិក្សាពីជំងឺរាតត្បាតកាន់តែច្រើនឡើងលើស្ថានភាពសុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជាបច្ចុប្បន្ន ។ ការធ្វេសប្រហែសនៃការស្រាវជ្រាវលើបញ្ហាផ្លូវចិត្ត និងប្រព័ន្ធសៃប្រសាទនៅក្នុងប្រទេសកម្ពុជាគឺជាឧបសគ្គចំពោះកិច្ចការបង្កើតផែនការគោលនយោបាយសម្រាប់សុខភាពផ្លូវចិត្តដោយផ្អែកលើភស្តុតាងជាតិ ។

## សេចក្តីសន្និដ្ឋាន

(ខ្មែរក្រហមបានបន្សាចសតិអារម្មណ៍ប្រជាជនកម្ពុជា ។ របបនេះបានបន្សល់ទុកនៅបញ្ហាផ្លូវចិត្ត និងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសុខភាពផ្លូវចិត្តរបស់កម្ពុជា ។ នេះមិនត្រូវបានគេដោះស្រាយឲ្យបានគ្រប់គ្រាន់នៅក្នុងការផ្លាស់ប្តូរបន្ទាប់ពីជម្លោះ ។ ការព្យាបាលផ្នែកចិត្តសាស្ត្រនៅតែជាការពិចារណាក្នុងការខិតខំប្រឹងប្រែងដើម្បីផ្តល់យុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍ ប៉ុន្តែវាចាំបាច់ណាស់ក្នុងការជួសជុលផលប៉ះពាល់ដែលបានបន្តឡើង ។ ការខិតខំប្រឹងប្រែងយ៉ាងតូចចង្អៀតរបស់សហគមន៍អន្តរជាតិចំពោះធាតុផ្សំដែលអាចមើលឃើញនៃយុត្តិធម៌ បានមិនយកចិត្តទុកដាក់ចំពោះសារសំខាន់នៃការស្តារឡើងវិញនូវសុខុមាលភាពផ្លូវចិត្តរបស់កម្ពុជា ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់អត្ថប្រយោជន៍ផ្នែកចិត្តសាស្ត្រដល់អ្នកចូលរួមមួយចំនួន ប៉ុន្តែមិនមានលទ្ធភាពធ្វើឲ្យប្រជាជនទូទៅក្នុងកម្ពុជាសះស្បើយនោះទេ ។

ខណៈដែលសាលាក្តីទទួលបាននូវតម្លៃលើសពីការព្យាបាលផ្លូវចិត្ត ការលើកកម្ពស់យុត្តិធម៌ប្រកបដោយតម្លាភាព និងនីតិរដ្ឋវាមិនមែនជាដំណាក់កាលចុងក្រោយនៃដំណើរការអន្តរកាលរបស់កម្ពុជានោះទេ ។ សហគមន៍អន្តរជាតិត្រូវតែធ្វើការជាមួយរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើត “វប្បធម៌ការពារសិទ្ធិមនុស្ស” ដែលក្នុងនោះការវិនិយោគលើការថែទាំសុខភាពផ្លូវចិត្តគឺជាអាទិភាពមួយ ។ របាយការណ៍នេះនឹងដោះស្រាយដោយផ្ទាល់នូវផលប៉ះពាល់ដែលបន្តឡើងដោយរបបនេះ ហើយវាមានសារសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។

**ម៉ាក ជូរី**

# សំឡេងចេញពីអន្លង់វែងថ្មីវិញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ថ្ងៃទី “១៧ មេសា ១៩៧៥” បានក្លាយជាកាលបរិច្ឆេទមួយ ដែលត្រូវបានពណ៌នាជាទូទៅបំផុតថាជាថ្ងៃនៃចំណុចរបត់សង្គមនយោបាយរបស់ប្រទេសកម្ពុជាប្រកបដោយសោកនាដកម្ម ឆ្ពោះទៅកាន់របបគ្រប់គ្រងរបស់ខ្មែរក្រហម ឬឈ្មោះជាផ្លូវការថា “របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)” ។ នៅពេលនិយាយអំពីកាលបរិច្ឆេទនេះ ប្រជាជនកម្ពុជាភាគច្រើនសម្តែងនូវអារម្មណ៍សោកសៅបំផុតចំពោះការមកដល់នៃយោធាខ្មែរក្រហមនៅក្នុងទីក្រុងភ្នំពេញ ខណៈអ្នកខ្លះទៀតក៏អបអរជាមួយនឹងជ័យជម្នះនេះដែរ និងសង្ឃឹមថាសង្គ្រាមបានផុតរលត់ទៅហើយប្រទេសជាតិនឹងមានសន្តិភាព ដែលប្រជាជនរង់ចាំអស់រយៈពេលជាយូរមកហើយ ។ កាលបរិច្ឆេទនេះ ក៏ត្រូវបានចងចាំថាជាថ្ងៃដែលចាប់ផ្តើមជម្លៀសប្រជាជនកម្ពុជានៅក្នុងទីក្រុងភ្នំពេញ និងទីប្រជុំជននានា ។ ភាពចលាចល និងភាពភ័យខ្លាចចំពោះវត្តមានយោធាខ្មែរក្រហមបានកើតមានចំពោះប្រជាជននៅក្នុងទីក្រុង ។

សំណួរដ៏គួរឲ្យចាប់អារម្មណ៍មួយត្រូវបានលើកឡើង គឺថា



ប្រជាជនជម្លៀសចេញពីក្រុងភ្នំពេញ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។

តើនៅពេលនោះអតីតយោធាខ្មែរក្រហមខ្លួនឯងមានការយល់ឃើញយ៉ាងដូចម្តេចដែរចំពោះថ្ងៃ១៧ មេសា ១៩៧៥ នេះ?

ដើម្បីស្វែងយល់ និងឆ្លុះបញ្ចាំងទៅលើកាលបរិច្ឆេទខាងលើ អត្ថបទនេះសូមលើកយកទស្សនៈរបស់ប្រជាជនអន្លង់វែង ដែលភាគច្រើនជាអតីតយោធា និងសមាជិកនៃចលនាខ្មែរក្រហម ។ គោលបំណងចម្បងគឺចង់ដឹងថាតើអតីតយោធាខ្មែរក្រហមមានទឹកចិត្ត និងសេចក្តីរំពឹងបែបណាចំពោះជ័យជម្នះទាំងស្រុង ហើយថាតើនរណាគួរត្រូវបន្ទោសចំពោះដំណើរវិវដ្តឆ្ពោះទៅរកសោកនាដកម្មដែលប្រជាជនកម្ពុជាជិតពីរលាននាក់បានបាត់បង់ជីវិតនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ សេចក្តីដកស្រង់សម្តីដើមមានដូចតទៅ៖

លោក ជាម ទ្រឹម អាយុ៦០ឆ្នាំ នៃស្រុកអន្លង់វែងៈ «ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺថ្ងៃដែលយើងវាយរំដោះភ្នំពេញ ។ ជាធម្មតាយើងចង់ចប់សង្គ្រាម ។ យើងអត់ចង់ទេក្នុងការធ្វើសង្គ្រាមហ្នឹង ។ ប៉ុន្តែនៅពេលវាយរំដោះបានឈ្នះហើយ គឺយើងត្រេកអរណាស់មួយពេលនោះ ព្រោះតួនាទីយើងជាអ្នកធ្វើសង្គ្រាមពេលឈ្នះយើងត្រេកអរ ។ តែក្រោយពីការឡើងកាន់អំណាចរបស់ខ្មែរក្រហម ហើយវាបែរជាមានការលំបាកជាងពេលយើងធ្វើសង្គ្រាមជាមួយ លន់ នល់ ទៅវិញ គឺលំបាកតាំងពីជីវភាពរស់នៅ លំបាកទាំងរបបនយោបាយគាបសង្កត់ទាំងយោធា និងប្រជាជនធម្មតា» ។

លោក ជួប សួរ អាយុ៦៥ឆ្នាំ នៃស្រុកអន្លង់វែងៈ «ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥គឺជាថ្ងៃដែលខ្មែរក្រហមបានវាយរំដោះទីក្រុងភ្នំពេញ ។ ខ្ញុំផ្ទាល់បានចូលវាយរំដោះក្នុងចលនាហ្នឹងដែរ ។ យើងវាយដាច់មកពីទិសខាងលិចភ្នំពេញរហូតចូលមកដល់ពោធិ៍ចិនតុង ។

នៅពេលដែលយើងទទួលបានជ័យជម្នះដោយផ្តួលរំលំរបប លន់ នល់ ដែលគាំទ្រដោយអាមេរិករួចហើយ ។ អារម្មណ៍របស់ខ្ញុំនៅពេលនោះគឺរំភើប និងត្រេកអរយ៉ាងខ្លាំង ដោយសង្ឃឹមថា នឹងអាចទៅលេងផ្ទះសម្បែង រួមទាំងក្រុមគ្រួសារនៅឯស្រុកទៀតផង ។ ជាពិសេសគឺសម្រាប់សង្គមខ្មែរយើងទាំងមូលនឹងឈានទៅរកសន្តិភាពចាប់ពីពេលនោះហើយមើលទៅ ។ តែវាផ្ទុយស្រឡះពីអ្វីដែលខ្ញុំគិតតែម្តង» ។

លោកស្រី សឹម ធីម អាយុ៦១ឆ្នាំ នៃស្រុកអន្លង់វែងៈ «នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានវាយបានទីក្រុងភ្នំពេញ ដោយផ្តួលរំលំ លន់ នល់ ដែលមានអាមេរិកជាអ្នកគាំទ្រ ។ នៅពេលហ្នឹង ខ្ញុំមានចិត្តរំភើបរីករាយយ៉ាងខ្លាំង ដោយគិតថាសង្គ្រាមនៅខ្មែរត្រូវបានបញ្ចប់ ហើយឈានទៅរកសន្តិភាពមួយដ៏ល្អប្រសើរ ។ តែក្រោយមក ខ្ញុំគិតថាសម័យដែលខ្មែរក្រហមដឹកនាំមានលក្ខណៈតឹងតែង និងធ្វើឲ្យមានការបែកបាក់ម៉ែឪ បងប្អូន ហើយត្រូវហូបរួមទៀត» ។

លោកស្រី ណុប រីម អាយុ៦០ឆ្នាំ នៃស្រុកអន្លង់វែងៈ «សម្រាប់ខ្ញុំ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺថានៅពេលដែលខ្មែរក្រហមបានដឹកនាំប្រជាជន និងកងទ័ពប្រឆាំងរបប លន់ នល់ ។ ខ្ញុំគិតថាការផ្តួលរំលំរបស់របប លន់ នល់ ហើយការឡើងកាន់អំណាចរបស់ខ្មែរក្រហម គឺល្អខ្លាំងណាស់សម្រាប់សង្គមជាតិខ្មែរ ។ ខ្ញុំតែងតែគិតទៀតថា ខ្លួននឹងបានទៅលេងស្រុកកំណើតវិញដោយសប្បាយរីករាយជួបជុំគ្រួសារ ។ ជាពិសេសសម្រាប់សង្គមជាតិអាចឈានទៅរកសុខសន្តិភាពតែម្តង ។ ផ្ទុយទៅវិញ អារម្មណ៍នៃការគិតទាំងហ្នឹងត្រូវរលាយសាបសូន្យ ដោយសារប្រទេសជាតិរឹតតែមានភាពតឹងតែងឡើងៗ» ។

លោក មិន រីម អាយុ៥៩ឆ្នាំ នៃស្រុកអន្លង់វែងៈ «ពេលដែលខ្មែរក្រហមឡើងកាន់អំណាចថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំគិតថា វាជាថ្ងៃល្អនៃការដណ្តើមជ័យជម្នះរបស់ខ្មែរក្រហមដែល



យោធាខ្មែរក្រហមនៅអន្លង់វែងចុះចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ១៩៩៨

បានផ្តួលរំលំរបប លន់ នល់ ដែលគាំទ្រដោយអាមេរិក ។ នៅពេលនោះ ខ្ញុំតែងតែសង្ឃឹមថា យើងអាចរស់នៅក្នុងរបបសង្គមមួយថ្មី និងប្រសើរជាងមុន» ។

លោក ហេង កេង អាយុ ៥៩ឆ្នាំ នៃស្រុកអន្លង់វែងៈ «យល់ថា ថ្ងៃទី១៧ មេសា ១៩៧៥ គឺជាថ្ងៃមួយដែលខ្មែរក្រហមបានរំដោះប្រទេសខ្មែរពីរបបគ្រប់គ្រងរបស់ លន់ នល់ ដែលមានអាមេរិកជាអ្នកដាក់នឹមត្រួតត្រា និងជាម្ចាស់ជំនួយពីព្រោះរាល់គ្រឿងសម្ភារទាំងអស់ គឺអាមេរិកជាអ្នកផ្តល់ជំនួយទាំងស្រុង ។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច អារម្មណ៍ខ្ញុំនៅពេលនោះ គឺមានការរំភើប និងត្រេកអរខ្លាំងណាស់ពីព្រោះខ្មែរក្រហមបានរំដោះប្រទេសឲ្យរួចផុតពីការត្រួតត្រារបស់អាមេរិក ។ ខ្ញុំគិតថា យើងបានរស់នៅក្នុងរបបសង្គមមួយថ្មី» ។

លោក អុក វ៉ា អាយុ៦០ឆ្នាំ នៃស្រុកអន្លង់វែងៈ «ខ្ញុំយល់ឃើញថា ថ្ងៃទី១៧ មេសា ជាថ្ងៃដែលខ្មែរក្រហមវាយរំដោះបានទីក្រុងភ្នំពេញពីរបបគ្រប់គ្រងរបស់ លន់ នល់ ដែលមានអាមេរិកជាអ្នកនៅពីក្រោយខ្នង ។ ចំពោះខ្ញុំនៅពេលនោះគឺមានការត្រេកអរយ៉ាងខ្លាំងក្នុងមួយពេលនោះ ដោយពុំបានគិតឲ្យជ្រៅថាទៅថ្ងៃមុខទៀត វាទៅជាយ៉ាងណានោះទេ» ។

លោកស្រី ឡាច ខន អាយុ៦៨ឆ្នាំ នៃស្រុកអន្លង់វែងៈ «ទស្សនៈរបស់ខ្ញុំជុំវិញថ្ងៃទី១៧ មេសា គឺថា នៅពេលនោះ ខ្មែរក្រហមបានរំដោះប្រទេសជាតិពីការគ្រប់គ្រងរបស់ លន់ នល់ និងអាមេរិក ។ ខ្ញុំមានចិត្តរំភើប និងត្រេកអរយ៉ាងខ្លាំងដោយគិតថាប្រទេសជាតិនឹងទទួលបានសន្តិភាព បានជួបជុំក្រុមគ្រួសារ និងមានពេលរកស៊ី ។ តែទីបញ្ចប់ វាខុសពីការពិតទាំងស្រុង» ។

លោកស្រី ឆាំ ឡុង អាយុ៦២ឆ្នាំ នៃស្រុកអន្លង់វែងៈ «ទស្សនៈរបស់ខ្ញុំជុំវិញថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺនៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចភ្លាម ចិត្តរបស់ខ្ញុំមានការរំភើបយ៉ាងខ្លាំង ។ យើងបានរួចផុតពីរបប លន់ នល់ ។ តែក្រោយមកក្រោមការដឹកនាំរបស់ខ្មែរក្រហម ច្បាប់វិន័យសម្រាប់អប់រំមនុស្សកុំឲ្យមានការឆក់លួចប្លន់គឺមាន ។ ប៉ុន្តែបើច្បាប់ទៅលើការកាត់ទោសវិញ គឺស្ថិតនៅលើមាត់មនុស្ស គឺមានលក្ខណៈអនាធិបតេយ្យដោយអាស្រ័យទៅលើគំនុំបុគ្គលម្នាក់ៗ ហើយណាមួយរឿងដែលមិនធំដុំ ក៏ធ្វើឲ្យមានការសម្លាប់ងាយៗ គឺមានការខុះចន្លោះត្រង់ហ្នឹងឯង ។ បើរឿងហូបចុកវិញ ជាធម្មតាមនុស្សរស់ដោយសារហូប តែដំនាន់ហ្នឹងវាមានលក្ខណៈតឹងតែងត្រង់ថា គេចង់ឲ្យហូបចុករួមគ្នាដោយសមូហភាព ។ អ្វីៗក៏រួមគ្នា ។ ជាធម្មតាមនុស្សក្រពះខុសគ្នាគឺឃ្លានហើយ ។ បើសម្រាប់ខ្ញុំ គឺមិនបានជួបប្រទះខ្លាំងដូចគេទេព្រោះតំបន់ ដែលស្ថិតនៅទីតាំងភូមិទឹកជុំសព្វថ្ងៃនេះគឺវាមិនតឹងរឹងដូចតំបន់ដទៃទេដោយមានការយោគយល់គ្នាដែរដូចថាយើងអាចគាស់ដំឡូងមកដុតហូបក្រៅគឺបាន តែបើកន្លែងផ្សេងៗ បើគេដឹងគឺគេយកទៅសម្លាប់ចោលតែម្តង ហើយបើនិយាយរួម នៅក្នុងសង្គមជាតិទាំងមូលពេលហ្នឹងគឺវាពិបាកដោយកន្លែងៗដែរ វាមិនទាំងស្រុងនោះទេ» ។

លោក ទិត្យ មន អាយុ ៧៣ ឆ្នាំ នៃស្រុកអន្លង់វែងៈ «នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំគិតថា កាលហ្នឹងនយោបាយតម្រូវឲ្យយើងចូលព្រៃដើម្បីដណ្តើមអំណាចមកវិញឲ្យសម្តេចព្រះ នរោត្តម សីហនុ ។ តែទីបញ្ចប់ នៅពេលដែលយើងវាយឈ្នះ លន់ នល់ ហើយបែរជាលេចចេញអ្នកផ្សេងមកកាន់អំណាចទៅវិញ ។

នៅពេលនោះ ខ្ញុំមិនដែលស្គាល់ ប៉ុល ពត ជាអ្នកណាផង ហើយក៏មិនដែលឮឈ្មោះ ប៉ុល ពត ទៅទៀត ។ តែបែរជាគាត់ក្លាយទៅជាអ្នកដឹកនាំប្រទេស ។ រឿងនេះធ្វើឲ្យខ្ញុំស្រងាកចិត្តខ្លាំងណាស់ តែមិនដឹងធ្វើអ្វីកើត បើយើងនៅក្រោមការគ្រប់គ្រងរបស់របបនោះទៅហើយ» ។

អតីតយោធាខ្មែរក្រហម និងប្រជាជនកម្ពុជាជាច្រើន ធ្លាប់មានសេចក្តីសង្ឃឹមស្រដៀងគ្នាដែរចំពោះថ្ងៃទី១៧ មេសា ១៩៧៥ ដោយគិតថាសង្គ្រាមបានបញ្ចប់ ហើយសន្តិភាពនឹងកើតមានឡើងចំពោះប្រទេសជាតិរបស់ខ្លួន ។ ជាពិសេសខ្លួនអាចនឹងវិលត្រឡប់ទៅកាន់ភូមិកំណើតរបស់ខ្លួន និងជួបជុំក្រុមគ្រួសារវិញ ។ នេះជាការតស៊ូ និងការលះបង់រួមគ្នារបស់ប្រជាជនកម្ពុជា ដើម្បីបុព្វហេតុជាតិ និងមាតុភូមិ ។ ក៏ប៉ុន្តែ ដូចដែលប្រវត្តិសាស្ត្របានបង្ហាញរួចហើយ របបខ្មែរក្រហមបានប្រែក្លាយទៅជាការគ្រប់គ្រងប្រកបដោយមហន្តរាយទៅវិញចាប់ពីថ្ងៃទី១៧ មេសា ១៩៧៥ ។

**លី សុខឃាង និង ស្នួត វិចិត្រ**

# ៧ មករា ១៩៧៩ ដល់ ៧ មករា ២០១៨ ជាថ្ងៃកំណើតជីវិតទី២របស់ខ្ញុំ បាន៣៩ឆ្នាំហើយ

## *មនុស្សសំណាងមួយនាក់ ក្នុងចំណោមមនុស្ស៥.០០០នាក់ ដែលមានជីវិតរស់នៅ រួចផុតពីការកាប់សម្លាប់ក្នុងរបបខ្មែរក្រហម*

*ប្រវត្តិពិតៗជាច្រើនឆ្នាំមកហើយ ដែលខ្ញុំលាក់ទុកក្នុងចិត្ត...*

**(តបប់)**



ស សារិន

តមកទៀត ខៀវ សំផន ក៏បានលើកឡើងអំពីរឿងខ្មាំងស៊ីរូងផ្ទៃក្នុងដែលធ្វើឲ្យរាំងស្ទះដល់ចលនាបដិវត្តន៍កម្ពុជា គឺមាននៅគ្រប់អង្គភាពរៀងៗខ្លួនសមមិត្តត្រូវប្រយ័ត្ន! បើនៅបររថភ្លើង វាធ្វើឲ្យបុករថភ្លើង បើនៅបើកឡានបន្តិចវាបើកបុក វាធ្វើឲ្យធុះធ្វើឲ្យក្រឡាប់ ធ្វើឲ្យម៉ាស៊ីនខ្សោកជាដើម ហើយទាំងនេះជាសកម្មភាពរបស់ខ្មាំងហើយ ។ បើខាងកាត់ដេរ វាធ្វើឲ្យបាក់ម្ជុល ធ្វើឲ្យខូចត្រល់ ធ្វើឲ្យអាក់ខានដំណើរការលែងបានទៅមុខ និងរាំងស្ទះនេះ យើងពិនិត្យតាំងពីរឿងតូចៗនេះទៅ ។ បើនៅតាមសហករណ៍ ខ្មាំងវាធ្វើឲ្យបាក់នង្គ័លបាក់រនាស់ បាក់ចប ទាំងនេះក៏ជាសកម្មភាពខ្មាំងដែរ ។ ទាំងនេះជាខ្មាំងស៊ីរូងផ្ទៃក្នុង ធ្វើឲ្យរាំងស្ទះដល់ចលនាកសាងសង្គមនិយម ។ តាមខ្ញុំយល់ ប្រជាជនខ្មែរយើងបានស្លាប់ច្រើនណាស់ គឺដោយសារតែការធ្វើឲ្យបាក់ចប ក៏ចាត់ទុកថាជាខ្មាំងដែរ ។

ដល់រសៀលស្អែក ខៀវ សំផនបន្តទៀតដោយលើកឡើងពីរឿងអ្នកដែលជាប់ខ្សែរយៈខ្មាំង ដែលត្រូវឡើងសារភាព និងធ្វើជីវទស្សន៍មានចំនួនពីរបី«ខ» ។ ខៀវ សំផន បានលើកឡើងថា ក្នុងសង្គ្រាមអាកាសរបស់ចក្រពត្តិអាមេរិកដែលបង្កវិនាសសកម្មមកលើទឹកដីកម្ពុជាយើងនេះ តើសមមិត្តមានគោលជំហរ និងសតិអារម្មណ៍យ៉ាងដូចម្តេចខ្លះក្នុងការតស៊ូបដិវត្តន៍? ហើយក្រោយពីបានសិក្សាគោលនយោបាយពីបក្សរួចចេញទៅវិញ និងចុះទៅហ្នឹង សមមិត្តត្រូវប្តេជ្ញាចិត្តអ្វីខ្លះ? ។ ក្នុងនោះដែរ ខ្ញុំបានចាំនូវអ្វីដែលខ្ញុំបានសរសេរខ្លះដែរ គឺមានការប្តេជ្ញាគោរពគោលនយោបាយរបស់បក្សគ្រប់បែបយ៉ាងនឹងចុះអនុវត្ត និងប្តេជ្ញារាវរកខ្មាំងស៊ីរូងផ្ទៃក្នុងដែលបង្កប់ក្នុងជួរប្រជាជន កម្មករ កសិករ និងកងទ័ពឲ្យបានល្អជាដាច់ខាត ។ ប្តេជ្ញាកសាងខ្លួន បំពាក់នូវគោលជំហរវណ្ណៈអធនដល់ខ្លួនដើម្បីធ្វើបដិវត្តន៍សង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យ ឲ្យមានល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ ។ សំខាន់ជាងគេនៅថ្ងៃកណ្តាលមួយថ្ងៃ ខៀវ សំផន បាននៅចាំស្រង់ឈ្មោះអ្នកដែលជាប់ឥទ្ធិពល និងនៅជាមួយជនក្បត់ ។

បន្ទាប់ពីបញ្ចប់ការរៀនសូត្រ មន្ទីររបស់ខ្ញុំបានបាត់មនុស្សអស់ប្រហែល៣០នាក់ ក្នុងចំណោមអ្នកបើកបរប្រហែលជា១០០នាក់ ។ ខ្លះត្រូវអង្គការប្តូរការងារ ហើយខ្ញុំក៏មិនហ៊ានសួរដេញដោលអ្វីដែរ ។ ភាគច្រើនអ្នកដែលធ្លាប់ធ្វើការជាមួយ កុយ ធួន តាមខ្ញុំសង្កេតមើល ដូចជាអ្នកដែលខ្ញុំធ្លាប់ស្គាល់មានឈ្មោះ ភួង, ឆួយ, រី និង សារី ត្រូវបានបាត់ខ្លួន ។ ខ្ញុំឲ្យតម្លៃចំពោះខ្មែរដែលស្លាប់បាត់បង់ជីវិតរាប់លាននាក់ ដោយសារតែសាលាមួយនេះ ដែលបានបង្រៀនបងៗពីជំនាន់មុន ។ កាលណោះ គឺសំដៅលើអ្នកដែល

មិនសម្របខ្លួនទៅតាមបក្ស មិនព្រមចូលសហករណ៍ ចុះដាប់ជនបទ គឺត្រូវបោសសម្អាត ។

## កន្លែងសម្លាប់មនុស្ស

ឆ្នាំ១៩៧៧ ប្រទេសកម្ពុជាយើងមានភាពចលាចលខ្លាំងជាមួយភាគីវៀតណាម ហើយស្ថានទូតវៀតណាមត្រូវបានដកចេញពីប្រទេសកម្ពុជា ដោយសារវិវាទគ្នារឿងកោះត្រល់ នេះបើតាមខ្ញុំដឹង ។ ភាគីវៀតណាម កើតទុកមិនសុខចិត្តបានយកដែនទីខ្មែរយើងទៅប្តឹងនៅក្រសួងការបរទេសប-១ ។ ការឈ្លោះគ្នាពីរឿងកោះត្រល់ យើងថាកោះយើង វៀតណាមថាកោះគេ ហើយមានរឿងវិវាទតាមព្រំដែន វាយគ្នាមិនអស់មិនហើយ ។ វាយគ្នាតាំងពីកន្ទុយនាគ រហូតមកដល់ឆ្នេរសមុទ្រ ហើយពេលដែលខៀវ សំផន បង្រៀនក៏បាននិយាយអំពីបញ្ហានេះដែរ គឺលើកឡើងថា យើងមានជម្លោះព្រំដែនរហូតដល់យើងទប់លែងបាន យើងបណ្តេញទូតចេញទាំងថ្ងៃត្រង់ ។ អំឡុងពេលនោះ ខ្ញុំជូនដំណើរភ្ញៀវចិនឡើងយន្តហោះ រួចក៏បានជួបក្រុមបង ជង ដែលជាក្រុមបើកឡានខាងទូត ក៏ជូនដំណើរខាងទូតវៀតណាមនេះទៅដែរ ។ ទូតវៀតណាមជិះតាមយន្តហោះតូចមួយ ដែលជិះគ្នាប្រហែល៦-៧នាក់ឡើងទៅទាំងថ្ងៃ ។ ចាប់តាំងពីនោះមក ខ្មែរយើង និងវៀតណាមចាប់ផ្តើមមិនត្រូវគ្នា និងមានការប្រយុទ្ធគ្នារហូត ។ បើនិយាយអំពីមន្ទីរពេទ្យដែលខ្ញុំធ្លាប់បានដឹកយុទ្ធជនត្រូវរបួសទៅ គឺរកកន្លែងដេកគ្មានទេ ដូចជាពេទ្យ ១៧ មេសា (ពេទ្យរុស្ស៊ី) និងពេទ្យអង្គឌួងមួយដែរ គឺពេញទៅដោយអ្នករបួស ។ អំឡុងពេលនោះ រថយន្តក្រុងដឹកភ្ញៀវលែងបានដឹកភ្ញៀវហើយ គឺដឹកតែអ្នករបួសប៉ុណ្ណោះ ដោយដោះពូកចេញទាំងអស់ ។ អ្នករបួសពេលនោះ ត្រូវបានដឹកតាមកប៉ាល់ដែលភាគច្រើនយកពីខាងទន្លេបិទ និងខ្លះពីអ្នកលឿង យកមកដាក់នៅមុខវាំង ទើបឡានពួកខ្ញុំទៅដឹកបន្តមកមន្ទីរពេទ្យ ។ ចំពោះអ្នករបួសឆ្ងាយៗដូចជានៅខាងក្រចេះ គឺដឹកតាមយន្តហោះមក ។ ឲ្យតែមានអ្នករបួសមក គឺស្នើមកខាងក-១២ ទៅជួយដឹកហើយប្រធានក-១២ របស់ខ្ញុំបានបញ្ជូនពួកខ្ញុំទៅដឹកតែម្តង ។

ដោយមានការប្រយុទ្ធជាមួយវៀតណាមកាន់តែខ្លាំង បក្សក៏មានផែនការអំពីគ្រាប់ដែលដឹកមក ។ ប៉ន់ ដែលជាប្រធានមន្ទីរ ៨៧០ បានពិភាក្សាជាមួយមេៗថា ត្រូវដកកម្លាំងពីកន្លែងបក្សទៅផ្ទាល់ អត់មានឲ្យកម្លាំងណាទៅទេ ។ កាលណោះ អង្គការបានចាត់តាំងឲ្យខ្ញុំទៅកាន់នៅឃ្លាំងគ្រាប់កំពង់ចាម ។ ខ្ញុំធ្លាប់តែនៅក្រសួងការបរទេស ម្ងៃៗទៅតែផ្សារ ទៅតែពោធិ៍ចិនតុង ។ កូនឡាន និងឡានធំគឺខុសគ្នា ។ ខ្ញុំមានសតិអារម្មណ៍ដែរ ប៉ុន្តែមិនហ៊ានតថ្លៃ ។ បន្ទាប់មក ខ្ញុំបានទៅនៅកំពង់ចាម ដំបូងអង្គការឲ្យទៅយកឡានធ្លាក់ទឹក ខ្ញុំបើកអារីន (ឡានចិន) ។ ដំបូងបង ឆាន អនុបង ខាំមី នៅកាន់មុខសញ្ញាខាងកំពង់ចាម សាលាដីដុះ ម៉ាជួរទួលស្បូវ មានផ្ទះធំៗដាក់គ្រាប់កាំភ្លើងទាំងអស់ ដាក់រហូតរកកន្លែងដាក់គ្មាន ។ បន្ទាប់មក ខ្ញុំបានចេញទៅនៅកំពង់ចាម ប្រហែលជាខែមីនា ឆ្នាំ១៩៧៨ ទៅធ្វើការនៅខាងលិចព្រលានយន្តហោះក្បែរភ្នំប្រុស ភ្នំស្រី ។ នៅកំពង់ចាម ខ្ញុំជាអ្នករៀបចំសម្ភារ និងដឹកជញ្ជូន ។ ខ្ញុំនិងមិត្ត វេទ ត្រូវដឹកជញ្ជូនមួយយប់ៗទល់ៗភ្លឺ ហើយការដឹកជញ្ជូនគ្រាប់នេះ គឺធ្វើតែនៅពេលយប់តែប៉ុណ្ណោះ ដោយលាក់ការណ៍មិនឲ្យអ្នកណាឃើញឡើយ ។ តាមខ្ញុំដឹង ឃ្លាំងគ្រាប់ធំជាងគេគឺនៅកំពង់ចាមនេះឯងដែលបានផ្តល់ឲ្យបណ្តាកងពល និងភូមិភាគ មានដូចជា ភូមិភាគបូព៌ា ភូមិភាគកណ្តាល និងភូមិភាគឥសាន្ត ។ គ្រាប់ត្រូវបានដឹកដោយកប៉ាល់យកទៅស្តុកទុកនៅឃ្លាំងគ្រាប់កំពង់ចាមស្ទើររាល់ថ្ងៃ ។ ពេលនោះបណ្តាកងពលផ្សេងៗ តែងតែមកស្នើសុំគ្រាប់ជាហូរហែ នៅទីនេះហើយ ខ្ញុំបានដឹងទៀតថា ឃ្លាំងគ្រាប់នេះបានផ្គត់ផ្គង់ឲ្យទៅ៣ភូមិភាគដែលបានរៀបរាប់ខាងលើ និងមួយចំណែកទៀតសម្រាប់បណ្តាកងពលរបស់មជ្ឈិម ។ កងពលភូមិភាគ គឺគណៈភូមិភាគមកស្នើសុំដោយផ្ទាល់ ឬក៏ពេលខ្លះ ខ្ញុំជាអ្នកដឹកយកទៅឲ្យដល់មន្ទីរភូមិភាគតែម្តងក៏មានដែរ ។

នៅកំពង់ចាមរហូតទាល់តែមានការផ្ទុះអាវុធនៅភូមិភាគបូព៌ា ។ ខ្ញុំចាំបានថា នៅខែឧសភា ឆ្នាំ១៩៧៨ មានការផ្ទុះអាវុធនៅថ្នល់ទទឹង ផ្ទុះអាវុធពេញភូមិភាគបូព៌ា ហើយនៅពេលនោះថ្នាក់លើក៏លែងឲ្យខ្ញុំដឹកគ្រាប់ទៅឲ្យភូមិភាគបូព៌ាទៀតដែរ ។ អំឡុងពេលនោះ មានការចាប់កម្មាភិបាល យុទ្ធជនរបស់ភូមិភាគបូព៌ាយកមកសម្លាប់នៅម្តុំភ្នំប្រុសច្រើនណាស់ ។ តាមខ្ញុំយល់ កន្លែងសម្លាប់មនុស្សនៅកំពង់ចាមអាចមានចំនួនច្រើនជាងបឹងជើងឯកទៅទៀត ។

ពេលខ្លះ ខ្ញុំពិតជាមានអារម្មណ៍នឹកផ្ទះខ្លាំងណាស់ ទោះបីជាធ្លាប់ជូនគណៈប្រតិភូ ថ្នាក់ដឹកនាំទៅកំពង់ចាមដែលជាស្រុកកំណើតក៏ពិតមែន ប៉ុន្តែខ្ញុំមិនដែលបានទៅរកគ្រួសារ ឬបានទៅលេងផ្ទះម្តងណាឡើយ គឺបានត្រឹមឃើញដំបូលផ្ទះដោយសម្លឹងមើលពីផ្លូវតែប៉ុណ្ណោះ ។ ការបែកចាកចេញឆ្ងាយពីស្រុកកំណើត និងក្រុមគ្រួសារអស់រយៈពេលបីឆ្នាំ ខ្ញុំមិនដែលហ៊ានសុំអង្គការមកលេងផ្ទះឡើយ ហើយក៏មិនដឹងថា ឪពុកម្តាយរបស់ខ្ញុំមានសុខទុក្ខយ៉ាងណាឡើយ ។ ខ្ញុំនឹកឃើញពេលដែលខ្ញុំជូនគណៈប្រតិភូចិន ឆឹង យុងគួយ និង ប៉ុល ពត ទៅកំពង់ចាម ខ្ញុំបានត្រឹមតែសួរសុខទុក្ខឪពុកម្តាយ និងក្រុមគ្រួសារតាមរយៈអ្នកជិតខាងដែលខ្ញុំជួបដោយចៃដន្យ ហើយបាននិយាយជាមួយគ្នាមិនបានប្រាំនាទីផង ។ ប៉ុន្តែខ្ញុំគិតថា ជារឿងល្អមួយដែរសម្រាប់គ្រួសារ ក្រោយពីកម្មាភិបាលដឹងថាខ្ញុំជាអ្នកបើកឡានជូនគណៈប្រតិភូ និងអង្គការលើ (ប៉ុល ពត) គ្រួសារខ្ញុំទាំងអស់មិនត្រូវបានចាត់ឲ្យធ្វើការធ្ងន់ទេ ។ ឪពុកម្តាយខ្ញុំត្រូវអង្គការដកឲ្យមកធ្វើការនៅរោងបាយ ហើយបងប្អូនរបស់ខ្ញុំក៏លែងឲ្យទៅធ្វើការនៅកងចល័តទៀតដែរ គឺត្រូវបានអង្គការ ឲ្យមកធ្វើការងារនៅភូមិវិញ ។

បន្ទាប់ពីព្រឹត្តិការណ៍ផ្ទុះអាវុធនៅបូព៌ា ខ្ញុំបានត្រឡប់មកមន្ទីរក-១២ ហើយពេលនោះ ខ្ញុំមានជំងឺចេះតែឈឺទ្រូង និងរាកមិនឈប់ ។ ខ្ញុំត្រូវអង្គការបញ្ជូនឲ្យសម្រាកពេទ្យ១៧ មេសា ។ អំឡុងពេលនោះ គណៈមន្ទីរក-១២ ត្រូវបានអង្គការលើបោសសម្អាតជាបណ្តើរៗ ។ ខ្ញុំដេកពេទ្យអស់រយៈពេលជិតមួយខែ ទើបបានត្រឡប់ទៅកំពង់ចាមវិញ ។ អំឡុងពេលសម្រាកនៅមន្ទីរពេទ្យ ខ្ញុំបានឆ្លៀតសួរយុទ្ធជនរបួសដែលមកពីភូមិភាគបូព៌ា ក្រែងបានជួបបងប្អូន ។ យុទ្ធជននោះបានប្រាប់ខ្ញុំថា បូព៌ាយើងត្រូវអង្គការចាប់អស់ហើយ អង្គការថាបូព៌ាយើងក្បត់ក្បាលយួនខ្លួនខ្មែរ ។ យុទ្ធជននេះជាអ្នកស្រុករស់នៅភូមិមោង ក្បែរភូមិខ្ញុំដែរ បានប្រាប់ខ្ញុំថា "បងបើអាចរត់បានរត់ទៅ" ។ ខ្ញុំបានតបទៅយុទ្ធជននោះវិញថា "មិនដឹងរត់ទៅណាទេ យើងឃើញស្រាប់ហើយ ស៊ីបាយសុទ្ធតែរួម អ្នកណាយកចេញមួយចានក៏ដឹងដែរ យើងទៅរកបាយឯណាស៊ីបាន" ។

ក្រោយមក ប្រធានមន្ទីរ បង មៀល បង វ៉ុយ ត្រូវបានអង្គការចាប់អស់ហើយ ប្រធានមន្ទីរស-៧១ ក៏បានប្តូរសមមិត្ត លីន ជំនួសសមមិត្ត ប៉ង់ ដែរ ។ សមមិត្ត លីន មានឈ្មោះមួយទៀតហៅថា សមមិត្ត កែន ។ កែន មានរាងខ្ពស់ស្គម ភ្នែកលានៗ ។ សមមិត្តលីន បានហៅកម្មាភិបាល យុទ្ធជននៃមន្ទីរក-១២ ទាំងអស់ប្រហែលជា២០០ទៅ៣០០នាក់ ទៅប្រជុំនៅសាលាយុគន្ធរដែលជាស្នាក់ការរបស់មន្ទីរក-១២ ។ ការប្រជុំនោះ លីន បានលើកឡើងថា អ្នកដែលមានជាប់ពាក់ព័ន្ធជាមួយអតីតប្រធានមន្ទីរចាស់ឈ្មោះមិត្ត មៀល មិត្ត វ៉ុយ មិត្ត ហ៊ិន (រម្លឹកពីអ្នកទាំងបីបន្តិចពីមុនមក បន្ទាប់ពីអង្គការចាប់ កុយ ធួន ហើយគណៈមន្ទីរក-១២ ក៏ត្រូវប្តូរចេញទាំងអស់ ។ មិត្ត ហ៊ិន ត្រូវទៅកាន់នៅកំពង់សោម ចំណែកមិត្ត វ៉ុយ ទៅជំនួស កុយ ធួន ហៅ ធុច ហើយមិត្តម្នាក់ទៀតឈ្មោះ សុទ្ធ ត្រូវទៅបើកឡានឲ្យ ប៉ុល ពត) ដែលចូលជាបក្ខជន ចូលជាសម្ព័ន្ធក្រុមស្ពួល សូមចេញមកសារភាពចំពោះ មុខបក្ស ។ ប្រពន្ធមិត្ត មៀល និងមិត្តផ្សេងៗទៀត ទឹកភ្នែកគ្រប់គ្នា ។ មិត្ត លីន បានបន្តថា បក្សយើងអត់មានគំនិតសម្លាប់មនុស្សទេ គ្រាន់តែឲ្យយកទៅរៀនសូត្រ ផ្លាស់ប្តូរភារកិច្ច ថ្ងៃខាងមុខពួកមិត្តគង់តែជួបគ្នាទេ ។

ពេលដែលខ្ញុំត្រឡប់ទៅកំពង់ចាមវិញ អ្នកនៅទីនោះមិនសូវចង់និយាយរាប់រកខ្ញុំទេ ចាត់ទុកខ្ញុំដូចជាខ្មាំងអីចឹង ។ សម្រាកបានមួយយប់ ព្រលឹមឡើងអង្គការយកខ្ញុំទៅ ខ្ញុំគិតថា ប្រហែលជាអង្គការយកខ្ញុំទៅបាញ់ចោលហើយមើលទៅ ។ អ្នកដែលនៅជាមួយខ្ញុំដូចជា បង ប៊ុន បង សារឿន មិត្ត វេត មិត្ត ឈិន និងមនុស្សដែលរាប់អានគ្នាជិតស្និទ្ធ ធ្លាប់ដេកប្រលែងលេងជាមួយគ្នា ធ្វើហាក់ដូចជាលែងស្គាល់ខ្ញុំទាំងអស់រួមទាំងបង ឌឹម ប្រធានមន្ទីរក-១ ដែលគាត់ឡើងទៅកាន់ឃ្លាំងគ្រាប់នៅកំពង់ចាមជំនួសបង ឆាន ផង ។ បង ឆាន ក៏ត្រូវអង្គការចាប់ដែរ បន្ទាប់ពីអង្គការចាប់បង ប៉ង់ រួចមក ។

ជារឿងរាល់ដងពេលខ្ញុំឡើងឡាន មិត្តទាំងអស់គ្នាបាននាំគ្នាជិះនៅកាប៊ីន ព្រោះវាមិនសូវរលាក់ តែម្តងនេះខុសពីសព្វដង ខ្ញុំមានចង្ងល់ក្នុងចិត្ត ប៉ុន្តែខ្ញុំក៏មិនបានសួរនាំអ្វីដែរ ព្រោះតាមរយៈទឹកមុខអ្នកទាំងអស់នោះ តាំងពីខ្ញុំត្រឡប់មកពីភ្នំពេញវិញ ខ្ញុំដឹងថាមិត្តទាំងអស់ដូចជាមិនស្រួលជាមួយខ្ញុំទេ ។ ពេលនោះ ខ្ញុំនឹកឃើញ

គុណម៉ែ គុណឪ និងទន្ទេញធម៌អស់ហើយ ខ្ញុំគិតថាបើចង់រត់ក៏រត់មិនរួចដែរ ចង់យំក៏យំមិនកើតដែរ ប៉ុន្តែខ្ញុំព្យាយាមតាំងចិត្តក្លាហាន ធ្វើជាច្រៀងហាក់ដូចជាគ្មានបញ្ហាអ្វីកើតឡើងចំពោះទេ តែខ្ញុំដឹងក្នុងចិត្តថា អ្នកទាំងអស់នេះច្បាស់ជាយកខ្ញុំទៅបាញ់ចោលហើយ ។ ក្រោយមកទើបខ្ញុំដឹងថា អ្នកទាំងអស់នោះយកខ្ញុំទៅពិសោធន៍ចង់ដឹងពីខ្ញុំថាតើរត់ ឬមិនរត់ ។ ពេលនោះ មិត្តទាំងអស់ប្រហែលជា ១០នាក់ បាននិយាយប្រាប់ខ្ញុំថា ឲ្យខ្ញុំជូនទៅបាញ់សត្វ ។ ពេលទៅដល់កន្លែងបាញ់សត្វ ក៏នាំគ្នាចុះបាត់អស់មិនដឹងជាទៅទីណាទេ ខ្ញុំនៅរង់ចាំក្នុងឡាន តែគ្មានឮសំឡេងកាំភ្លើងបាញ់សត្វទេ ខ្ញុំគិតក្នុងចិត្តថា អ្នកទាំងអស់គ្នាប្រហែលជាពួននៅក្បែរៗឡានខ្ញុំនេះទេ ចៃដន្យពេលនោះមានកុមារីម្នាក់កំពុងឃ្វាលគោនៅក្បែរនោះ ខ្ញុំក៏បានអង្គុយនិយាយលេងជាមួយកុមារីនោះអស់រយៈពេលជិតមួយម៉ោង ក៏នៅតែមិនឮសំឡេងកាំភ្លើងផ្ទុះដដែល ។ ខ្ញុំក៏ត្រឡប់មកអង្គុយរង់ចាំនៅកាប៊ីនឡានវិញ ហើយធ្វើជាច្រៀងលេងហាក់ដូចជាគ្មានរឿងអ្វីកើតសោះ ។ ខ្ញុំអាចធ្វើការសន្និដ្ឋានបានថា ពេលនោះបើខ្ញុំហ៊ានតែរត់អ្នកទាំងអស់គ្នានឹងចេញមកបាញ់សម្លាប់ខ្ញុំជាមិនខាន ។ ដោយឃើញថាខ្ញុំមិនមានសកម្មភាពអ្វីប្លែក មិត្តទាំងអស់នោះបានចេញពីព្រៃ ហើយហៅខ្ញុំឲ្យជូនត្រឡប់មកផ្ទះវិញ ។ ពេលនោះ ខ្ញុំបានសួរមិត្ត ឌឹម ថាអត់បានសត្វទេឬមិត្តបង? មិត្ត ឌឹម ធ្វើទឹកមុខស្មើ និងមិនស្តីជាមួយខ្ញុំសូម្បីតែមួយម៉ាត់ ។ ព្រឹកស្អែកឡើង អង្គការក៏បានឲ្យខ្ញុំរៀបខោអាវមកភ្នំពេញ ។ ខ្ញុំសូមរម្លឹកថា អ្នកបូព៌ានៅឃ្វាំងគ្រាប់ប្រហែលជា១០នាក់ ដែលខ្លះចេញពីក-៣ ខ្លះនៅកងទ័ព ខាំ មី ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ១៩៧៦ ហើយបានបញ្ជូនមកភ្នំពេញទាំងអស់ ។

ខ្ញុំនិងអ្នកទាំងនោះ ត្រូវបានបញ្ជូនឲ្យមកនៅក-៧វិញ ហើយអង្គការក៏ឈប់ចាត់ឲ្យខ្ញុំបើកឡានទៀតដែរ ។ ខ្ញុំដឹងថាអង្គការប្រាកដជាយកទៅលត់ជាដំមិនខាន ។ ខ្ញុំរួមជាមួយនឹងអ្នកទាំង១០នាក់នោះ ត្រូវអង្គការបញ្ជូនឲ្យទៅវត្តស្វែង (វត្តជ័យឧត្តម) ។ នៅទីនោះមានមនុស្សច្រើនណាស់ ខ្ញុំអាចនិយាយបានថារាប់ម៉ឺននាក់ ស្ទើរតែរកកន្លែងដេកគ្មាន ។ អង្គការបានដឹកយកមនុស្សទៅវាយចោលរាល់ថ្ងៃ ប៉ុន្តែខ្ញុំមិនដឹងថាមនុស្សទាំងនោះត្រូវអង្គការយកទៅទីណាខ្លះនោះទេ ។ ចំពោះវិន័យ និងសីលធម៌នៅកន្លែងនោះ គឺមិនអនុញ្ញាតឲ្យជំនុំគ្នាលើសពី៣នាក់ឡើយ ។ រីឯការងារវិញ អង្គការបានឲ្យធ្វើងារធ្ងន់ជាទីបំផុត ដោយត្រូវក្រោកតាំងពីម៉ោង៤ទាបភ្លឺធ្វើការរហូតដល់ម៉ោង១០យប់ ហើយឲ្យឈប់សម្រាកតែពេលហូបអាហារមួយភ្លែតប៉ុណ្ណោះ ។ អង្គការបានបញ្ជូនមនុស្សមកជាបន្តបន្ទាប់ ។ កន្លះខែក្រោយមក ខ្ញុំនិងមនុស្សមួយចំនួនទៀតត្រូវអង្គការផ្លាស់ឲ្យទៅធ្វើការនៅផ្លូវរថភ្លើងថ្មី មានសុទ្ធតែអ្នកបូព៌ាទាំងអស់ ដែលជាអតីតកម្មាភិបាល យុទ្ធជននៅតាមក្រសួង រោងចក្រនានា ។ កាលណោះ អង្គការមានផែនការធ្វើផ្លូវរថភ្លើងថ្មី ដែលដំណើរការដោយកម្លាំងអគ្គិសនីពីក្រុងកំពង់សោម ត្រង់ចំណុចវ៉ាសំរោងកាត់តាមផ្លូវជាតិលេខ៤ ឆ្ពោះមកភ្នំពេញ ។ ខ្ញុំកត់សម្គាល់ឃើញថា មានមនុស្សស្លាប់ច្រើននៅការដ្ឋានធ្វើផ្លូវរថភ្លើងថ្មីនេះ ។ ចំពោះអ្នកមានប្រវត្តិរូបមិនល្អ ក៏ត្រូវអង្គការយកទៅសម្លាប់ចោលជាហូរហែដែរ ។ បន្ទាប់ពីនោះមក មានការដ្ឋានធ្វើផ្លូវដែលអង្គការឲ្យធ្វើផ្លូវខាងលើ និងរថភ្លើងរត់ពីក្រោម ហេតុនេះតម្រូវឲ្យជីករូងភ្នំថែមទៀតនៅម្តុំត្រែងត្រយឹង ។ សំណាងល្អ នៅថ្ងៃនោះ អ្នកកាន់ម៉ាស៊ីនបុកគ្រឹះមិនស្រួលខ្លួនមិនបានមកធ្វើការទេ ពេលនោះ ខ្ញុំក៏សាកល្បងប្រើម៉ាស៊ីនបុកគ្រឹះនោះ ហើយទីបំផុតក៏អាចប្រើម៉ាស៊ីនបុកគ្រឹះនោះបាន ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានស្រួលខ្លួនជាងមុន ដោយអាចចៀសផុតពីការងាររែកដី ហើយបានកាន់ម៉ាស៊ីនបុកគ្រឹះនេះជាប់រហូតមក ។ នៅអំឡុងថ្ងៃទី២៨ ខែកញ្ញាដែលជាថ្ងៃខួបបក្ស ហេតុនេះអង្គការបានឲ្យប្រជាជនហូបអាហារតាមចិត្តមួយសេរីបានរយៈពេលមួយថ្ងៃពេញ ។ កាលណោះ មនុស្សមួយចំនួនបានស្លាប់ដោយសារតែការហូបច្រើនពេក (ហូបហល់) ។

បន្ទាប់មកទៀត មានការបះបោរមួយបានកើតឡើងនៅការដ្ឋានស្រែថ្កុង នៅក្បែរការដ្ឋានត្រែងត្រយឹងដែលខ្ញុំកំពុងតែធ្វើការដែរ ។ អ្នកទាំងនោះ ដែលភាគច្រើនជាអ្នកមកពីបូព៌ាបានធ្វើការបះបោរតវ៉ារឿងឲ្យហូបបាយមិនឆ្អែត ។ អ្នកទាំងអស់គ្នាបានលើកឡើងថា នឹងទៅប្តឹងដល់បក្សព្រោះជឿថាបក្សមិនមែនឲ្យហូប ប្រជាជនហូបមិនឆ្អែតអ៊ីចឹងទេ ពេលនោះអង្គការបានឆ្លើយតបថា នឹងដោះស្រាយបញ្ហានេះឲ្យ ។ លុះស្អែកឡើង អង្គការបានចាប់ខ្លួនអ្នកទាំងនោះគ្មានសល់ម្នាក់នៅក្នុងការដ្ឋាននោះ ហើយអ្នកទាំងនោះត្រូវបានអង្គការយកមកសម្លាប់ចោលនៅបឹងជើង

ឯក ។ អំឡុងពេលបះបោរ មិត្ត ដាំ មិត្ត ថៃ បានលើកឡើងថា សមមិត្តមិនត្រូវបះបោរឡើយ មិត្តណាហ៊ានបះបោរប្រាកដជាកំបុតក្បាលមិនខាន ។

ការយកមនុស្សពីការដ្ឋានរបស់ខ្ញុំទៅវាយចោល បានកើតមានឡើងជាហូរហែ ខ្ញុំជាមនុស្សម្នាក់មានវាសនាបានរស់រានមានជីវិតដោយសារចេះបច្ចេកទេសធ្វើការងារបម្រើអង្គការ ។ និយាយពីអ្នកបូព៌ាក្នុងចំណោម៥.០០០នាក់ ដែលបានឡើងទៅវគ្គជាមួយខ្ញុំ គឺត្រូវបញ្ជូនទៅនៅទីនេះទាំងអស់ ហើយអ្នកដែលនៅរស់មានជីវិត គឺមានតិចតួចណាស់ អាចនិយាយបានថា ខ្ញុំជាមនុស្សម្នាក់ដែលមានសំណាងជាងអ្នកដទៃទៀត ។ នៅពេលដែលខ្ញុំសម្រាករាល់ថ្ងៃមិនដែលមានអ្នកយាមទេ តែប៉ុន្មានថ្ងៃនេះមានអ្នកយាម ។

ខ្ញុំចាំបានថា ពេលនោះកងទ័ពវៀតណាមបានវាយចូលជិតមកដល់ហើយ ហេតុនេះអង្គការខ្លាចកងទ័ពវៀតណាមវាយមកដល់ ហើយកៀរយកអ្នកនៅក្នុងការដ្ឋាននេះទៅជាមួយ ព្រោះនៅទីនេះសុទ្ធតែអ្នកមកពីភូមិភាគបូព៌ា ។ តាមអ្វីដែលខ្ញុំដឹងទៀតនោះ ភាគច្រើនអ្នកភូមិភាគបូព៌ាដែលជាកងទ័ព អង្គការយកទៅដាក់ឲ្យធ្វើការនៅព្រលានយន្តហោះក្នុងខេត្តកំពង់ឆ្នាំង ដែលជាកន្លែងលត់ដំ ហើយក៏ជាកន្លែងវាលពិឃាតមួយដែរ ។ រីឯនៅការដ្ឋានផ្លូវរថភ្លើងថ្មីពីភ្នំពេញទៅកំពង់សោម ភាគច្រើនជាជនស៊ីវិល និងមានលាយយោធាមួយចំនួនតែប៉ុណ្ណោះ ។

នៅខែសីហា ឆ្នាំ១៩៧៨ កាលណោះខ្ញុំបានជួបលោកពូ ជុំ ហ៊ល់ ដែលជាមេចាស់របស់ខ្ញុំកាលពីចូលបដិវត្តន៍ដំបូង គឺជួបនៅពេជ្រនិលដែលជាកន្លែងស្នាក់ការធ្វើផ្លូវរថភ្លើងថ្មី ។ ខ្ញុំបានសួរគាត់ថា «លោកពូអញ្ជើញមកដល់ទីនេះដែរ? គាត់ឆ្លើយថាបាទ» ហើយគាត់ក៏បានកេះខ្ញុំឲ្យទៅកៀនព្រៃនៅក្បែរនោះ ហើយបាននិយាយតិចៗថា «កុំមាត់ កុំនិយាយអ្វីផ្ដេសផ្ដាស យើងត្រូវដាំដើមគណាក្លួយ» គាត់បាននិយាយបន្តទៀតថា «ខ្ញុំបានមកដេកពេទ្យ១៧មេសា (ពេទ្យរុស្ស៊ី) ដោយមានបញ្ហាសុខភាព» ។ នៅពេលដែលអង្គការសួរ គាត់បានឆ្លើយថា គាត់ជាប្រជាជនសាមញ្ញអត់មានធ្វើការងារអ្វីទេ បន្ទាប់មក អង្គការបានបញ្ជូនឲ្យគាត់មកកន្លែងនេះ ។ ពូ ជុំ ហ៊ល់ បានសួរបន្តថា ក្មួយកូនចៅអ្នកណា ហើយរស់នៅឯណា គាត់ចាំមិនបានទេ ។ ខ្ញុំក៏ឆ្លើយតបគាត់វិញថា ខ្ញុំនៅត្រពាំងក្រពើ ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ឪពុកឈ្មោះ សេន ម្ដាយឈ្មោះ រឿន ជាប្រធានភូមិ មីងឈ្មោះ សារួន ពូឈ្មោះពូ យ៉ែន ធ្វើជាប្រធានកងឈ្លបឃុំមង់រៀវ ដែលជាកូនចៅលោកពូពីមុននោះ ខ្ញុំតែងតែដើរលេងសិល្បៈ កាលពីជំនាន់ដើរឃោសនាការងាររណសិរ្សជាមួយក្រុមយោធា លោកពូពីមុននោះ និងក្រោយមកក្លាយជាអ្នកប្រមូលស្បៀងប្រចាំនៅឃុំមង់រៀវ ដែល ពូ និងបង ទន់ គ្រី បងរតនា និង តាផល្លា តាម៉ាលី មេយោធាតំបន់២១ ។ ពេលរម្លឹកត្រង់នេះ ទើបលោកពូ ជុំ ហ៊ល់ នឹកឃើញឡើងវិញ ហើយបានសួរថា ឯងឈ្មោះអី? ខ្ញុំក៏បានប្រាប់គាត់វិញថាឈ្មោះ សរ សារិន គាត់បានបន្តថា ឯងប៉ុនដើរតួកាលពីនៅលេងសិល្បៈ ឯងប៉ុននិយាយធ្វើចុកពោះ ធ្វើជាយំពេលព្រាត់ម៉ែឪនៅពេលយន្តហោះទម្លាក់គ្រាប់បែក ខ្ញុំឆ្លើយថាបាទ ទើបគាត់នឹកឃើញកាន់តែច្បាស់ ហើយពូ ជុំ ហ៊ល់ បានបន្តសួរទៀតថា កុំប្រកាន់គាត់ធម្មតាទេ មេតែម្នាក់ ចំណែកឯកូនចៅរាប់រយនាក់អ៊ីចឹងចំណាំមិនបានអស់ទេ ខ្ញុំក៏ឆ្លើយតបទៅគាត់វិញ បាទ! ខ្ញុំមិនប្រកាន់ទេ ។ ពូបានបន្តទៀតថា រិន ឯងកុំនិយាយអំពីតួនាទីរបស់ពូអីទាំងអស់ថា តែពូជាជនស៊ីវិលធម្មតាបានហើយ ។

ការដួលរលំនៃរបបខ្មែរក្រហមថ្ងៃមួយនៅការដ្ឋាន ខ្ញុំបានឮសំឡេងមេក្រូចាក់បទគោរពទង់ជាតិទាំងព្រឹក ។ ខ្ញុំឆ្ងល់ក្នុងចិត្តថាប្រហែលជាអ្នកចាក់មេក្រូចាក់ច្រឡំហើយ ។ ពីរម៉ោងក្រោយមក កម្មាភិបាលដែលមកពីភ្នំពេញ បានចេញទៅប្រកាសប្រាប់ថា យួនចូលដល់ទីក្រុងភ្នំពេញហើយ ។ ប្រហែលជាបីបួនម៉ោង មានមួយក្រុមមកពីខាងកំពង់សោម និងវាលរេញទៀត បានប្រាប់ដូចគ្នាថា យួន បានចូលដល់កំពង់សោមហើយ ។ ខ្ញុំគិតសង្ស័យក្នុងចិត្តអំពីដំណឹងនេះ មិត្តដែលនៅការដ្ឋានជាមួយខ្ញុំបានប្រាប់ថា គាត់មិននៅគាំទ្រទៀតទេ ហើយខ្ញុំក៏មិនទាន់ហ៊ានបញ្ចេញសកម្មភាពអ្វីដែរ ។

មិត្ត អួន និងប្រពន្ធ បានគេចបកទៅក្រោយវិលត្រឡប់ទៅស្រុកកំណើតវិញ ប៉ុន្តែត្រូវខ្មែរក្រហមចាប់បានហើយបានបាញ់សម្លាប់ចោលនៅចិញ្ចើមផ្លូវតែម្ដង ។ ពេលនោះ កម្មាភិបាលខ្មែរក្រហមម្នាក់បានប្រកាសថា មិត្តទាំងអស់គ្នាត្រូវធ្វើដំណើរឆ្ពោះទៅជើងភ្នំគីរីរម្យ អត់មានចលាចលទៅណានោះទេ ។ ពេលនោះខ្ញុំ

ឃើញកម្លាំងទ័ពខ្មែរក្រហមមកជុំគ្នាយ៉ាងច្រើន និងមានអាវុធគ្រប់ដៃ ។ តាំងពីពេលនោះមក ការរស់នៅមានភាពធូរស្រាលជាងមុន ខ្ញុំបានហូបឆ្អែត និងមានសិទ្ធិដើរបេះផ្លែឈើព្រៃហូប ។ កាលណោះ ទម្រាំវៀតណាមវាយយកបានម្តុំត្រែងត្រយឹងនេះ បានប្រហែលជាបីខែ បើទោះបីជាវៀតណាមវាយយកភ្នំពេញបានហើយក៏ដោយ ។ យើងទាំងអស់គ្នាធ្វើដំណើរជាមួយកងទ័ពខ្មែរក្រហមទៅដល់គិរីរម្យចុះទៅជើង ដែលគេហៅថាទំនប់ក្រាំងដីហ្វាយ ហើយបាននៅទីនោះប្រហែលជាកន្លះខែ ។ ខ្ញុំក៏មិនដឹងសភាពការណ៍របស់ស្រុកទេសយ៉ាងណាដែរ ព្រោះមិនមានវិទ្យុស្តាប់ ហើយនៅពេលយប់ឮតែសំឡេងផ្ទុះឃ្លាំងគ្រាប់នៅកំពង់ស្ពឺ ។ ក្នុងចិត្តអរក៏អរ ភ័យក៏ភ័យ ព្រោះខ្លាចខ្មែរក្រហមប្រមូលយកទៅវាយចោល ។ ក្នុងអំឡុងពេលនោះ មានមនុស្សស្លាប់ច្រើនណាស់ ឃើញសាកសពដេកស្លាប់ពេញតែដីហើយគាត់បានកាត់សក់ឲ្យខ្ញុំនៅក្រោមដើមកណ្តោល ក្រោយសហករណ៍ក្រគួត ។ កាត់សក់បណ្តើរ លោកពូនិយាយខ្សឹបៗបណ្តើរប្រាប់ថា កងទ័ពវៀតណាមមិនមែនសម្លាប់ប្រជាជនខ្មែរយើងដូចពាក្យឃោសនារបស់អង្គការបានលើកឡើងនោះទេ ។ ខ្ញុំមានការភ្ញាក់ខ្លួនព្រឺតដោយបានដឹងពីព័ត៌មាននេះ ព្រោះខ្ញុំមិនដែលបានឮពាក្យទាំងនេះទេ ។ ពូ ជុំ ហ៊ិល់ បានបន្តថា ក្មួយឯងកុំជ្រួលច្របល់ ចាំថ្ងៃណាថ្ងៃនោះទៅ ។ ពាក្យមួយឃ្លាដែលលោកពូ ជុំ ហ៊ិល់ បានខ្សឹបប្រាប់ពីរឿងដែលវៀតណាមមិនសម្លាប់ប្រជាជនខ្មែរនោះ បានដិតជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំជានិច្ច ។ រូបរាងកាយរបស់លោកពូ ជុំ ហ៊ិល់ ស្គមដូចព្រះស្រ្គម ដោយគាត់មានសុខភាពមិនសូវល្អផង ហើយទទួលទានក៏មិនបានគ្រប់គ្រាន់ទៀត ។ សហករណ៍បានធ្វើកូនតូបមួយនៅកៀនរបងក្រោមដើមអំពិលដាច់ឆ្ងាយពីគេ និងពូ ហ៊ិល់ ត្រូវបានអង្គការឲ្យនៅអង្គភាពផ្សេងគ្នា ។ ថ្ងៃមួយអង្គការបានឲ្យទៅរកត្រីនៅតាមស្ទឹងតាសាល ស្ទឹងកន្ទួត បានលាក់ត្រីបួនប្រាំដោយមូរនឹងចង្កេះខោរួចពាក់អាវពីលើដោយមិនឲ្យនរណាឃើញឡើយ លុះមកដល់តូបពូ ជុំ ហ៊ិល់ ខ្ញុំក៏បានខ្សឹបប្រាប់គាត់ថា បានត្រីជូនពូ ខ្ញុំក៏អង្គុយបន្តិចមើលនាយមើលអាយដោយខ្លាចអង្គការឃើញ ហើយក៏បានដាក់ត្រីក្នុងកំសៀវដាំទឹក ។ បើសិនជា អង្គការបានឃើញប្រាកដជាអង្គការយកយើងទៅសម្លាប់ចោល ហើយនៅពេលនោះ ។ ពេលបានត្រីហើយ ពូ ជុំ ហ៊ិល់ ត្រេកអរខ្លាំងណាស់ គាត់បាននិយាយថា ពេលនេះ ពូនឹងមានកម្លាំង និងបានរស់ឡើងវិញហើយ ខ្ញុំក៏ខ្សឹបប្រាប់គាត់វិញថា យើងនឹងរត់ចូលមកខាងលោក ហេង សំរិន ។ ពូ ជុំ ហ៊ិល់ បាននិយាយតិចៗថា មិនបានទេណាក្មួយ យើងមិនស្គាល់ភូមិសាស្រ្ត ហើយតាមកងតាមក្រុមអង្គការនៅតែក្តាប់យ៉ាងណែនដដែល កុំអាលជ្រួលច្របល់សម្របខ្លួនទៅតាមសភាពការណ៍សិនទៅក្មួយ ។

ក្រោយមកខាងសហករណ៍ បានបែងចែកមនុស្សជាក្រុមៗយកទៅលត់ដំនៅឆ្ងាយពីកន្ទួតប្រហែល១០គីឡូម៉ែត្រ ហើយមិនមានបាយបរិភោគទេ គឺមានតែពោតក្រហមមួយមុខគត់ ។ នៅកន្លែងនោះពេលសម្រាកយើងអាចលួចរកអាហារ ឬបរបាញ់សត្វបាន ។ ពេលមួយ ប្រធានសហករណ៍ ជាជនជាតិគួយបានដឹងរឿងនេះ ក៏និយាយជាមួយនឹងសំឡេងរដឹនៗប្រាប់អ្នកទាំងអស់គ្នាថា កន្លែងនេះគឺជាកន្លែងវែងស្មែ សមមិត្តទាំងអស់គ្នាកុំធ្វើតាពីសតាពាស ងាប់ណា! ត្រូវតែប្រឹង! ។

ក្រោយមកទៀត ដោយវៀតណាមចេះតែបន្តវាយយើងក៏រត់ភៀសខ្លួនពីកន្ទួតទៅក្នុងព្រៃឆ្កោះទៅរលាក់កងជើង ។ ពេលមកដល់រលាក់កងជើង ការរស់នៅបានធូរស្រាលជាងមុនច្រើន ។ មកនៅទីនេះបានកន្លះខែ យើងមិនមានអាហារបរិភោគក្រៅពីដំឡូងនោះទេ ហើយប្រជាជនដែលជាជនជាតិភាគតិចរស់នៅទីនេះមានការរាប់អាន និងស្មោះត្រង់ណាស់ ព្រមទាំងបានបង្ហាញអ្នកភៀសខ្លួនទាំងអស់នៅកន្លែងណាដែលយើងអាចរកដំឡូងបាន ។ ខ្ញុំនៅចាំបានថា ដំឡូងនៅពេលនោះ យើងជីកបានទាំងបាវៗ គឺជីកបានច្រើនណាស់ ។ នៅរលាក់កងជើងបានកន្លះខែក្រោយមក អង្គការបានជម្លៀសបន្តឲ្យមកខាងឱរ៉ាល់វិញ ។ ពេលនោះ អង្គការបានយកមនុស្សចេញចំនួនច្រើនដែរ ដោយប្រាប់ថា យកទៅប្រមូលផលស្រូវនៅភូមិភាគពាយ័ព្យ ។ ខ្ញុំក៏ជាមនុស្សម្នាក់ក្នុងចំណោមអ្នកឯទៀតដែរ ដែលត្រូវធ្វើដំណើរទៅភូមិភាគពាយ័ព្យ ។ យើងបានធ្វើដំណើរមកដល់លាច ខេត្តពោធិ៍សាត់ ។ យើងបានសម្រាកនៅលាចនេះប្រហែលជា១០ថ្ងៃ ហើយក្នុងអំឡុងពេលនោះ ខ្ញុំបានជួបមិត្តចាស់ៗដែលនៅស្គាល់គ្នានៅភ្នំពេញជាច្រើន ដូចជាអ្នកនៅក-៦ និងនៅពេទ្យ១៧មេសាជាដើម ។ អ្នកទាំង

អស់គ្នាបានលួចខ្សឹបប្រាប់ខ្ញុំថា អ៊ី ដួន ជឿន ក៏នៅលាចនេះដែរ ។ បើតាមខ្ញុំយល់ ប៉ុល ពត ប្រហែលជានៅទីនេះដែរ ព្រោះឃើញអ្នកនៅមន្ទីរក-៦ ក-៧ នៅទីនោះដែរ ។ ក្រោយមកទៀត យើងក៏ឲ្យបន្តដំណើរទៅខាងតាលោ ដែលនៅកៀកនឹងព្រែកជីក១៧មេសា ហើយទៅដល់សហករណ៍ដំណាក់រុននោះ មានមនុស្សកកកុញ ។ ទីនោះអង្គការបានយកមនុស្សទៅសម្លាប់ចោល ឲ្យតែអ្នកមកពីភូមិភាគបូព៌ា ហើយនៅពេលដែលគេសួរ ខ្ញុំបានឆ្លើយថា ខ្ញុំជាអ្នកនិរតី ទើបបានរួចជីវិតមកដល់ពេលនេះ ។ បើតាមខ្ញុំយល់ មានការកាប់សម្លាប់អ្នកបូព៌ានៅពេលនោះខ្លាំងជាងជំនាន់វៀតណាមមិនទាន់ចូលទៀត ។ អ្នកដែលមានបងប្អូននៅខាងស្វាយរៀង និងព្រៃវែង ខ្លះបានដឹងហើយថា អ្នកដែលមានជីវិតមកស្រុកកំណើតវិញ គឺមានចំនួនតិចតួចណាស់ ឧទាហរណ៍ បើទៅ១០០នាក់ មកវិញបានតែ២០ ទៅ៣០នាក់ប៉ុណ្ណោះ ។ ហេតុនេះហើយបានជាខ្ញុំលើកឡើងថា មនុស្សចំនួន៥.០០០នាក់ មិនមាននៅសេសសល់ទេគឺស្លាប់បង្ហើយនៅសហករណ៍អូរត្រជាក់ចិត្តនោះតែម្តង ។

ក្រោយមក កងទ័ពវៀតណាមបានតាមមកវាយទៀត ខ្ញុំត្រូវរត់ទៅតាមខ្មែរក្រហម ។ កាលណោះ បើអ្នកណាមានបំណងចង់រត់ ខ្មែរក្រហមនឹងបាញ់សម្លាប់ចោលតែម្តង ។ ខ្មែរក្រហមបានកៀរអ្នកទាំងអស់គ្នាឡើងលើភ្នំតាផ្ដេរ ហើយរស់នៅលើភ្នំបានប្រហែលជាមួយទៅពីរខែដែរ ។ ថ្ងៃមួយ ខ្ញុំបានទៅឃ្លាំងកាំភ្លើងនៅចុងស្ទឹងមោង ពេលនោះខ្មែរក្រហមបានបើកកាំភ្លើងឲ្យម្នាក់បីដើម បេ-១៩មួយដើម និងដេកា២ដើម ប៉ុន្តែកាំភ្លើងទាំងនោះមិនមានគ្រាប់ទេ ។

ការវិលត្រឡប់មកស្រុកកំណើតវិញ ក្រោយមកបន្ទាប់ពីអង្គការបានចែកកាំភ្លើងហើយ ខ្ញុំបានស្នើសុំគ្រាប់អង្គការបានបីបួនគ្រាប់ ។ ពេលនោះ ខ្ញុំមានកូនចិត្តមួយចង់រត់ហើយ ខ្ញុំបានគិតថាពេលនេះបើខ្ញុំមិនរត់ទេ គឺមិនបានទេ ។ ខ្មែរក្រហមបានប្រើក្រុមខ្ញុំឲ្យដើររកបន្លែរហូតដល់សហករណ៍ត្រជាក់ចិត្តដែលខ្ញុំធ្លាប់រស់នៅពីមុនមក ។ នៅតាមផ្លូវ ខ្ញុំបានឃើញសាកសពជាច្រើននៅក្នុងព្រៃ និងនៅតាមស្ទឹងព្រែកជីក ។ ក្រោយមក ខ្ញុំសន្សំបានគ្រាប់ច្រើនគួរសម ហើយខ្ញុំក៏បាននិយាយបំផុសសមាជិកក្នុងក្រុមឲ្យរត់គេចចេញពីខ្មែរក្រហម ។ បន្ទាប់មក ខ្ញុំចាប់ផ្តើមរៀបចំគម្រោងការដើម្បីរត់គេច ។ ប្រហែលជាម៉ោង៥ល្ងាច កងទ័ពចាប់ផ្តើមចេញដំណើរ ខ្ញុំក៏ប្រាប់ក្រុមឲ្យធ្វើដំណើរបើឃើញខ្ញុំឈប់ ឲ្យឈប់តាមខ្ញុំ ។ ខ្ញុំឲ្យមិត្តម្នាក់ឈ្មោះ ហុង ធ្វើពុតជាឈឺកោសខ្យល់ ហើយទ័ពក៏មិនចាប់អារម្មណ៍ ព្រោះមនុស្សធ្វើដំណើរនៅពេលនោះច្រើន ។ ខ្ញុំនិងសមាជិកក្រុមបានរត់បកមកក្រោយវិញ ប្រហែលជានៅក្នុងខែកក្កដា ព្រោះឃើញពោតចេញស្មៀតហើយ ប្រជាជនយើងបាននាំគ្នាស្ទូងស្រូវហើយដែរ ។ ពេលមកដល់ទំនប់មួយខាងត្បូងតាលោ ខ្ញុំបានបោះកាំភ្លើងចោល ហើយបានធ្វើដំណើរចូលភូមិ ខ្ញុំក៏បានឃើញអ្នកភូមិកំពុងដកសំណាប ពេលនោះអ្នកភូមិបានមកចោមរោមខ្ញុំជិត ហើយមានចំពាមកៅស៊ូនៅនឹងដៃម្នាក់មួយ និងឃើញមានកាន់កាំភ្លើងសេកាសេមួយដើមផង ។ ខ្ញុំបានដោះអាវនៅតែខ្លួនទទេដើម្បីបង្ហាញថា ខ្ញុំជាប្រជាជនធម្មតាមកពីភូមិភាគបូព៌ាមិនមានអាវុធអ្វីទេ ។ ក្រោយមក អ្នកភូមិបានសួរនាំរកបងប្អូនកូនចៅ ខ្ញុំបានឆ្លើយថា មានបងប្អូនច្រើនណាស់ដែលត្រូវខ្មែរក្រហមសម្លាប់ និងកៀរយកទៅជាមួយ ។

ខ្ញុំបានស្នាក់នៅភូមិនោះ (មិនចាំឈ្មោះ) បានពីរថ្ងៃ ក៏សុំអ្នកភូមិធ្វើដំណើរមករកឪពុកម្តាយ និងបងប្អូននៅស្រុកកំណើតឯកំពង់ចាមវិញ ។ ខ្ញុំបានធ្វើដំណើរពីខេត្តពោធិ៍សាត់ទៅដល់កំពង់ចាម ដោយប្រើរយៈពេលមួយខែ ។ អំឡុងពេលធ្វើដំណើរ ប្រជាជនបានប្រាប់ខ្ញុំថា ប្រសិនបើជួបកងទ័ពវៀតណាមសូមកុំរត់ប្រយ័ត្នវៀតណាមបាញ់ ហើយបើវៀតណាមសួរ គ្រាន់តែប្រាប់ថា យើងធ្វើដំណើរទៅស្រុកកំណើត ។ ខ្ញុំបានធ្វើដំណើរមកដល់ឧដុង្គ ពេលនោះរដ្ឋអំណាចមិនអនុញ្ញាតឲ្យធ្វើដំណើរដោយថ្មើរជើងទេ ហើយបានឲ្យជិះឡានឆ្លងភ្នំពេញ រហូតដល់ស្ពានច្បារអំពៅ រួចធ្វើដំណើរបន្តទៅតាមខេត្តព្រៃវែង ទើបបន្តដំណើររហូតដល់ផ្ទះនៅកំពង់ចាម ។

ទៅដល់ផ្ទះ ម្តាយខ្ញុំបានឃើញ គាត់មានសេចក្តីត្រេកអរណាស់ ។ ក្រោយមក ខ្ញុំក៏បានរៀបការប្រពន្ធ និងចូលធ្វើការជាអ្នកបើកឡានរហូតដល់រាល់ថ្ងៃ ។ បច្ចុប្បន្ននេះ ខ្ញុំរស់នៅជាមួយគ្រួសារ ដែលមានកូនប្រុសស្រី៥នាក់ (ប្រុស២នាក់) ព្រមទាំងមានចៅ១០នាក់ ចំណែកកូនៗរបស់មានគ្រួសារអស់ហើយ ។

**ស សារិន**

# ព្រលឹងមាសម្តាយ

***(ពីលេខមុន)***



*អ៊ុង វណ្ណា*

*ឱ! អ្នកម្តាយក្នុងលោកអើយ! តើម្តាយឯណាដែលមិនឈឺផ្សា នៅពេលឃើញកូនព្រលឹងមាសរបស់ម្តាយដែលអ្នកម្តាយស្រឡាញ់ស្មើកែវភ្នែក ដែលអ្នកខំថ្នាក់ថ្នមតាំងពីតូចក្រូចឆ្មារមក សូម្បីតែស្រមោចសង្គារមួយ ក៏អ្នកមិនអនុញ្ញាតឲ្យវារលើកូនប្រុសស្រីរបស់អ្នកបាន អ្នកម្តាយដែលលះបង់អ្វីៗទាំងអស់ដែលអ្នកមាន អ្នកម្តាយដែលស៊ូហែលឆ្លងការលំបាកគោកយ៉ាកសព្វបែបយ៉ាងដើម្បីការចិញ្ចឹមបីបាច់បុត្រធីតាឲ្យធំធាត់លូតលាស់ និងរុងរឿង តើអ្នកឈឺផ្សាយ៉ាងណានៅពេលដែលអ្នកដឹងថា កូនមាសរបស់អ្នកត្រូវគេដឹកទៅសម្លាប់ ដោយត្បូងចបទាំងខ្សែៗ ក៏ដូចជាមើលឃើញកូនដែលរស់នៅស្ទើរផុត និស្ស័យជាមនុស្សរស់ហួសនរកយ៉ាងនេះ ។ ពេលនេះសូម្បីតែអត្ថបទទុក្ខម្តាយទុរគតរបស់ព្រះមហាវិរិយបណ្ឌិត ប៉ាង ខាត់ ដែលលាតសន្ធឹងពីទុក្ខអ្នកម្តាយមួយរូបក្នុងរឿងក្រខ្សត់ព្រាត់ប្រាស់ស្វាមីនោះ ក៏នៅតែមិនអាចលាតសន្ធឹងពណ៌នាឲ្យអស់នូវទំហំនៃទុក្ខសោករបស់មាតាខ្មែរគ្រប់រូបពេលនេះបានឡើយ ។ តើមានអ្វីប្រដូចបានវាស់ជម្រៅទុក្ខលំបាកនៃការឈឺចាប់របស់អ្នកម្តាយដែលឈឺផ្សាចំពោះទុក្ខវេទនារបស់កូនមាសស្ងួននៃអ្នកម្តាយក្នុងមហាវាលទុរភិក្ស និងវាលពិឃាតនេះបាន ។*

*ឱ! ដើមរកាដែកដែលកំពុងដុងចាក់រូងឆ្អូតព្រលឹងខ្មោចជាប់ទោសឲ្យហូរឈាម ស្រោចរលេះរូចត្រូវយមរាជចងដៃចងជើងបោះចូលទៅទឹកខ្ទះដែលកំពុងពុះ តើអ្នកឈឺចាប់យ៉ាងណា? មានក្តីឈឺចាប់របស់អ្នកម្តាយខ្មែរ របស់ជនជាតិខ្មែរគ្រប់រូបនៅពេលនេះបាន ។ ឋាននរកតាមរយៈរឿងល្ខោនទាំងនោះ ជាក់ស្តែងប៉ុណ្ណោះ តែនរកលោកិយពេលនេះ វាស្តែងជាងរឿងល្ខោនទៅទៀត ពីព្រោះជាតិខ្មែរ ជនខ្មែរគ្រប់រូបត្រូវដើរតួគ្មានសល់ម្នាក់ ហើយម្នាក់ៗសុទ្ធតែជាតួឯក ទោះបីយុទ្ធជន កម្មាភិបាលរំដោះក្តី ពលទាហាន នាយទាហានក្តី ប្រជាពលករ និស្សិត បញ្ញវន្ត ធនធានមនុស្សដែលចេញមកពីវត្តអារាមក្តី ស្តេច រាស្ត្រ មន្ត្រី គ្រប់ជាន់ថ្នាក់ក្តី សុទ្ធតែជាតួអង្គឯកគ្មានសល់ម្នាក់ ជាតួឯកដែលត្រូវគេរៀបចំឲ្យសម្តែងយ៉ាងស័ក្តិសមឥតខ្ចោះ ទាំងការភរកុហកក៏ឥតខ្ចោះ ទាំងការបោកប្រាស់ក៏ស្រស់ឥតខ្ចោះ រហូតដល់ការកាប់សម្លាប់ ក៏សាហាវឥតខ្ចោះ ការបំផ្លាញជាតិខ្លួនឯងក៏ព្រៃឥតខ្ចោះ ឯអ្នករងគ្រោះក៏ត្រូវវេទនាឥតខ្ចោះ ឱ! ជីវិតតួឯក ដ៏គ្មានសិទ្ធិអំណាចចាត់ចែងដោគវាសនាក្នុងដៃខ្លួនឯងអើយ ចូរប្រយោគមើលអាត្មាអ្នកចុះ ។*

## ***អង្គការមានតែមួយ ឬពីរ? រកស្ថានមិនដល់***

*សំណួរនេះបានចោទជាចម្ងល់យ៉ាងប្រេះស្រាំនៅក្នុងអារម្មណ៍ប្រជាជនថ្មី ភូមិខ្លែងជួរ ។ រដូវបម្រូត ឆ្នាំ១៩៧៦ ដោយការអត់បាយ អត់ទាំងទឹក អ្នកភូមិខ្លែងជួរ ខ្លះបានត្រាច់ចររកបន្លែរហូតទៅដល់ថ្នល់ ដើម្បីទៅរើសក្ទួរស្រូវនៅសហករណ៍ក្រកោះ ដែលនៅជាប់ទីផ្លូវជាតិលេខ៥ ក្នុងចម្ងាយ៤៥គីឡូម៉ែត្រ មុនទៅដល់ទីរួមខេត្តបាត់ដំបង បើយើងធ្វើដំណើរពីភ្នំពេញទៅ ។ ក្រកោះជាសហករណ៍យោធាដែលធ្វើស្រែដោយត្រាក់ទ័រ ច្រូតកាត់មិនទាន់ពេល ព្រោះកម្លាំងយោធាមានតិចធ្វើឲ្យស្រូវទុំទន់បាក់ក ជ្រុះក្ទួរក្រហមប្រាលនៅពេញវាលស្រែ ក្រោយពេលប្រមូលផលរួច ។ ដំណឹងនេះធ្វើឲ្យអ្នកខ្លែងក្ទួរឆ្លៀតឱកាសលាក់លួចពីភ្នែកអង្គការស្ទុះស្ទែងមករករើសក្ទួរស្រូវនេះយ៉ាងភ្លូកទឹក*

ភ្ជួកដី ។

កម្មាភិបាលយោធាក្រកោះ បានដាំបាយឲ្យប្រជាជនទៅរើសក្តួរលើកទី១ ហូបមួយចម្អែត ។ មានមនុស្សពីរនាក់ហូបច្រើនរហូតដល់ទៅហល់ស្លាប់ ដោយសារតែការស្រេក ឃ្លានដាច់សង្វែងដ៏យូរឆ្នាំ ព្រឹត្តិការណ៍នេះបង្កើតឡើងនូវចម្ងល់ធ្វើឲ្យសមមិត្តយោធាដេញដោលសាកសួរអំពីស្ថានភាពរស់នៅឯសមរភូមិក្រោយរបស់ប្រជាជន ។ យើងខំតស៊ូលះបង់សាច់ស្រស់ ឈាមស្រស់ ដើម្បីរំដោះប្រជាជនពីចក្រពត្តិមក តើនៅសមរភូមិក្រោយគេឲ្យបងប្អូនហូបចុកយ៉ាងណា បានជាបងប្អូនស្រេកឃ្លានហួសនិស្ស័យយ៉ាងនេះ ។ សំណួររបស់សមមិត្តប្រធានអង្គភាពយោធាក្រកោះ ។

យើងបានទទួលរបបអង្ករមួយស្លាបព្រាក្នុង១ថ្ងៃ ។ មានពេលខ្លះយើងដាច់របបរហូតដល់ទៅ១៣ថ្ងៃ ខ្ញុំសូមសមមិត្តបងមេត្តាអភ័យទោស ។ ប្រជាជនថ្មីរ៉ៃយចំណាស់ម្នាក់ ពោលដោយលើកដៃប្រណម្យផង ។

បើដូច្នោះមែន សូមបងប្អូនទៅនាំក្រុមគ្រួសាររត់មករួមរស់ជាមួយយើងខ្ញុំចុះ យើងខ្ញុំនឹងបើកសហករណ៍បដិវត្តន៍ស្រូវវស្សាមួយជូនបងប្អូនពុកម៉ែមារមីង ។ ប្រសាសន៍របស់កម្មាភិបាលយោធា ។

ឱ ! មិនស្មានសោះ ស្មានមិនដល់ទាល់តែសោះថា អង្គការមានទស្សនៈ និងទឹកចិត្តខុសគ្នាដូចមេឃ និងដីយ៉ាងនេះ! ពេលនេះយើងទើបតែយល់ថា អង្គភាពយោធាក្រកោះនេះ នៅមានទឹកចិត្តទស្សនវិស័យល្អស្មោះសនឹងប្រជាជនដូចជាអ្វីៗដែលកងទ័ពរំដោះឆ្នាំ១៩៧០-១៩៧១ សម័យដែលសង្គ្រាមទើបនឹងចាប់ផ្តើមឡើងបានសម្តែងចេញ ធ្វើឲ្យប្រជាជនស្រឡាញ់គោរព និងប្តូរផ្តាច់ស្លាប់រស់ជាមួយយុទ្ធជនបដិវត្តន៍ ធ្វើឲ្យប្រជាជនហ៊ានលះបង់កូនចៅប្តីសីសុខចិត្តផ្តាច់ពីមាត់ពង្រាត់ពីកនូវស្បៀងអាហារប្រាក់កាសដ៏ក្រខ្សត់ខ្សោយនៃសេដ្ឋកិច្ចគ្រួសារ ដើម្បីជួយជំរុញចលនាបដិវត្តន៍ឲ្យដើរទៅមុខ ។ តើអង្គការមានតែមួយឬពីរ? ចម្ងល់នេះបានកើតឡើងនៅក្នុងទឹកចិត្តប្រជាជនថ្មីនៃភូមិខ្លែងជួរគ្រប់ៗរូប ។

គិតទៅឆន្ទះពិតរបស់រៀមច្បងយោធា គឺលះបង់អ្វីទាំងអស់ដើម្បីបដិវត្តន៍ដើម្បីប្រជាជន និងប្រទេសជាតិ! ហើយលោកក៏មិនដឹងរឿងពិតនៃទុក្ខវេទនារបស់ប្រជាពលរដ្ឋដែរ? តើការពិតធាតុពិតចរិតពិតរបស់បដិវត្តន៍យ៉ាងណាទៅ? តើអាចមានបដិវត្តន៍មួយទៀតកើតឡើងបានឬទេ? រកយល់មិនបានស្មានមិនត្រូវទាល់តែសោះ ។ ប្រជាជនថ្មីម្នាក់ៗ ចោទសំណួរបែបនេះមកលើខ្លួនឯងនេះ គឺជាសំណួរគ្មានចម្លើយ ។

ចលនារត់មកកាន់សហករណ៍យោធា បានក្លាយជាចលនាលួចភៀសខ្លួនពីក្នុងតំបន់រំដោះទៅកាន់តំបន់រំដោះ យ៉ាងភ្ជួកទឹកភ្ជួកដីប្រជាជនថ្មីមកពីភូមិជាច្រើនក្នុងស្រុកគាស់ក្រឡ តំបន់១បាននាំគ្នារកមធ្យោបាយចាកចេញដោយសម្ងាត់មកតាំងទីលំនៅនៅភូមិថ្មីឃុំក្រកោះ តំបន់៤ ។

ថ្ងៃនេះ វគ្គបើកការដ្ឋានស្រូវវស្សារបស់យើងចាប់ផ្តើមហើយសមមិត្ត ខូយ អនុប្រធានភូមិភាគពាយ័ព្យបានដឹកនាំកិច្ចប្រជុំបើកវគ្គសម្រុកប្រមូលផលលើកនេះ បងប្អូនយើងត្រូវចេញពលកម្មទាំងអស់គ្នា ទុកចោលសម្ភារស្លួនតួជាប់នឹងខ្លួន ក្នុងទីជម្រករបស់បងប្អូន ដែលជួនកាលអាចមានជារបស់មានតម្លៃខ្ពស់ មានមាសពេជ្រកែវកងជាដើម ហើយវាអាចបាត់បង់ដោយប្រការណាមួយ អង្គការមិនអាចជួយថែរក្សាឲ្យបងប្អូនបានឡើយ ដូច្នេះហើយ អង្គភាពសូមឲ្យបងប្អូនត្រូវតែស្មោះត្រង់មកចុះក្នុងបញ្ជីរតនភណ្ឌផ្ទាល់ខ្លួនទាំងនេះ ចំពោះមុខអង្គការឲ្យបានគ្រប់ចំនួន បើពុំដូច្នោះទេ ថ្ងៃណាមានការបាត់បង់ទើបបងប្អូនមកប្តឹងនោះ អង្គការពុំអាចទទួលខុសត្រូវបានឡើយ ។ ក្នុងនាមពុកម៉ែ ប្រជាជន អង្គការសូមសន្យាជាមួយប្រជាជនថា ទង្វើបែបនេះ អង្គការគ្មានបំណងណាផ្សេង ក្រៅពីការថែរក្សាសុវត្ថិភាពជូនពុកម៉ែឡើយ បើថ្ងៃក្រោយទៅអង្គការធ្វើអ្វីក្រៅពីពាក្យសន្យានេះ ដូចជាហ៊ានដកយកទ្រព្យសម្បត្តិបងប្អូន យើងខ្ញុំសូមឲ្យបងប្អូនយកដើងទៅជាន់អាចម៍មកធាក់មាត់យើងខ្ញុំចុះ ។

បទឧទ្ទេសនេះ ធ្វើឲ្យប្រជាជនលួចខ្សឹបខ្សៀវគ្នាពីមាត់មួយទៅមួយ យោបល់រួមបានលើកឡើងថា យើងមិនអាចធ្វើអ្វីផ្សេងពីបំណងអង្គការបានឡើយអង្គការមានភ្នែក ដូចម្នាស់ ។ ម្នាក់ៗបានសម្តែងសេចក្តីស្មោះត្រង់រាយការណ៍ជូនអង្គការ ដោយពុំអាចលាក់លៀម ។ បីថ្ងៃគត់ បន្ទាប់មកអង្គការបានកោះប្រជុំធំមួយឡើងម្តងទៀត ដោយផ្អាកចោលនូវទិវាពលកម្មមួយព្រឹក ដែល

ពេលនោះ ពលកម្មគឺជាកិច្ចការប្រតិបត្តិដ៏តឹងតែង និងប្រុងប្រយ័ត្នខ្ពស់បំផុតរបស់បដិវត្តន៍ ។ យើងបានសម្រាកពលកម្មមួយព្រឹក ប្រៀបដូចជាបានទទួលឱសថទិព្វបង្កើនកម្លាំង ឬដូចជាអ្នកស្រែចុងកាត់ដែលពុំដែលស្គាល់ទីក្រុងសោះ ត្រូវបានឱកាសទៅដើរលេងភ្នំពេញមួយព្រឹកពេញយ៉ាងនឹងដែរ ។ កងកម្លាំងមកពីគ្រប់ទិសគ្រប់សមរភូមិ ស្រែប្រាំង ប្រឡាយ ស្ពានីយ៍ ផលិតផលធម្មជាតិដ៏មហិមារ មានទាំងកងចល័ត កងម៉ែៗចាំចម្ការ កងតាៗ កងកុមារ កងយាយមើលចៅ កងយោធា កងអ្នកមូលដ្ឋានខាងផលិតអង្ករ ខាងបេះបន្លែ កងចុងភៅ បានប្រមូលមកចូលរួមមីទ្ទីងពិសេសនេះ ។

នៅក្នុងអង្គមីទ្ទីងនេះ យើងមិនឃើញមានសមមិត្ត ខ្ញុយ ទេ មានមនុស្សថ្មីផ្សេងទៀត មកពីជួរភូមិភាគជាអ្នកដឹកនាំអង្គមីទ្ទីង ។ ដោយកម្មវិធីពិសេស អង្គការត្រូវជំរុញផលស្រូវវស្សាឆ្នាំ១៩៧៧នេះ ឲ្យសមតាមផែនការមហាលោតផ្លោះ មហាអស្ចារ្យក្នុងមួយហិកតាឲ្យបានផលពី៣ទៅ៦តោនក្នុង១ឆ្នាំ និងធ្វើស្រែឲ្យបាន៣ដងក្នុងមួយឆ្នាំ ។ បងប្អូនគួរតែយល់ដល់ទិសស្លោករបស់អង្គការ ទីណាមានដីទីនោះត្រូវតែមានស្រូវ ហើយបើយើងមានស្រូវ គឺយើងមានអ្វីៗទាំងអស់ សូមបងប្អូនត្រៀមលក្ខណៈបម្រើមាគ៌ាអង្គការឲ្យបានសម្រេចជាដាច់ខាត ។ ដូច្នេះ មាសប្រាក់កែវកងដែលបានចុះបញ្ជីហើយនោះ អង្គការសូមស្នើថាសូមប្រមូលយកទៅជាវយកគ្រឿងកសិកម្មគ្រប់ប្រភេទ ពីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីធ្វើឲ្យកសិកម្មយើងបានជឿនលឿនសម្បូរបែប មហាលោតផ្លោះមហាអស្ចារ្យ មិនចាញ់ប្រទេសមហាសង្គមនិយមនានា លើសកលលោក ។ ខ្ញុំសង្ឃឹមថា បងប្អូនទាំងអស់គ្នានឹងសម្តែងសេចក្តីស្នេហស្មោះចំពោះអង្គការ ដោយនាំយកមកប្រគល់ជូនអង្គការគ្រប់ចំនួនដូចដែលបានចុះបញ្ជីរួចហើយ ។

ជាមួយនឹងចុងបញ្ចប់នៃប្រយោគនេះ គ្រែឫស្សីដ៏ធំមួយបានត្រូវសែងចូលមក មាសពេជ្រកែវកងចាំងដេញពន្លឺថ្ងៃព្រាកៗ បានហូរស្រោចចុះមកពូនគរ យ៉ាងហូរហៀរលើគ្រែ ឫស្សីនោះប្រៀបដូចជាមហាមេឃបានបង្អុរតំណក់ភ្លៀងពេជ្រស្រោចចុះមកយ៉ាងនោះ ។

រដូវវស្សា១៩៧៧ ក្រកោះត្រូវបានប្រសិទ្ធនាមជាសហករណ៍គំរូប្រចាំភូមិភាគពាយ័ព្យទាំងមូល ដែលធ្វើស្រែដោយមានកម្លាំងត្រាក់ទ័រយ៉ាងគគ្រឹកគគ្រេងសម្រាប់ការអូសទាញ ដែលមានគណៈភូមិភាគសមមិត្ត ខ្ញុយ ចុះមកកាន់ក្តាប់ដោយផ្ទាល់ផង ។ យើងសង្ឃឹមថា ទីនេះជាពន្លឺពិតនៃរស្មីបដិវត្តន៍ហើយ ហើយនៅរដូវច្រូតកាត់ខាងមុខប្រហែលជាអង្គការនឹងនាំម៉ាស៊ីនច្រូត ម៉ាស៊ីនបោកបែន ម៉ាស៊ីនកិនស្រូវ ចូលមកទៀតហើយជាមួយនឹងរតនវត្ថុដែលអង្គការប្រមូលយកពីយើងទៅនោះ ។

ប៉ុន្តែ តែប៉ុន្មានថ្ងៃប៉ុណ្ណោះ ត្រាក់ទ័រចេះតែត្រូវដកចេញទៅ កម្លាំងមនុស្សត្រូវដើរតួជំនួសគ្រឿងយន្តឡើងវិញ គ្រប់ទីកន្លែង រហូតដល់ពេលខ្លះគោឈឺ មនុស្សត្រូវបញ្ចូលទៅក្នុងនឹមឲ្យអូសនង្គ័លជំនួសគោក្របីជារៀងរាល់ថ្ងៃផង ។ របបហូបចុកក៏បានឆ្អែតតែប្រមាណ១អាទិត្យប៉ុណ្ណោះ ក្រោយពីនោះមករបបអាហារដែលអង្គការកំណត់ឲ្យយើងនោះកាន់តែថយចុះទៅៗ ។

មកដល់ចុងឆ្នាំ១៩៧៨ ក្នុងពេលដែលស្រូវវស្សាកំពុងតែទុំស្វាបសេករបបអាហាររបស់កងចល័តឈានមុខ ក្នុងសមរភូមិស្រែប្រាំងបានធ្លាក់ចុះរហូតអង្ករមួយកំប៉ុងសម្រាប់មនុស្ស៣០នាក់ អស់រយៈពេលជាច្រើនខែ ។ ភ្នែកព្រឹលមើលព្រះអាទិត្យលែងច្បាស់ហើយ ត្រចៀកហឹកលាន់សូរឮជាអលជ្ជី ពុទ្ធោអើយ! តើហេតុអ្វីទៅ? ហេតុអ្វីមកប្រែប្រួលជំនឿ និងក្តីសង្ឃឹមរបស់យើងឲ្យរលាយទៅវិញទៀតហើយ គិតទៅផែនការរបស់អង្គការនៅទីណាក៏ដូចទីណាដែរ គឺជាផែនការតែមួយប៉ុណ្ណោះ ។

ក្រោមពន្លឺព្រះចន្ទពេញបូណ៌មី ក្នុងពេលដែលរដូវស្រូវទុំពេញវាលឈានចូលមកដល់អធ្រាត្រយប់ជ្រៅដែលកងចល័តទាំងអស់និទ្រាលង់លក់ដោយសារការហត់នឿយដ៏ទារុណដុនដាបក្នុងការសង់ទំនប់ស្ពានីយ៍ ភូមិថ្មីនៃឃុំក្រកោះនេះ ។ ពីរបបមួយទៅរបបមួយ គេបានធ្វើឲ្យលាន់រន្ទឺនូវការរិះគន់របបចាស់ដែលគេបានផ្តួលរំលំទៅ ប៉ុន្តែតើព្រាយបិសាចអ្វីមកបង្វិលបង្វែងមាគ៌ាបដិវត្តន៍ឬ? ហេតុអ្វីក៏ប្រទះតែសង្គមស្វែងល្ងាយ៉ាងនេះ បែបនេះជាសង្គមដែលលោកហៅថា «លោកថាល្ងាដង សម្បកក្រៅហោង ក្លីផ្ទេកយល់យន់ រីឯក្នុងផ្ទៃសុទ្ធតែមមុងគ្រាស់គ្រែនៅក្នុងនេះហោងលោកថា» តើពេលណាទៅទើបអាចជួបនឹងសង្គមខ្ទរណាំងដែលមានសម្បកស្តោកស្តាំងបន្ទាច្រូងនៅតែក្នុងសឹងក្អែបក្រអូប

ផ្តើមទៅទាល់ក្នុងឥតសៅរស់សឹងពិសានោះ? មែនហើយ ទំនួញទួញថ្ងូរសោកវិយោគក្នុងចិត្តប្រជាពលរដ្ឋខ្មែរនៅពេលនោះ គឺការអនិច្ចានឹងជោគវាសនាស្រុកទេស ដែលឃើញតែការផ្លាស់ប្តូរប្រែប្រួលជារបៀបគាស់ស្នែងដាំល្ពៅ ។

នៅពេលនោះ ខ្ញុំរស់ដោយព្រលឹងស្រពាំង ត្រចៀកហឹងស្តាប់អ្វីលែងឮម្តង១ ហើយប្អូនប្រុសតែមួយ និងប្អូនស្រីពៅខ្ញុំបានលាចាកលោកទៅនៅសហករណ៍ភូមិថ្មី ឃុំក្រកោះ ដោយស្រែកសុំតែបាយមួយចម្អែត ។ ក្រុមគ្រួសារយើងដែលមានគ្នា៥នាក់កាលចាកចេញពីភ្នំពេញមក ឥឡូវនេះយើងនៅសល់តែ៣នាក់ដូចមុំចង្ក្រាន ។ ជង្គង់ខ្ញុំកាន់តែទន់ទៅៗ ហើយ ប៉ុន្តែខ្ញុំត្រូវតែចេញទៅធ្វើពលកម្ម អ្នកទម្រន់ជ្រាយនឹងត្រូវអង្គការប្រមាថមាក់ងាយដោយពាក្យអសុរសថា ជាខ្មាំងវណ្ណៈ ខ្ញុំទ្រាំលែងបានហើយ ខ្ញុំលែងចង់រស់ហើយ ខ្ញុំចង់តែស្រែកហៅរកគ្រាប់កាំភ្លើង គ្រាប់បែក ឲ្យមកជំនួសគ្រាប់បាយ ។

រសៀលថ្ងៃបន្ទាប់មានការកោះប្រជុំដ៏ធំមួយ ក្នុងរង្វង់កងចល័តស្នាដីយ៍ក្រកោះ ព្រមទាំងកងម៉ែៗ ភូមិថ្មីប្រមាណ២.០០០នាក់ ។ បន្សល់ទុកតែចល័តកងពលតូច ខ្ញុំត្រូវអង្គការចាត់តាំងឲ្យនៅចាំលានស្រូវទុំ ។ យើងបោកស្រូវបណ្តើរបប្អូលគ្នាគិតបណ្តើរថា តើគេប្រជុំពីរឿងអ្វី ហេតុអ្វីក៏អង្គការមិនឲ្យកងយើងបានទៅចូលរួមនឹងគេ កងយើងសិយណាស់ គេបានទៅអង្គុយប្រជុំរួចពីពលកម្មក៏យ៉ាប់យឺនមួយល្ងាច យើងនៅរងការនឿយលំបាកពេញមួយល្ងាច ប៉ុន្តែល្ងាចនេះ គ្មានអ្នកមូលដ្ឋានណាម្នាក់នៅកាន់ក្តាប់ការងារលើយើងទេ នៅសល់ត្រឹមតែមេកងប្រជាជនថ្មីដូចគ្នាយើងអាចធ្វើការលេងៗយករួចខ្លួនបាន និងយើងមានឱកាសលួចលាក់លីងស្រូវទុំនេះ គេះហូបសម្រន់ការស្រេកឃ្លានបាន ។ ពេលព្រលប់អ្នកចេញពីប្រជុំបានវិលមកវិញយ៉ាងឈូរឆរជាមួយនឹងការចចារឆ្លើយឆ្លងគ្នា ដោយវិភាគទៅលើអត្ថបទកាព្យអនាមឹកពីរបទ ដែលសមមិត្តពូ យ៉ាន រើសបានលើពំនូកស្រូវកាលពីម្សិលមិញ ។

ខ្ញុំសន្និដ្ឋានថា សមមិត្តពូ យ៉ាន បានប្រឌិតចំណុចនេះឡើងដើម្បីសង្គ្រោះជីវិតខ្ញុំហើយ ប៉ុន្តែតើវាមានឥទ្ធិពលអ្វីអាចធ្វើឲ្យពូយ៉ាន សម្រេចចិត្តរៀបចំកិច្ចប្រជុំវិភាគអត្ថបទនេះយ៉ាងមហោឡារិកយ៉ាងនេះ? ខ្ញុំព្រឺក្បាលខ្វាកៗ ស្មានមិនដល់សោះថា ការទុកកងចល័តឲ្យនៅចាំលាន គឺជាការរៀបចំដ៏ពោរពេញដោយឆន្ទៈមនុស្សធម៌របស់សមមិត្តពូ យ៉ាន គណៈសហករណ៍ ។ នោះក៏ព្រោះតែពាក្យដែលមិត្តកងចល័តខ្លះ បានលួចខ្សិបគ្នាថា លោកពូយ៉ាន ជាអតីតសាស្ត្រាចារ្យខ្មែរ នៅវិទ្យាល័យព្រះខ័យ ខេត្តតាកែវ គឺជាការត្រឹមត្រូវ ។ បើក្រៅពីដៃលោកសាស្ត្រាចារ្យជីវិតច្បាស់ជាត្រូវបញ្ចប់ពេលនោះហើយ ។

### វិប្បដិសារី តួឥតវាសនា
### អាពាហ៍ពិពាហ៍ទាំងហ្វូង

ថ្ងៃនេះ មីក្រូប្រចាំស្នាដីយ៍ក្រកោះ បានចាក់បទចម្រៀងបដិវត្តន៍តាំងពីព្រលឹមមកម៉េ្ះ "ថ្ងៃណាក៏បុណ្យ បុណ្យជារៀងរាល់ថ្ងៃ នេះហើយសម័យ សម័យបដិវត្តន៍ ជោគជម្នះបានជាប្រាកដ" ។ "យើងដាំដាំដាំគ្រប់អ្វីៗ ដាំមិនឲ្យសល់ដីមួយចម្អាមឡើយ" ។ ឱ! ចម្រៀងបដិវត្តន៍អើយ អ្នកពិរោះខ្ទ័រខ្ទរគួរឲ្យពលកររគ្រប់រូបមានទឹកចិត្តណាស់ អ្នកហាក់កំពុងលើកទឹកចិត្តពលករកម្មករ កសិករ យ៉ាងពេញទំហឹង ប៉ុន្តែកម្លាំងចិត្តដែលបក្សផ្តល់ឲ្យនេះវាហាក់ដូចជាគ្រាន់តែជាមាយាសិល្បៈ ដែលតាមពិតទៅវាគ្រាន់តែជាមោទកភាពសម្រាប់យោធា កម្មាភិបាលបដិវត្តន៍ និងអ្នកមូលដ្ឋាន ឬប្រជាជនចាស់១៨ មីនា តែឯកងឯងប៉ុណ្ណោះចំណែកឯប្រជាជនថ្មី ឬអ្នក១៧មេសា គឺជាកសិទាសករ ឬជាចំណាប់ខ្មាំងដ៏ជាសត្រូវជួជាតិរបស់បដិវត្តន៍ ។ ឱ! បដិវត្តន៍អើយម្តេចឡើយអ្នកធ្វើឲ្យវណ្ណៈកសិករ វណ្ណៈអធនដែលអ្នកធ្លាប់ពោលថានឹងលើកស្ទួយឲ្យមានសិទ្ធិសេរី ម្ចាស់ការលើជោគវាសនាខ្លួនឯង និងលើវាសនាជាតិមាតុភូមិនោះ កាន់តែក្រលំបាកគោកយ៉ាកគ្មានប្រដូចយ៉ាងនេះ ។

ចម្លាស់ជាមួយនឹងបទចម្រៀងនេះ ព័ត៌មានបដិវត្តន៍ផ្សព្វផ្សាយឡើង "សូមគោរពសមមិត្តកម្មាភិបាល យោធា យុទ្ធជនយុទ្ធនារីបដិវត្តន៍ សូមគោរពពុកម៉ែប្រជាជន និងយុវជន យុវនារីកងចល័តទាំងអស់ ថ្ងៃនេះវិទ្យុសំឡេងបដិវត្តន៍ សូមជូនព័ត៌មានអំពីភូមិភាគបូព៌ាៈ អំពីសកម្មភាពនៃការដ្ឋាន កសិដ្ឋាននានា នៅខេត្តព្រៃវែង ។ នៅចុងរដូវវស្សា ឆ្នាំ១៩៧៨ នេះ ការសង់ទំនប់ប្រឡាយភ្ជោះ ពីវាលទួលសំពៅង កាត់វាលស្រែភូមិព្រែកណ្ដៀង

រហូតទៅដល់ភូមិព្រៃខ្លា ត្រូវបានយុទ្ធជន យុទ្ធនារីបដិវត្តន៍ ដឹកនាំសម្រុកការសាងសង់ សម្រេចជាស្ថាពរហើយ» ។ ពុទ្ធោអើយ! ព្រៃកណ្តៀង ទួលសំរោងអើយ ទីដែលបង កន ត្រូវកន្ទុំរុយរបស់ទាហាន លន់ នល់ បាញ់ត្រូវស្មាហើយដែលអ៊ំ សៀន រត់លូនកាត់គ្រាប់រុក្កែតដេញតាមមើលសុខទុក្ខបង កន ទួលដែលបងគង់ សម្រេចចិត្តចាកចោលពួកយើង រត់ចូលបដិវត្តន៍! នេះជាថ្ងៃទី១ហើយ ក្រោយពីការនិរាស្រ្តព្រាត់ចេញពីស្រុកកំណើត៧ឆ្នាំមក ខ្ញុំទើបនឹងបានឮដំណឹងពីវា ។ ព្រៃវែង ទួលសំរោង ព្រៃកណ្តៀងអើយ ខ្ញុំនឹកអ្នកណាស់ «ឱ! ស្រុកកំណើតអើយ ថ្ងៃណាឡើយបានជួបអ្នកវិញ ឬគ្រួសារយើងនឹងត្រូវវាបាត់បង់ជីវិត ទាំងអស់គ្នានឹងក្លាយជាខ្លាញ់ដីនៅលើដីខ្លាញ់នេះ លែងបានស្គាល់ស្រុកកំណើតយើងជារៀងរហូត ឬយ៉ាងណា?

អូរ! ព័ត៌មានពីភូមិភាគបូព៌ាមិនទាន់ចប់ទេ! យើងស្តាប់គទៅទៀតសិន ៖ «ជាបន្តទៅនេះ សូមជូនព័ត៌មានការបរទេសកាលពីសប្តាហ៍មុននេះ សមមិត្តប្រធានមជ្ឈិមបក្ស និងជាប្រធានបក្សពលករវៀតណាម បានដឹកនាំបក្សពលករវៀតណាមក្នុងដំណើរទស្សនកិច្ចមួយមកកាន់ភូមិភាគបូព៌ា ។ សមមិត្ត សោ ភឹម ប្រធានភូមិ ភាគភូមិភាគបូព៌ាបានរៀបចំបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ ចំពោះគណៈប្រតិភូនេះ» ។ ឱ! ភូមិភាគបូព៌ាអើយ នេះជាថ្ងៃទី១ហើយ ក្រោយបដិវត្តន៍ទទួលជោគជ័យជិត៣ឆ្នាំមក ខ្ញុំទើបនឹងបានឮឈ្មោះប្រធានភូមិភាគបូព៌ា (សមមិត្ត សោ ភឹម) ដែលជាភូមិភាគរបស់ខេត្តព្រៃវែង បូព៌ា-ពាយ័ព្យ ៤០០-៥០០ គីឡូម៉ែត្រពីគ្នា តែយើងសែនឆ្ងាយពីគ្នា ឆ្ងាយហួសពីជើងមេឃ ។ ជើងមេឃមិនដឹងនៅឯណាទេ តែអ្នកវិទ្យាសាស្ត្រមានសេរីភាពនឹងសិក្សាពីវា ប៉ុន្តែរូបគ្រួសារដែលជាប់ក្នុងទ្រុងជញ្ជាំងនៅពាយ័ព្យនេះ គ្មានថ្ងៃស្គាល់បូព៌ាឡើយ ។ ឱ! បូព៌ាអើយ ថ្ងៃណាឡើយ បានឃើញអ្នកវិញ ។

កិច្ចប្រជុំបើកវគ្គសម្រុកប្រមូលផលស្រូវប្រាំងលើកទី៣ឆ្នាំបានបើកឡើង ។ ទីលានបោកស្រូវនៅស្ថានីយ៍ក្រកោះថ្ងៃនេះ មានកិត្តិយសទទួលពលករដ៏ស្គមស្គាំងរីងរៃរាប់ពាន់នាក់ ឲ្យមកអង្គុយត្របោមក្បាលជង្គង់យ៉ាងកុះករត្រៀបត្រា ដើម្បីស្តាប់កិច្ចប្រជុំ ។ អ្នកជួរមុខៗ ត្រូវតែខំបង្ហាញទឹកមុខថា ទាក់អារម្មណ៍ណាស់នឹងកិច្ចប្រជុំ ចំណែកឯអ្នកអង្គុយជួរក្រោយៗ អាចឆ្លៀតឱកាសផ្ទេចភ្នែកងោកយកកម្លាំងបណ្តើរស្តាប់កិច្ចប្រជុំបណ្តើរ ។ អង្គការមិនមែនមិនដឹង មិនឃើញពីទិដ្ឋភាពបែបនេះទេ ប៉ុន្តែពួកគាត់ក៏នៅមានបេះដូងជាមនុស្សខ្លះដែរ ប្រសិនបើបេះដូងពួកគាត់ត្រូវមនោគមន៍វិជ្ជាបដិវត្តន៍ចងជាប់ដូចជាមនុស្សយន្តវិញ ច្បាស់ជាពួកយើងត្រូវគេកាប់សម្លាប់បំបាត់ពូជសាសន៍ក្នុងពេលយ៉ាងខ្លី ។ ខ្ញុំចង់មានន័យថា កំហុសជាច្រើនទៀតដែលប្រជាជនថ្មីបានប្រព្រឹត្តឡើងផ្ទុយពីឆន្ទៈបដិវត្តន៍របស់គេ ដូចលួចបេះស្លឹកឈើដាក់ក្នុងហោប៉ៅ ក្នុងម៉ោងធ្វើការ ដើម្បីស្លហូបក្រោយពីម៉ោងពលកម្មចប់ទៅ មិនមែនអាចលាក់បាំងពីភ្នែកអង្គការមួយរយភាគរយនោះទេ ប៉ុន្តែអង្គការក៏នៅសល់ចំណែកបេះដូងឈាមជ័រជាមនុស្សខ្លះដែរ ដែលពួកគាត់បានធ្មេចភ្នែកទុកឲ្យពួកយើង ត្រដរបេះបោចដើម្បីបន្តរស់ជាកសិទាសករបម្រើនយោបាយរបស់អង្គការតទៅទៀត ។

អង្គប្រជុំចាប់ផ្តើមហើយ សមមិត្តពូ ខូយ អនុប្រធានភូមិភាគពាក្យបានធ្វើការចាប់អារម្មណ៍ៈ សូមគោរពសមមិត្ត សមមិត្តនារីកម្មាភិបាលបដិវត្តន៍ យុទ្ធជន យុទ្ធនារីបដិវត្តន៍ សូមគោរពពុកម៉ែ ប្រជាជន បងប្អូនមីមាក្មួយៗកុមារា កុមារី និងយុវជនយុវនារីកងចល័តទាំងអស់ជាទីគោរព និងស្នេហាបដិវត្តន៍យ៉ាងជ្រាលជ្រៅ តាងនាមអង្គការថ្នាក់លើ ថ្ងៃនេះខ្ញុំសូមសម្តែងនូវការស្ងើចសរសើរចំពោះវីរភាពដ៏ក្លៀវក្លារបស់កម្មាភិបាល យុទ្ធជនបដិវត្តន៍ ក៏ដូចជាស្មារតីយកចិត្តទុកដាក់ខ្ពស់របស់ពុកម៉ែប្រជាជន និងកងចល័តទាំងអស់ ដែលបានធ្វើឲ្យផែនការស្តារវិស័យកសិកម្មដែលអង្គការថ្នាក់លើបានដាក់ទិសធ្វើស្រែមួយឆ្នាំ៣ដង និងមួយហិកតាបានផលពីបីទៅប្រាំមួយតោនឲ្យទៅជាការពិត ។ ស្នូរទះដៃបានលាន់ឮឡើងយ៉ាងកងរំពងបន្ទរពីក្រោយក្តីសរសើរនេះ ដែលថ្ងៃនេះ វាហាក់ដូចជាផុសចេញពីមនោសញ្ចេតនាពិតៗរបស់សមមិត្តពូ ខូយ គាត់បន្តទៀតថា ក្នុងការចាប់ផ្តើមយុទ្ធនាការសម្រុកប្រមូលផលស្រូវប្រាំងវគ្គលើកទី៣ នៅវាលស្ថានីយ៍ក្រកោះយើងនេះ ខ្ញុំសូមជម្រាប និងដាស់ស្មារតីសមមិត្ត សមមិត្តនារីកម្មាភិបាលបដិវត្តន៍ យុទ្ធជន យុទ្ធនារី បដិវត្តន៍ ពុកម៉ែ ប្រជាជនបងប្អូនមីងមា ក្មួយៗកុមារា កុមារី និងយុវជន យុវនារីកងចល័ត បដិវត្តន៍ទាំងអស់ សូមឲ្យមានស្មារតីប្រុងប្រយ័ត្នបដិវត្តន៍បែបនេះ ជាប់ជាប្រចាំ និងជានិច្ចជាកាល ពីព្រោះថា ថ្មីៗនេះ អង្គការបានក្តាប់បាន

នូវសភាពការណ៍ខ្លាំង ។ ខ្ញុំសូមជម្រាបថា ថ្មីៗនេះ អង្គការបានចាប់បានខ្មាំង និងខ្សែរយៈបង្កប់បានអស់ហើយ មានទាំង សោ ភឹម អតីតប្រធានភូមិភាគបូព៌ា និង រស់ ញឹម អតីតប្រធានភូមិភាគពាយ័ព្យទាំងពីរអ្នកជាដន្លងនឹងគ្នាហើយឃុបឃិតគ្នាយកយួន មកលាក់ដល់ទន្លេសាប ។ អង្គប្រជុំទាំងមូលស្ងាត់ដូចចោរលួចសេះ ម្នាក់ៗសឹងមិនហ៊ានកម្រើកខ្លួនទេ ខំផ្ទៀងស្តាប់ព្រឹត្តិការណ៍នេះ ។ សមមិត្តពូ ខ្ជួយ បន្តទៀតថា បងប្អូនជ្រាបស្រាប់ហើយ អង្គការមានភ្នែកដូចភ្នែកម្នាស់ គ្មាននរណាម្នាក់អាចធ្វើអ្វីកំបាំងនឹងភ្នែកអង្គការបានទេ ហើយមាគ៌ាអង្គការតែកាលណាដឹកស្មៅ គឺត្រូវដឹកទាំងឫស ។

ប្រយោគចុងក្រោយនេះ ប្រហែលជាគាត់ចង់គំរាមថា អាចមានខ្មាំងបង្កប់នៅទីនេះឬ? ទោះបីជាមានការគំរាមយ៉ាងនេះ ក៏យើងហាក់ដូចជាដកដង្ហើមបានធូរបន្តិច ប្រសិនបើមានខ្មាំងបង្កប់មែន យើងអបអរឲ្យតែមានទេ ក្រែងលោបដិវត្តន៍ណាថ្មីអាចកើតមានឡើង នេះជាការវិភាគនៅក្នុងចិត្តរបស់ប្រជាជនថ្មីម្នាក់ៗ ។ សមមិត្តពូ ខ្ជួយ បន្តទៀត ថា ចុងឆ្នាំ១៩៧៨នេះ ការបង្កើនចំនួនប្រជាពលរដ្ឋជាទិសដៅថ្មីមួយទៀតរបស់យុទ្ធសាស្ត្របដិវត្តន៍ដើម្បីបន្តពង្រីកផែនការស្តាកសិកម្មជាតិឲ្យរីកទៅទូទាំងប្រទេស និងបន្តពង្រីកប្រពៃណីធ្វើស្រែ១ឆ្នាំ ៣ដងទៅមុខទៀត ។ នេះមកពីគុណសម្បត្តិខ្ពស់របស់ជាប្រជាជនថ្មី ដូចខ្ញុំបានលើករួចមកហើយ បក្សបានដាក់ចុះនូវទិសដៅរៀបចំគូស្រករជូនយុទ្ធជន យុទ្ធនារី ក៏ដូចជាយុវជន យុវនារីចល័តដោយលែងគិតថា ជាប្រជាជនចាស់ ឬប្រជាជនថ្មីអ្វីទៀតហើយ ។ អង្គប្រជុំបានបញ្ចប់ទៅ ដោយស្នូរទះដៃអបអរសាទរបានលាន់ឮឡើង ។

ពិពាហ៍រវាងអ្នកមូលដ្ឋានចាស់ ឬអ្នក១៨មីនា ជាមួយអ្នកជម្លៀសថ្មី ឬប្រជាជន១៧មេសា មិនត្រឹមតែជាការហាមឃាត់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវចាត់ទុកថាជាខ្មាំងសត្រូវរបស់បដិវត្តន៍ទៀតផង អ្នកប្រព្រឹត្តល្មើសនឹងក្រមសីលធម៌បដិវត្តន៍ខត្តុង្គខត្តមនេះត្រូវបានប្រហារជីវិតជាច្រើនគូមកហើយ ។ រវាងអ្នកថ្មី និងអ្នកចាស់មិនបាច់និយាយចេញមកទេ សូម្បីតែសំបករូបរាងក៏បង្ហាញពីស្រទាប់វណ្ណៈដែលដាច់ស្រឡះរួចទៅហើយ ពីព្រោះថា អ្នកមូលដ្ឋានមានសាច់ឈាមស្រស់ថ្លាទ្រលុកទ្រលន់ ម្នាក់ៗស្ថិតក្នុងសម្លៀកបំពាក់ខ្មៅក្រិប បង់កក្រមាក្រហម ឬខៀវថ្មីៗមានក្រឡាចាស់ និងពាក់ស្បែកជើងកង់ឡានយ៉ាងសមសួន ។ ផ្ទុយទៅវិញ ខាងប្រជាជនថ្មី មានរូបរាងស្គមកំព្រឹង ស្លេកស្លាំង សើងមមើងកន្ទ្រើងកន្ទ្រើង ក្នុងសម្លៀកបំពាក់ខ្មៅដែរ ប៉ុន្តែចាស់រយីករយាកពក្លិកពក្លាក់ បំណះមុខក្រោយ យ៉ាងពិបាកភ្នែក ។

យុទ្ធសាស្ត្រថ្មីឆ្នាំ១៩៧៨នេះ បក្សបានប្តូរទិសយ៉ាងក្រឡាប់ចក្រ ដោយហែកចោលនូវជញ្ជាំងវណ្ណៈនៃព្រំខណ្ឌស្នេហាយុវវ័យចោល បក្សមិនត្រឹមតែអនុញ្ញាតទេ ប៉ុន្តែជាការជំរុញយ៉ាងខ្លាំងនូវអាពាហ៍ពិពាហ៍ទាំងហ្វូង ដោយលែងគិតថានរណាជានរណា ឬជាស្រទាប់ណាទាំងអស់ ។ ពិតជារកស្មានមិនដល់មែន ។ នៅការដ្ឋានស្ថានីយ៍ស្រែប្រាំងភូមិថ្មី ក្រកោះថ្ងៃនេះ មាន៧០គូត្រូវត្រៀមខ្លួនបំពេញភារកិច្ចជូនបក្ស ក្នុងទិសដៅផែនការកសាងគ្រួសារជូនយុវវ័យឲ្យមានលទ្ធភាពបង្កើតពលរដ្ឋថ្មីទៀត ដើម្បីបង្កើនពលកម្មសម្រាប់ការប្រយុទ្ធស្តាកសិកម្ម និងសេដ្ឋកិច្ចជាតិឲ្យបានសមតាមទិសស្លោកមហាលោតផ្លោះ មហាអស្ចារ្យរបស់មាគ៌ាបដិវត្តន៍ ។

រង្វាន់នៃមង្គលការដែលមានការបើកសម្លៀកបំពាក់ខ្មៅក្រិបថ្មីបែសមួយកំប្លេរម្នាក់ និងពិធីជប់លាងអាហារល្ងាចមួយចម្អែតដោយមានបង្អែមលាងមាត់ផង បានបន្តក្រោយពីការតម្រង់ជួរចាប់ដៃគ្នាមានអ្នកតំណាងពីរទៅបីគូឡើង ធ្វើសេចក្តីប្តេជ្ញាចិត្តកសាងគ្រួសារ តាមមាគ៌ាកំណត់របស់បក្សបានឈានដល់ទីបញ្ចប់ ។ គូនីមួយៗត្រូវទទួលទិសកំណត់របស់បក្ស ដោយត្រូវនាំគ្នាឆ្ពោះទៅកាន់កូនគេហដ្ឋានស្បូវសង់ថ្មីតូចៗ មានទំហំប្រមាណ២,៥០ម៉ែត្រ គុណនឹង ៤ម៉ែត្រ ក្នុងវេលាយប់ដ៏ងងឹតឈឹង ។ បាតុភូតវង្វេងគូជាច្រើនបានកើតឡើង តែគ្មាននរណាហ៊ានតវ៉ាសើរើទេ ពីព្រោះថាគោលការណ៍ និងទិសកំណត់របស់បក្សសុទ្ធតែរកស្មានមិនដល់បាន ហើយបើតវ៉ាទៅសុទ្ធតែអ្នកដែលខ្លួនមិនស្គាល់ដដែល ជាដដែល ដូច្នោះគូដែលអង្គការចាប់ដាក់ឲ្យនោះក៏គ្មានអ្វីប្រសើរជាងការស៊ូទ្រាំផ្សងព្រេងទទួលយកគូដែលប្រឡំនេះឡើយ ។

**(តទៅលេខក្រោយ)**

**អ៊ុខ ចណ្ណា**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ *truthpdara@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




***សូមផ្ដល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្ដាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្ដាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្ដល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 220, April 2018 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.